ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-May-2017, 14:20
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពិរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី២៩៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

កញ្ញា ជា ស៊ីវហ័ង

កញ្ញា ម៉ាដាលេណា ហ្គេហ្សី
*(Ms. Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆរ័ន្ត

លោក សេង លាង

លោក ឌេល លីសាក់ *(Dale Lysak)*

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោក យាន លន់ (2-TCW-830) | ខ្មែរ |
| លោកស្រី គង់ សៀក (2-TCCP-261) | ខ្មែរ |
| លោក សែម ហឿន (2-TCW-943) | ខ្មែរ |

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅសាក្សី៖ លោក យ៉ាន លន់ (2-TCW-830)

សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី ....................................................ទំព័រ ២
សួរដោយលោក គង់ សំអុន ផ្ដើមពី ....................................................ទំព័រ ១៣

## ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី គង់ សៀក (2-TCCP-261)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................................................ទំព័រ ២២
សួរដោយលោកស្រី ទី ស្រ៊ុនណា ផ្ដើមពី ....................................................ទំព័រ ២៤
សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលីណេ ផ្ដើមពី ....................................................ទំព័រ ៤០
សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្ដើមពី....................................................ទំព័រ ៤៦
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ....................................................ទំព័រ ៥២
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី....................................................ទំព័រ ៥៣

## ការសួរសំណួរទៅសាក្សី៖ លោក សែម ហឿន (2-TCW-943)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................................................ទំព័រ ៧៤
សួរដោយលោក នីកូឡាស គូមជែន ផ្ដើមពី ....................................................ទំព័រ ៧៦

# កិច្ចដំណើរការនីតិវិធី

[០៩:០៤:១២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មសាក្សី យាន លន់ បញ្ចប់ ផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-261 និងអាចផ្តើមស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-943។ ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក យាន លន់ លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះដែរ មានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូប ដែលមានរហស្សនាម TCCP-261 និងមានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម TCW-943។ តាមព័ត៌មានពីអង្គភាពសាក្សី និងអ្នកជំនាញ បានបញ្ជាក់ថា សាក្សីរូបនេះ នឹងមកដល់តុលាការនៅថ្ងៃនេះ។ សាក្សីនឹងធ្វើសម្បថនៅមុខចំពោះលោកតាដំបងដែកនៅល្ងាចនេះ។

សូមអរគុណលោកប្រធាន។

[០៩:០៦:២០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដោយគាត់

មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង មានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាលថែទាំងសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះខ្លាំង និងវិលមុខពេលអង្គុយ និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីខាងក្រោម -- ពីបន្ទប់នៅខាងក្រោមសាលសវនាការនេះ។

[០៩:០៧:២៣]

ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់ រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។

[០៩:០៨:២០]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំនឹងបន្តសួរមួយចំនួនទៀតដើម្បីសូមការបំភ្លឺមួយចំនួនពីលោក។ ដូចកាលពីម្សិលមិញដែរ សូមឲ្យលោកស្តាប់ដោយយកចិត្តទុកដាក់ ខ្ញុំសួរខ្លីៗទេ ហើយសូមឲ្យលោក

ឆ្លើយឲ្យចំៗទៅនឹងសំណួររបស់ខ្ញុំ។ លោកបានឆ្លើយថា លោកបានធ្វើការនៅទំនប់ ដោយលោកជីកប្រឡាយ តើលោកឯកភាពទេថា លោកធ្វើការហ្នឹង គឺនៅក្នុងឃុំកំពង់ថ្ម?

**លោក យាន លន់៖**

**ឆ៖** បាទ គឺខ្ញុំបានធ្វើនៅក្នុងឃុំកំពង់ថ្ម ទំនប់ហ្នឹង គឺខ្ញុំឯកភាព។ ខ្ញុំបានធ្វើ។

**ស៖** តើលោកដឹងទេថា ពីកន្លែងដែលលោកធ្វើការ ហើយនិងអាងទំនប់ហ្នឹងវាមានចម្ងាយប៉ុន្មានគីឡូម៉ែត្រពីគ្នាដែរ?

**ឆ៖** បាទ គឺខ្ញុំបាទ គឺស្មានមិនត្រូវដែរ មិនដឹងស្មាន ប៉ុន្តែខាងកើតវត្តកំពង់ថ្ម។

**ស៖** កាលពីម្សិលមិញលោកបានឆ្លើយថានៅការដ្ឋានសាងសង់ទំនប់ហ្នឹង គឺអត់មានគ្រឿងចក្រទេ។ ដូច្នេះលោកមានន័យថា នៅទំនប់ហ្នឹងទាំងមូលតែម្តងហ្នឹង គឺគ្មានគ្រឿងចក្រទេ ឬក៏លោកសំដៅតែនៅកន្លែងលោកធ្វើការហ្នឹងទេ ដែលគ្មានគ្រឿងចក្រនោះ?

[០៩:១០:១៧]

**ឆ៖** បាទ គឺការងារពីកាលនោះ គឺអត់មានគ្រឿងចក្រទេ គឺគ្រឿងចក្រហ្នឹង កាប់នឹងចបទេបាទ គឺអត់មានទេ។ មនុស្សរែកតែម្តង គឺគ្រឿងចក្រកាលនោះ កាប់នឹងចបកាប់។

**ស៖** ខ្ញុំនិយាយបែបនេះ ពីព្រោះថាបុគ្គលមួយចំនួនដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការនេះ គាត់បញ្ជាក់ថានៅកន្លែងខ្លះនោះគេប្រើប្រាស់គ្រឿងចក្រ ដូចជា<ម៉ាស៊ីនឈូសដី> និងក៏មានម៉ាស៊ីនកាយដី<>ហើយ<ជួនកាល>គេប្រើរំសេវដើម្បីកម្ទេចថ្ម<នៅកន្លែងខ្លះទៀតផង>។ ដូច្នេះលោកកែប្រែគោលជំហររបស់លោកទេ ឬក៏លោកនៅតែរក្សាជំហររបស់លោកដដែល ថាអត់មានគ្រឿងចក្រ អត់មានអីទេ?

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមជំទាស់ គឺថាមេធាវីគាត់អាចសួរដេញដោលសាក្សីដោយយកសក្ខីកម្មរបស់អ្នកដទៃ អត់បញ្ហាទេ។ ប៉ុន្តែការដែលគាត់សួរថា នៅពេលដែលគាត់ផ្តល់សក្ខីកម្មរបស់អ្នកដទៃ ហើយគាត់សួរសាក្សី ថាសាក្សីប្តូរគំនិតឬក៏អត់ អាហ្នឹងវាហាក់ដូចជាមិនសមស្របទេ។ ព្រោះថាសាក្សី<ជាច្រើននាក់បាន>និយាយ<ថាមិនមាន>គ្រឿងចក្រ<ទេ>។ ដូច្នេះគាត់<មិន>គួរ<លើកយកសក្ខីកម្មរបស់សាក្សីផ្សេងហើយសួរឲ្យសាក្សីនេះផ្លាស់ប្តូរចម្លើយរបស់គាត់ទេ។ មេធាវីអាចដេញដោលសាក្សីរូបនេះជាមួយព័ត៌មានជាក់លាក់តាមបំណងប្រាថ្នារបស់ខ្លួនបាន>។

**កញ្ញា អង់តា ហ្គីសសេ៖**

មិនបញ្ហាទេ លោកសហព្រះរាជអាជ្ញា ខ្ញុំអាចធ្វើអ៊ីចឹងបាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី នៅចំពោះមុខតុលាការនេះ យើងមានសាក្សីមួយចំនួន ខ្ញុំយោងទៅលើសាក្សី ប៊ិច សុខា។ ប្រតិចារឹកសវនាការ E1/303.1<>គឺក្រោយម៉ោងដប់ហាសិបប្រាំពីរនាទី គេសួរគាត់ដូចតទៅ៖ “លោកសាក្សី តើលោកចាំគេប្រើម៉ាស៊ីន ឬក៏គ្រឿងចក្រអ្វីនៅការដ្ឋានទេ?” គាត់ឆ្លើយនៅពេលនោះថា៖ “បាទ ខ្ញុំចាំ។ យើងមានគ្រឿងចក្រមែន មាន<ម៉ាស៊ីនឈូស និងម៉ាស៊ីនកាយដី>។” សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើលោកដឹងទេថានៅកន្លែងផ្សេងក្រៅពីកន្លែងដែល<>លោកធ្វើការហ្នឹង គេមានប្រើ<ម៉ាស៊ីនឈូសដី ឬម៉ាស៊ីនកាយដីដែរឬ>ទេ?

**លោក យាន លន់៖**

**ឆ៖** បាទ គឺតាមខ្ញុំដឹង ដែលខ្ញុំឃើញ ហើយបានចប់មួយទំនប់ហ្នឹង គឺគ្មានទេ គ្មានអាប៊ុល គ្មានអាត្រាក់អីចូកទេបាទ។ មួយទំនប់១មករា ទល់ទៅនឹងផ្លូវថ្នល់ជាតិទៅលិច ភ្នំសន្ទុកទៀត គឺអត់មានទេ គឺពួកខ្ញុំដើរធ្វើមួយចប់ហ្នឹង គ្មានអាប៊ុល គ្មានអីទេ មានតែចបកាប់ទេបាទ។

[០៩:១៣:៥០]

**ស៖** តើលោកអាចជម្រាបបានទេថា លោកធ្វើការនៅ<ទីកន្លែង>ណាដែរ? លោក<ថាពីដំបូងលោកធ្វើការនៅកំពង់ថ្ម តើលោក>អាចបញ្ជាក់<ពី>កន្លែង<នានា>ដែលលោកធ្វើការហ្នឹង នៅ<ការដ្ឋានទំនប់ហ្នឹងបាន>ដែរ<ឬទេ>?

**ឆ៖** កន្លែងនោះគឺ កន្លែងគេតាមកងតាមក្រុម តាមដំណាក់ៗគេ គឺខ្ញុំមិនស្គាល់ទេ ប្រធានគេធ្វើដំណាក់ៗ ប៉ុន្តែវាប្រធាន មានប្រធានក្រុមប្រធានកងអីតូចៗទៅ គេធ្វើតាមហ្នឹងទៅជាប់។ ក៏ប៉ុន្តែដល់និយាយពីធ្វើ ដែលថាហ្នឹង--

**ស៖** <>លោកសាក្សី ខ្ញុំមិនមែនសួរអ៊ីចឹងទេ។ លោកបានឆ្លើយប្រាប់ខ្ញុំថា លោកបានទៅកន្លែងជាច្រើននៅ<ការដ្ឋាន>ទំនប់<នោះ។> ខ្ញុំមិនសួរឈ្មោះប្រធានកង ប្រធានអីទេ ខ្ញុំចង់សួរ<>កន្លែងណាខ្លះដែលលោកបានទៅធ្វើការនោះ<។> ព្រោះលោកបញ្ជាក់ថា លោកធ្វើការនៅច្រើនកន្លែង នៅការដ្ឋានហ្នឹង អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ជាក់ឈ្មោះកន្លែងនីមួយៗនៅការដ្ឋានហ្នឹង។

**ឆ៖** បាទ គឺចាប់ពីកកោះមក ទល់មកខាងជើងភូមិផ្គុង មកទល់នឹងទឹកវិល មកទល់នឹង១មករា

បាទ មួយទំនប់ហ្នឹងមួយចប់ហ្នឹង ច្រើនកន្លែងណាស់។ ព្រោះកងនីមួយៗផ្លាស់ប្ដូរគ្នា អ្នករែកដីភូមិនេះផ្លាស់ទៅភូមិនោះ ភូមិនោះផ្លាស់មកខាងណេះ។ ប្ដូរគ្នាចុះឡើងៗ បាទ។

[០៩:១៦:០៦]

**ស៖** ចុះកន្លែងផ្សេងៗដែលលោកធ្វើការហ្នឹង គឺលោកធ្វើការក្នុងរយៈពេល៣ខែ ដូចដែលលោកបានបញ្ជាក់កាលពីម្សិលមិញមែនទេ?

**ឆ៖** បាទ ដូចហ្នឹងហើយ។

**ស៖** ខ្ញុំយល់ថា លោកទទួលខុសត្រូវលើក្រុមមួយដែលមានគ្នា៥០ទៅ៦០នាក់។ ចុះពាក់ព័ន្ធនឹងការរៀបចំម្ហូបអាហារ តើលោកធ្វើយ៉ាងម៉េច? គឺមានចង្ក្រានបាយដាំស្លអីនៅកន្លែងដែលលោកធ្វើការហ្នឹងផ្ទាល់តែម្ដង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ គឺកន្លែងនៅផ្ទាល់នៅកន្លែងហ្នឹង គឺហើយម្ហូបម្ហាអីគឺដោះស្រាយទៅតាមភូមិ មកយកពីភូមិទៅ ជួយឲ្យអ្នកភូមិជួយ អ្នកខាងក្រោយនេះគេជួយអ៊ីចឹងទៅ។ ជាប់រែកដី ហើយក៏មានកម្លាំងហ្នឹងយកម្ហូបម្ហា អង្ករស្រូវអីទៅឲ្យទៅ បាទផ្ដល់ឲ្យទៅ។

**ស៖** នៅក្នុងកងរបស់លោក តើមានអ្នកណាម្នាក់ទទួលខុសត្រូវក្នុងការដាំស្លទេ?

**ឆ៖** បាទ គឺមាន។

[០៩:១៧:២៧]

**ស៖** កាលពីម្សិលមិញ<បើខ្ញុំមិនច្រឡំទេនោះ> លោកក៏បាននិយាយថា លោក<>ជីកអណ្ដូង<យកទឹកប្រើ>។ ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវីដា គាត់បានពន្យល់កាលពីសវនាការថ្ងៃទី០២<ខែមិថុនា> ឆ្នាំ២០១៥ <គឺ>ឯកសារ E1/308.1។ ពេលនោះគេសួរគាត់ដូចតទៅ៖ "តើទឹកស្អាតអាចហូបបានទេ មានទឹកដាំពុះអី ហូបទេ?" គាត់ក៏បានឆ្លើយថា៖ "ទឹកគេដាំទឹកឲ្យ<ពលករ>ផឹក ខ្ញុំមិនដឹងថាតើទឹកហ្នឹងស្អាតមិនស្អាតទេ ក៏ប៉ុន្តែយើងដងទឹកហ្នឹងមកពីស្ទឹង ពីត្រពាំងអី គឺអត់មានទឹកម៉ាស៊ីនទេ។" សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់សួរលោកដូចតទៅ ក្នុងឋានៈលោកជាមេកង តើលោកមាន<ចាត់វិធានការ>ដាំទឹកដើម្បីឲ្យ<កូនក្រុមរបស់លោកផឹក>ទេ?

**ឆ៖** បាទ គឺដាំខ្លះ មិនដាំខ្លះអី។ វាពេលប្រញាប់ពេលអី ភ្លៀងផ្គរទៅក៏មិនបានដាំទៅ វាភ្លៀងពិបាកចង្ក្រានពិបាកអីទៅ ក៏ខានម៉្លេះអ៊ីចឹងទៅបាទ។ ដោះស្រាយគឺដោះស្រាយ ខំជួយដោះស្រាយជីវភាពប្រជាពលរដ្ឋនោះគឺខំដែរ។ បាទខំខ្លាំងណាស់ ដុតជើងដុតដៃហ្នឹងឯង។

**ស៖** លោកក៏បាននិយាយផងដែរអំពីបង្គន់អនាម័យនៅកន្លែងសម្រាក។ តើលោកអាចបញ្ជាក់បានទេថា តើអ្នកណាជាអ្នកផ្តួចផ្តើមគំនិតសាងសង់បង្គន់អនាម័យទាំងអស់នោះ?

**ឆ៖** បាទ គឺអ្នកសាងសង់បង្គន់អនាម័យនោះ គឺម្ចាស់ការតាមភូមិនីមួយៗ តាមភូមិមួយៗដោះស្រាយខ្លួនឯង។

[០៩:២០:០៧]

**ស៖** ចុះលោកផ្ទាល់ហ្នឹង លោកមានបានរៀបចំចាត់ចែងការសាងសង់រោងស្នាក់នៅទេ?

**ឆ៖** បាទ គឺរោងហ្នឹងរៀបចំមិនបានគ្រប់គ្រាន់ទេ។ វាភ្លៀងទទឹក ភ្លៀងផ្គរផង វាដូចថាស្លឹកត្នោតហ្នឹងវារហែកវាដាចអីចឹងទៅ ពេលភ្លៀងផ្គរទៅវាមានទទឹកខ្លះហើយ ភ្លៀង។ វាសាងសង់ និងគ្រប់គ្រងប្រជាពលរដ្ឋនោះមិនបានឋិតថេរ មិនបានគ្រាប់គ្រាន់ទេ បាទ។

**ស៖** សូមអរគុណ។ សូមឲ្យលោកឆ្លើយឲ្យត្រង់ៗទៅនឹងសំណួររបស់ខ្ញុំ។ ខ្ញុំចង់ដឹងថាលោកហ្នឹងហើយជាអ្នកចាត់ចែងឲ្យគេសាងសង់រោងស្នាក់នៅហ្នឹងមែនទេ? <>

**ឆ៖** បាទ គឺខ្ញុំហើយអ្នកចាត់ចែងរោង។ ខ្ញុំជាអ្នកគ្រប់គ្រង។ ភូមិខ្ញុំ ខ្ញុំគ្រប់គ្រងភូមិខ្ញុំ។ ដោះស្រាយភូមិខ្ញុំអី រោងហ្នឹង។

**ស៖** លោកបាននិយាយអំពីស្បៀងអាហារ ហើយលោកបញ្ជាក់ថាខាងភូមិជាអ្នកផ្តល់ស្បៀងអាហារមកដល់កម្មករនៅការដ្ឋាន។ អីចឹងមានន័យថា លោកជាអ្នកបញ្ជូនសំណើទៅឲ្យខាងភូមិគេដឹក<ដូចជាត្រូវការ>ស្បៀងអាហារ<ប៉ុន្មាន>យកមកឲ្យកម្មករនៅការដ្ឋានមែនទេ?

**ឆ៖** បាទ គឺខ្ញុំអ្នកចាត់ចែង ដែលខ្ញុំនៅការដ្ឋានហ្នឹង គឺឲ្យមនុស្សមកយកតាមភូមិមក បាទ ព្រោះខ្ញុំជាប់រវល់រែកដី ហើយជាប់នឹងបងប្អូនអីចឹងទៅ ឲ្យចាត់កម្លាំងមកយកតាមភូមិទៅ អង្ករស្ពៅអី។ ខ្ញុំជាអ្នកចាត់ចែង មើលការខុសត្រូវប្រជាពលរដ្ឋខ្ញុំនៅក្នុងភូមិបាទ។

**ស៖** ពាក់ព័ន្ធនឹងវិន័យ<តើលោក>ជាអ្នកទទួលខុសត្រូវ <និងអនុវត្ត>វិន័យ<ដល់ពលករ>ដែលធ្វើការនៅក្រោមបង្គាប់របស់លោក <និងទទួលខុសត្រូវត្រួតពិនិត្យមើលការងាររបស់កូនក្រុម>នោះ?

[០៩:២២:៥១]

**ឆ៖** បាទ គឺការគ្រប់គ្រងរបស់ខ្ញុំ ហើយការគ្រប់គ្រង អ្នកគ្រប់គ្រងពីលើខ្ញុំទៀតតាមថ្នាក់ៗមក។ ក៏ពេលការងារធ្វើនោះ ក៏ពេលម៉ោងពេលវេលា ពេលគេបង្ខំទៅក៏ ក្នុងពេលនោះគឺត្រូវខំខ្លាំងទៅ បាទ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ព្រោះគេថ្នាក់ពីលើមក គេបង្ខំមកយើងទៀត មិនមែនតែត្រឹមខ្ញុំឯណា។ គេពីលើមកបង្ខំអ៊ីចឹងទៀត ឲ្យខ្ញុំធ្វើដូច បងប្អូនក៏ធ្វើដូចខ្ញុំ ខ្ញុំក៏ដូចបងប្អូន ដូចគ្នាបាទ។

**ស៖** ប្រសិនបើលោកចាំ តើលោកអាចបញ្ជាក់ឈ្មោះមេផ្ទាល់របស់លោកនៅការដ្ឋាននុ៎ងបានទេ?

**ឆ៖** បាទ មេការដ្ឋានហ្នឹង គឺគេផ្លាស់ទៅអស់ហើយបាទ។ ជំនាន់នោះគេផ្លាស់ទៅទ័ព ទៅអីអស់ទៅព្រំដែនអីអស់ទៅ វាបាត់អស់ហើយបាទ ភ្លេចអស់ហើយ។

**ស៖** ខ្ញុំមិនយល់ច្បាស់ចម្លើយរបស់លោកទេ។ ពេលដែលលោកធ្វើការនៅ<ការដ្ឋាន>ទំនប់១មករាហ្នឹង គឺមេរបស់លោកហ្នឹងមាននៅទំនប់ហ្នឹងទេ ឬក៏លោក<យូរៗបាន>ឃើញពួកគាត់<ម្តង>?

**ឆ៖** បាទ មេមកពីផ្សេងៗទៀតបាទ។ ពីភូមិផ្សេងៗ មិនមេហ្នឹងមិននៅហ្នឹងទេដែលត្រួតពិនិត្យលើខ្ញុំមួយទៀតបាទ។ ហើយដល់ពេលនេះទៅ គេដកទៅទ័ពអីអស់ទៅ។ ទៅបាត់អស់ទៅបាទ។

**ស៖** ឥឡូវនេះខ្ញុំសូមចូលទៅចំណុចផ្សេងនៃសកម្មភាពរបស់លោក<>ជាឈ្លប។ នៅក្នុង<ចម្លើយរបស់លោកគឺ>ឯកសារលេខ D166/156 លោកបានបញ្ជាក់ថា ថ្លាង ជាប្រធានឃុំ <បើខ្ញុំមិនច្រឡំទេគាត់ក៏ជាប្រធានអង្គភាពសម្ងាត់ផងដែរ>។ អ៊ីចឹងតើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ? ខ្ញុំសូមបញ្ជាក់ថាចំណុចនេះគឺនៅ ERN ជាភាសាបារាំង <00402982>, ជាភាសាអង់គ្លេស 00330719, ជាភាសាខ្មែរគឺ 00321786។ <ខ្ញុំនឹងសួរសំណួរជាថ្មីម្តងទៀតដើម្បីឲ្យលោកងាយស្រួលយល់។ សំណួរខ្ញុំគឺ> តើឈ្មោះ ថ្លាង <ដែលមាននៅក្នុងចម្លើយរបស់លោកនោះ> ជាប្រធានកង<សម្ងាត់មែនដែរឬទេ>?

[០៩:២៦:៣៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនដឹងថា ដោយសារមានបញ្ហាបកប្រែ ឬក៏អីនោះទេ ប៉ុន្តែចំពោះភាសាអង់គ្លេស ចំពោះផ្នែកដែលបញ្ជាក់គឺថា ថ្លាង គឺជាប្រធាន <>ឃុំ មិនមែនជាមេឈ្លបឃុំទេ។ ដូច្នេះខ្ញុំមិនដឹងថា<ភាសាបារាំង>បកប្រែភាសាឯកសារ<ខុសគ្នា>ឬមួយក៏យ៉ាងម៉េច ព្រោះក្នុងឯកសារភាសាអង់គ្លេសមិនបាននិយាយថា ថ្លាង ជាមេឈ្លបឃុំនោះទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគិតថាមានបញ្ហាបកប្រែជាភាសាបារាំងហើយ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមដកស្រង់នៅក្នុងកំណត់ហេតុ៖ "ខ្ញុំធ្វើជាសមាជិក<កងសម្ងាត់ឃុំ>អស់រយៈពេល ២ខែក្នុងឆ្នាំ<>១៩៧៦។ នៅក្នុងកង<សម្ងាត់>របស់ខ្ញុំមានសមាជិក១២នាក់ ប្រធានកងនោះឈ្មោះ ថ្លាង។ ឥឡូវនេះគាត់ស្លាប់ហើយ។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងដើម្បីចៀសវាងការលំបាក គឺឲ្យសាក្សីគាត់បញ្ជាក់ត្រង់ចំណុចនេះឲ្យបានច្បាស់។ តើលោកសាក្សី តើលោកអាចលោកអាចបញ្ជាក់បានទេថា តើឈ្មោះ ថ្លាង នេះគាត់ជាប្រធានកង<សម្ងាត់>ផង ហើយជាប្រធានឃុំផង<ក្នុងពេលតែមួយ> ឬក៏យ៉ាងម៉េច ឬ<មិនមែនដូច្នោះ>ទេ?

[០៩:២៧:៥៩]

**លោក យាន លន់៖**

**ឆ៖** បាទ ប្រធានឈ្លបឃុំបាទ។ មិនមែនប្រធានឃុំទេ ប្រធានកងឈ្លបឃុំ។ ប្រធានឈ្លបឃុំបាទ។

**ស៖** ចុះអ្នកណាជាប្រធានឃុំ?

**ឆ៖** កាលណោះប្រធានឃុំនោះឈ្មោះ ឃី ទេបាទ។ ឈ្មោះ ឃី បាទ។

**ស៖** តើ ថ្លាង នេះហើយមែនទេ ជាអ្នកជ្រើសរើសយកលោកយកមកធ្វើជាឈ្លបនោះ?

**ឆ៖** បាទ ថ្លាង ហ្នឹងហើយបាទ។

**ស៖** ចុះមុនពេលគាត់រើសយកលោកមកធ្វើឈ្លបហ្នឹង លោកស្គាល់គាត់ទេពីមុនហ្នឹង? ហើយលោកធ្លាប់ធ្វើការជាមួយគាត់ទេ?

**ឆ៖** អត់បានធ្លាប់ស្គាល់យូរទេបាទ។ អត់ស្គាល់យូរទេបាទ ទើបស្គាល់តិចបាទ។

**ស៖** កាលពីម្សិលមិញ នៅពេលដែលឆ្លើយទៅនឹងសំណួររបស់<មេធាវី>ដើមបណ្តឹងរដ្ឋប្បវេណី គឺមុនម៉ោង០២:៣០នាទីបន្តិច <ជាក់លាក់>គឺចន្លោះពីម៉ោង<០២:២៨ ទៅដល់ម៉ោង០២:៣០> លោកបាននិយាយថា <ខ្ញុំសូមដកស្រង់>៖ "ខ្ញុំអត់មានភារកិច្ចសម្លាប់មនុស្សទេ គឺផ្ទុយទៅវិញខ្ញុំនៅទីនេះ គឺដើម្បីការពារ<>ភូមិ ការពារប្រជាជន។" <ចប់ការដកស្រង់។> អ្នកណាជា<អ្នក>ប្រាប់លោកថា ក្នុងឋានៈលោកជាឈ្លបហ្នឹង លោកត្រូវការពារភូមិ ការពារអ្នកប្រជាជននោះ?

[០៩:៣០:៣៣]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ប្រធានភូមិ -- ប្រធានសង្កាត់នេះចាត់តាំងឈ្លបតាមភូមិឲ្យយាមតាមរោងបាយបាទ ឈ្លបភូមិបាទ។

**ស៖** ដូច្នេះនៅពេលដែលលោកនិយាយថា <“ខ្ញុំគ្មាន>ភារកិច្ចសម្លាប់មនុស្សទេ ផ្ទុយទៅវិញ <ខ្ញុំ>មានភារកិច្ចការពារភូមិ ការពារប្រជាជន” <តើ>មេឃុំជាអ្នកប្រាប់លោកអ៊ីចឹងមែនទេថាភារកិច្ចរបស់លោកគឺធ្វើបែបនេះ?

**ឆ៖** បាទ អ៊ីចឹងមែនបាទ។

**ស៖** គឺមុនម៉ោង០២:៣០នាទីដដែលលោកបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ “គេឲ្យ<ឃ្លាំមើលសកម្មភាពអ្នកភូមិ>ទាំងអស់<មិនថាជា>អ្នកភូមិ<សាមញ្ញ> ឬក៏មេដឹកនាំអីក៏ដោយ គឺគេតែងតែឃ្លាំមើលទាំងអស់។” សូមបញ្ចប់ការដកស្រង់។ <តើ>លោកខ្លួនឯងផ្ទាល់ហ្នឹង <>ធ្លាប់ឃ្លាំមើល <សកម្មភាពប្រជាជន>ណាមួយទេ? <ប្រសិនបើធ្លាប់តើលោកឃ្លាំមើលសកម្មភាពរបស់នរណា?>

**ឆ៖** បាទ គឺក្នុងហ្នឹងគឺមានពិនិត្យពិច័យមើលការដឹកនាំ ពិសេសមែនទែនគឺពិនិត្យមើលក្នុងភូមិខ្លួនឯងនេះឯង ពិនិត្យមើលការពារនៅក្នុងភូមិរបស់ខ្លួននេះ បាទ។

**ស៖** ខ្ញុំសួរសំណួរខ្ញុំម្តងទៀត។ លោកឆ្លើយថា គេត្រូវតាមដានទាំងមេដឹកនាំផងដែរ។ អ៊ីចឹងខ្ញុំចង់សួរលោកថា លោកខ្លួនឯងផ្ទាល់នេះ លោកធ្លាប់តាមដាន ឬឃ្លាំមើលមេដឹកនាំណាមួយទេ? ហើយប្រសិនបើធ្លាប់នោះ សូមលោកបញ្ជាក់មើល៍មេដឹកនាំណាដែរ ដែលលោកតាមដាននោះ?

[០៩:៣៣:១៣]

**ឆ៖** បាទ គឺធ្លាប់ដែលពិនិត្យពិច័យមើល គឺមេដែលដឹកនាំ ដូចដឹកនាំនៅឈ្លបអី ហើយនិងមេដឹកនាំក្នុងឈ្លប មេដឹកនាំក្នុងឃុំអី ក្រែងលោថា ដូចថាពេលបើកអង្ករបើកអីឲ្យប្រជាពលរដ្ឋអ៊ីចឹងទៅ វាដូចថាកិបកេង មិនបើកឲ្យគ្រប់ចំនួនអី គឺតាមដានតែរឿងស៊ីទេបាទ។ រឿងតាមដានអី មិនតាមទេ អារឿងហូបចុកប្រជាជនមិនឆ្អែតទេ បាទ។ តាមដានអ្នកធំៗ ដែលដឹកនាំសង្កាត់អីហ្នឹងបាទ។

**ស៖** ខ្ញុំមានបញ្ហាបន្តិច ខ្ញុំមិនសូវយល់<ទេ>។ <ម្សិលមិញពេលដែលខ្ញុំ>ថា លោកជាឈ្លបឃុំមែនទេ <លោកកែតម្រូវខ្ញុំថាលោកមិនមែនឈ្លបឃុំទេ> លោក<ជា>ឈ្លប<នៅថ្នាក់>ភូមិ។ <>ចម្លើយ<នោះបាននាំឲ្យខ្ញុំគិតថាលោកមានភារៈតាមឃ្លាំមើលមេដឹកនាំទោះបីនៅឃុំដទៃក៏ដោយ>។ អ៊ីចឹងខ្ញុំចង់ដឹងថា តើ<លោកមាន>អំណាច<>ប៉ុនណាដែរ<? តើគេចាត់តាំងឲ្យ>លោក<>តាមដានទៅដល់អ្នកណា<? នៅឯណា? តើលោកមានសិទ្ធិ ឬភារកិច្ចធ្វើដូច្នោះដែរឬទេ>?

**ឆ៖** បាទ គឺអង្គាល់ណោះ ក៏វាអត់មានអំណាចអីទេគឺខ្ញុំនោះ។ ប៉ុន្តែគ្រាន់តែពិនិត្យពិច័យមើលក្នុងការបើកបរហ្នឹង ដូចថាបើកអង្ករ បើកម្ហូបម្ហាអីដែលគេបើទៅឲ្យតាមសង្កាត់ តាមអីហ្នឹង គឺជូនអីសង្កាត់កិបកេង វាយកទៅ ដូចថាឲ្យទៅបងប្អូនវាអ៊ីចឹងទៅ។ ដូច្នេះគឺអ្នកដទៃទៀត រោងបាយដទៃទៀតគឺមិនបើក បើកឲ្យក៏ដោយខ្វះខាត ខ្វះកន្លះ។ អានេះគឺអានេះខ្ញុំ គឺតាមដានតែប៉ុណ្ណឹងទេបាទ។ ខ្ញុំមានសិទ្ធិតាមដាន ព្រោះធ្វើមិនត្រូវ ខ្ញុំតាមដាន។ ខ្ញុំអាណិតប្រជាពលរដ្ឋណាស់។

[០៩:៣៥:៣០]

**ស៖** គឺលោកផ្ទាល់ លោកសម្រេចថាត្រូវតាមដាន<ប្រជាជន>ហ្នឹង<ដោយខ្លួនឯង> ឬក៏<មេឃុំជា>អ្នក<>បញ្ជាលោក<> ឲ្យត្រូវតាមដានបែបនេះ?

**ឆ៖** បាទ គឺអត់មានទេ គឺខ្ញុំអត់មានអ្នកណាគេបំពាក់បំប៉នខ្ញុំទេ។ ខ្ញុំតាមដានអ៊ីចឹងតែម្តង។ ខ្ញុំមើលទៅឃើញគេធ្វើការខុស ឃើញខុសអ៊ីចឹង គឺតាមពិនិត្យពិច័យ ព្រោះកន្លងមកវាច្រើនណាស់ទៅហើយ ប្រជាជនហូរទឹកភ្នែកដោយសារស៊ី។ ម៉្លោះហើយខ្ញុំបែកគំនិតតាមខ្លួនឯងទេ។ អត់មានពីណាចាត់តាំងខ្ញុំឲ្យតាមទេបាទ នេះនិយាយឲ្យអស់។

**ស៖** អ៊ីចឹងលោកតាមដាន<ប្រជាជន>ក្រៅ<ពី>ភូមិរបស់លោកទៀត មែនទេ?

**ឆ៖** អត់ទេ។ ខ្ញុំតាមដាននៅក្នុងភូមិខ្ញុំទេ ពេលដែលបើកសម្ភារៈរបស់ខ្ញុំ។ ភូមិខ្ញុំបាទ។

**ស៖** តាមរយៈការពន្យល់របស់លោកកាលពីម្សិលមិញ <ខ្ញុំយល់ថា> លោកប្រើតួនាទីរបស់លោកជាឈ្លបដើម្បីជួយទៅដល់អ្នកភូមិ។ លោកបាននិយាយថា លោកបាន<>លួច<អង្ករយកមក>ចែក<>ប្រជាជន។ <សំណួររបស់ខ្ញុំថា>តើលោកលួច<អង្ករ>ពី<កន្លែង>ណា<> ដើម្បីយកទៅចែក<>ប្រជាជនហ្នឹង?

**ឆ៖** បាទ គឺស្រូវរួមឃុំហ្នឹង ដែលដាក់នឹងភូមិខ្ញុំហ្នឹងឯង ដាក់នឹងភូមិខ្ញុំ។ ហើយដូច្នេះដាក់ហ្នឹងគេមិនសូវឲ្យប្រជាពលរដ្ឋហ្នឹងហូបបានឆ្អែតទេ គឺពេលនេះទៅ ដឹងគេយកស្រូវ និងអង្ករហ្នឹងទៅណាបាត់ទៅ។ ដល់នេះទៅ ជង្រុកមើលទៅទទេ។ ដល់នេះគឺខ្ញុំក៏មានចេតនាជាមួយបងប្អូន គឺសួរប្រជុំអ៊ំចាស់ៗ អ៊ំៗចាស់ថាយកទៅក្លួយ ធ្វើម៉េចយកបាន គាត់ជួយគាំទ្រអាយុជីវិតខ្ញុំ មិនឲ្យគេចាប់គេចងអីទេ អត់មានទោសទេ ហូបចុកប្រជាជននោះ បាទ។ អានេះ បាទ។

[០៩:៣៧:៥៨]

**ស៖** <>តើ<>សមាជិកឃុំ<>ហ្នឹងគេដឹងទេ នៅពេលដែលលោកធ្វើបែបនេះនោះ?

**ឆ៖** បាទ អត់ដឹងទេ។ បើដឹង មិនរស់ទេខ្ញុំនោះ។ អត់ដឹងទេ ឈ្លបក្នុងហ្នឹង ថ្លាង អីហ្នឹងគឺអត់ឲ្យដឹងទេឈ្លប។ តែឲ្យដឹងហ្នឹង រឿងទៀតហើយ ងាប់ៗភ្លាម។ នេះច្បាស់លាស់ហើយ បាទ។ រឿងលួចអីចឹងៗ ឈ្លបដឹងនោះ ចប់ហើយ កន្ត្រាក់កយកទៅភ្លាម បាទ។

**សៈ** អីចឹងមានន័យថា អត់មានអ្នកណាតាមដានលោកទេ? ព្រោះលោកថាមានឈ្លបហ្នឹងគឺ១២នាក់នៅក្នុងឃុំ។ អីចឹងមានន័យថា អត់មានឈ្លបណាមួយតាមដានលោកទេ មែនទេ? ពីព្រោះលោកបាននិយាយពីមុនថា គេតាមដានគ្នាទៅវិញទៅមក។ អីចឹងនៅពេលដែលលោកលួចអីចឹង អត់មានឈ្លបណាតាមដានលោកទេ?

**ឆ៖** បាទ អារបស់យកអីចឹង គឺរបស់រួមអីចឹង ឈ្លបគេតាមដានយើង ហើយបើយើងលួច គេថាយើងក្បត់។ ក៏យកស្រូវរួម អង្កររួម គឺគេថាយើងក្បត់។ អាពាក្យ “ក្បត់” ហ្នឹងវាងាប់ផុយ គឺស្លាប់លឿនហើយអាន៎ុង។ ពាក្យ “ក្បត់” ក្បត់គេហៅថា “ក្បត់រួម” របស់រួម។ ម្ល៉ោះហើយខ្ញុំអត់ឲ្យឈ្លបដឹងទេ ការលួចចិញ្ចឹមប្រជាពលរដ្ឋខ្ញុំក្នុងភូមិ អង្ករដាក់ក្នុងភូមិខ្ញុំឯង អង្ករស្រូវហ្នឹង ស្រូវហ្នឹងបាទ។ ហើយអត់ឲ្យឈ្លបដឹងទេ លួចតែយប់ៗ ចិញ្ចឹមប្រជាពលរដ្ឋខ្ញុំហ្នឹង។ អាណិតណាស់ យកបបរធ្វើការ អស់ហើយបបរ បីកំប៉ុងបួនកំប៉ុងហ្នឹង រាវកក្លូក។ ទាំងគាត់ ទាំងខ្ញុំហ្នឹងហូបចុកមិនដែលស្គាល់ជាតិបាយឲ្យបានចប់ចុងដើមទេ បាទ។

[០៩:៤០:១៦]

**សៈ** ក៏ប៉ុន្តែកាលពីម្សិលមិញលោកបានឆ្លើយថា លោកលួច<អង្ករ> ហើយអ្នកភូមិដឹងគុណលោក<បានដាំបាយហើយកាប់>មាន់<ធ្វើម្ហូបឲ្យលោកហូប>ទៀត។ អីចឹងតើ<ប្រជាជនបាន>មាន់ហ្នឹង<ពីណា? តើ>ពួកគាត់មាន<មាន់ជាកម្ម>សិទ្ធិ<ឯកជន>អីចឹង<ដែរ>?

**ឆ៖** បាទ គឺមាន់ហ្នឹងមាន់នៅនោះឯង មាន់នៅហ្នឹងភូមិនេះទេ មាន់នៅភូមិហ្នឹងឯងតើបាទ។ ព្រោះពីអង្កាល់ណោះ បើសិនជាថា ដូចតែខ្ញុំក្តាប់នៅហ្នឹង បើថាខ្ញុំមិនថាមិនឲ្យវៃស៊ី គឺក៏គាត់មិនហ៊ានដែរ។ ទាល់តែប្រធានយើងទាំងអស់គ្នាអី ហូបចុកទាំងអស់គ្នាទៅ ឯកភាពគ្នាបានហូបទៅកើត។ បើសិនជាខ្ញុំហូបតែម្នាក់ឯងក៏មិនកើត ម្ល៉ោះហើយទាល់តែហូបជាមួយប្រជាពលរដ្ឋទាំងអស់បានយើងថា ស្មើគេថាស្មើភាពគ្នានោះ។ បាទ ប្រជាជនហើយនិងអ្នកដឹកនាំឲ្យស្មើគ្នា អត់មានក្បត់គ្នាទៅវិញទៅមកទេបាយបបរដូចគ្នា បាយដូចគ្នាបាទ។ នេះជំនាន់ហ្នឹងបាទ ជ្រាបបាទ។

**សៈ** <តើខ្ញុំយល់ត្រូវទេថា>ក្នុងភូមិរបស់លោកហ្នឹង គឺលោក<ជាអ្នក>មានសិទ្ធិបែងចែក

ស្បៀងអាហារទៅឲ្យអ្នកភូមិមែនទេ?

**ឆ៖** បាទ គឺខ្ញុំចាត់ចែងតាំងពីសម្ភារៈ ហូបចុក បន្លែបង្ការអីហ្នឹង ខ្ញុំចាត់កម្លាំងមានខាងនេសាទ ខាងបន្លែដាំសម្រាប់ប្រជាពលរដ្ឋនៅនឹងភូមិខ្ញុំ ដោះស្រាយនឹងបាយ រោងបាយហ្នឹងឯងបាទ។

[០៩:៤២:២១]

**ស៖** ខ្ញុំបានស្ដាប់<យ៉ាងយកចិត្តទុកដាក់នូវ>ការរៀបរាប់រឿងរ៉ាវរបស់លោក<> លោកសាក្សី។> ដូចមេធាវី<ការពារក្ដីលោក> នួន ជា បានបញ្ជាក់កាលពីម្សិលមិញអ៊ីចឹង ថាអ្នកភូមិគាត់មិនយល់ឃើញអ៊ីចឹងទេ<។> ហេតុដូច្នេះហើយបានជាខ្ញុំចង់អាននូវ<>សក្ខីកម្មរបស់លោក អ៊ុត សេង កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ គឺឯកសារ E1/309.1 គឺនៅ<>ចន្លោះម៉ោង០៩:៣២ ដល់ម៉ោង០៩:៣៤។ ខាងមេធាវី នួន ជា គាត់បានដកស្រង់ចំណុចនេះហើយ ដែល អ៊ុត សេង គាត់បានរៀបរាប់រួចមកហើយ។ ហើយខ្ញុំនឹងដកស្រង់ម្ដងទៀត ដើម្បីឲ្យបញ្ជាក់អំពីទំនាក់ទំនងនៃអង្គហេតុផ្សេងៗ។ គាត់និយាយអំពីលោកផ្ទាល់តែម្ដង លោក អ៊ុត សេង គាត់ថា៖ “<គាត់>ជាមេឈ្លបឃុំកំពង់ថ្ម។ ដូចដែលខ្ញុំបញ្ជាក់ហើយ យើងឃើញមានដាវ មានកាំបិតប្រឡាក់<>ឈាម<។> នៅពេលគាត់ជិះកង់មកហ្នឹង ម្នាក់ៗខ្លាចគាត់គ្រប់គ្នា។” សូមបញ្ចប់ការដកស្រង់។ សំណួរទី១ របស់ខ្ញុំពាក់ព័ន្ធនឹងចំណុចនេះ ខ្ញុំចង់ដឹងថា តើលោក <ឬក៏ថ្លាង>ជា<ប្រធាន>ឈ្លបឃុំនោះ<>?

**ឆ៖** បាទ អង្គាល់នោះខ្ញុំគ្មានមេគ្មានអីទេ។ មានតែ ថ្លាង ទេគឺគាត់អ្នកធ្វើអ៊ីចឹងបាទ។ គឺខ្ញុំគឺអត់ធ្វើទេបាទ។

**ស៖** <>គ្រាន់តែជាសមាជិកឈ្លបឃុំធម្មតា<ម្នាក់ តើលោក>មានសិទ្ធិទៅចាត់ចែងស្បៀងអាហារក្នុងភូមិ<ដែរមែនទេ?>

**ឆ៖** បាទ គឺក្នុងនោះគឺបានតែខ្ញុំមាននាទីចាត់ចែងអ៊ីចឹង ខ្ញុំក្ដាប់នឹងភូមិហ្នឹងផង គឺខ្ញុំធ្វើឈ្លបក្នុងនៅភូមិហ្នឹងផង បាទវាពីរ។ ខ្ញុំក្ដាប់ក្នុងភូមិហ្នឹងឯង ព្រោះខ្ញុំជាប្រធានហើយមិនដោះស្រាយ ម៉េចនឹងកើតបាទ។ ម្ល៉ោះហើយធ្វើឈ្លបបន្តិចបន្តួចផងទៅ ដោះស្រាយស្បៀងអាហារប្រជាពលរដ្ឋផងទៅ។ បើខ្ញុំមិនដោះ បានអីប្រជាពលរដ្ឋបានរស់ បាទមិនរស់ទេបាទ។

[០៩:៤៥:១០]

**ស៖** តើលោកពិតជាបានជិះកង់ទៅមកក្នុងភូមិ ហើយមាន<>ដាវ មាន<>កាំបិត<>ប្រឡាក់ឈាម<>មែនទេ?

**ឆ៖** បាទ គឺអត់ទេបាទ។ បើកង់ជិះទេតើ ប៉ុន្តែខ្ញុំមិនបានស្ពាយកាំបិតអីទេបាទ។

**ស៖** តាមរយៈសក្ខីកម្មរបស់លោក ខ្ញុំយល់ថា លោកមិន<ធ្លាប់>សម្លាប់អ្នកណាម្នាក់ទេ។ តើ<>ត្រឹមត្រូវអ៊ីចឹងទេ?

**ឆ៖** បាទ ចម្លើយហ្នឹងគឺត្រឹមត្រូវ បាទ។

**ស៖** សាក្សី អ៊ុត សេង <បន្តបន្តិចទៀត>គាត់បានឆ្លើយពាក់ព័ន្ធនឹងលោកដដែលថា ខ្ញុំសូមដកស្រង់ "មានតែគាត់ទេនៅក្នុងសង្កាត់កំពង់ថ្មនុំង ដែលមានសិទ្ធិអំណាចខ្ពស់នោះ ហើយគាត់កាន់កាំបិតកាន់ដាវ អ៊ីចឹងវាបញ្ជាក់ថា គាត់នុំងហើយជាមនុស្សមានអំណាចខ្លាំងណាស់នៅក្នុងសង្កាត់ហ្នឹង។" លោកសាក្សី អ៊ីចឹងខ្ញុំចង់ដឹងថា តើលោកពិតជាមនុស្សខ្លាំង មនុស្សមានអំណាចអាចធ្វើអីក៏បានដែរនៅក្នុងភូមិរបស់លោក តើអ៊ីចឹងមែនទេ?

[០៩:៤៦:៥១]

**ឆ៖** បាទ អត់ដូច្នោះទេបាទ។ ខ្ញុំមិនខ្លាំងទេបាទ។ ខ្ញុំខ្លាំងតែអារឿងដោះស្រាយប្រជាពលរដ្ឋតែម្តង បើខ្លាំងធ្វើអ៊ីចឹង គឺខ្ញុំអត់ខ្លាំងទេ។ ខ្ញុំខ្លាចណាស់បាទ ព្រោះខ្ញុំខ្លាចហើយបានខ្ញុំរស់បានប៉ុណ្ណេះ បាទ។ ព្រោះខ្ញុំខ្លាចណាស់មុខអ៊ីចឹង មុខខុសខ្ញុំខ្លាចណាស់។ ម្ល៉ោះហើយខ្ញុំខ្លាំងតែត្រង់ដោះស្រាយប្រជាពលរដ្ឋទេ។ បើប្រជាពលរដ្ឋខ្ញុំខ្លាំងមែន ដោះស្រាយណាស់។ ខ្ញុំអាណិតអាសូរ បើពាក្យនេះ ដែលគេបណ្តឹងមកនេះ គឺខ្ញុំអត់ឯកភាពទេ បាទ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអនុញ្ញាតប្រគល់វេទិកានេះ ជូនសហភាគីរបស់ខ្ញុំលោកមេធាវី គង់ សំអុន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ និងភាគី។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំមានសំណួរតិចតួចទេ ដើម្បីសួរបញ្ជាក់បន្ថែម។ មុននេះអំមិញ ខ្ញុំបានឮលោកមានប្រសាសន៍ថា ឈ្មោះ ឃី ជាប្រធានសង្កាត់ត្រពាំងថ្ម។ តើអ៊ីចឹងត្រឹមត្រូវទេ?

[០៩:៤៨:០៧]

**លោក យាន លន់៖**

**ឆ៖** បាទ ប្រធានឃុំកំពង់ថ្មឈ្មោះ ឃី នៅនិរតីបាទ។ ឈ្មោះ ឃី នៅឃុំកំពង់ថ្ម។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារស្តាប់ចម្លើយរបស់លោកលេខ D166/156 ត្រង់ ERN ជាភាសាខ្មែរ 00321786, ភាសាបារាំង 00402982, ភាសាអង់គ្លេស 00330719។ លោកបានលើកពីឈ្មោះ ឃឹន ជាអនុប្រធានឃុំ។ លោកអាចបញ្ជាក់បានទេថាមានឈ្មោះ ឃឹន អ៊ីចឹងដែរឬមួយក៏ឈ្មោះ ឃី ឈ្មោះ ឃឹន ហ្នឹងជាឈ្មោះតែមួយ?

**ឆ៖** បាទ គឺឈ្មោះខុស មនុស្សដោយខ្លួនទេបាទ។ មនុស្សពីរនាក់ ឃឹន និង ឃី ហ្នឹង, ឃី ម្នាក់ ឃឹន ម្នាក់បាទ។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ហើយថា នៅក្នុងសមាជិកឃុំហ្នឹងបានស្លាប់អស់ហើយ។ ហើយលោកអាចបញ្ជាក់ពីសមាសភាពនៅក្នុងភូមិរបស់លោក ភូមិកងសៅរបស់លោកហ្នឹង តើមានអ្នកណានៅរស់ទេ?

**ឆ៖** បាទគឺក្នុងនោះ គឺដែលនៅធ្វើការជាមួយខ្ញុំនឹងភូមិហ្នឹងទាំងបីនាក់ហ្នឹង ក៏គាត់ស្លាប់អស់ហើយ នៅនឹងភូមិកងសៅហ្នឹង កាលដែលនៅប្រធានភូមិជាមួយខ្ញុំនោះ។ បាទ គាត់ស្លាប់អស់ហើយ។

[០៩:៥០:១០]

**ស៖** បាទ សូមអរគុណ។ លោកអាចរៀបរាប់ឈ្មោះបានទេអ្នកទាំងបីនាក់ហ្នឹង?

**ឆ៖** បាទ ឈ្មោះ គឿន, ឈ្មោះ ថាន់ ឈ្មោះន៉ែ -- ភ្លេចឈ្មោះហើយមួយទៀតនោះបាទ។

**ស៖** បាទ លោកអាចបញ្ជាក់ពីតួនាទីផង ថាឈ្មោះ គឿន ធ្វើអី? ឈ្មោះ ថាន់ ធ្វើអី?

**ឆ៖** ឈ្មោះ គឿន ហ្នឹងគាត់កាន់ខាងសេដ្ឋកិច្ចភូមិ។ ថាន់ ហ្នឹងអនុប្រធាន។ ខ្ញុំជាប្រធានទាំងអស់គ្នានេះបាទ។

**ស៖** បាទ សូមអរគុណ។ ចុះទាក់ទងនឹងសមាជិកក្រុមការងាររបស់លោក នៅពេលដែលលោកទៅធ្វើការ ដែលលោកថា លោកបានធ្វើការនៅទំនប់១មករា មានសមាជិក៥០នាក់ដែលទៅធ្វើការទីនោះ។ លោកមានចាំថា មានអ្នកណាម្នាក់នៅរស់ទេ ដល់បច្ចុប្បន្ននេះ?

**ឆ៖** បាទ សព្វថ្ងៃនៅរស់ទេ នៅរស់ច្រើនណាស់ ប៉ុន្តែខ្ញុំវាភ្លេចឈ្មោះហើយគេ ក្មេងៗចាស់ៗអស់រៀងគ្នា វាភ្លេចឈ្មោះ។ នៅចាំតែចាស់ៗខ្លះ ម្នាក់ពីរនាក់ ប៉ុន្តែមនុស្សនោះនៅទាំងអស់ទេ គេរអត់

មានទៅណាទេ អត់ទៅណាទេ។

**ស៖** ពួកប្រជាពលរដ្ឋដែលជាសមាជិកក្រុមក្នុងកងរបស់លោកហ្នឹង នៅក្នុងភូមិកងសៅរហូតដល់បច្ចុប្បន្ននេះទេ?

**ឆ៖** បាទ នៅទល់សព្វថ្ងៃ បច្ចុប្បន្នសព្វថ្ងៃនៅរស់ទាំងអស់បាទ។

[០៩:៥២:១៥]

**ស៖** បាទ ទាក់ទងនឹងទីតាំងដែលលោកថាលោកបានធ្វើការនៅទំនប់១មករា លោកបានបញ្ជាក់អំមិញ មាននៅភូមិកកោះ ភូមិផ្គុង ហើយនិងទឹកវិល។ ហើយមុនហ្នឹងបន្តិចលោកបានបញ្ជាក់អំពីទំនប់១មករា ហ្នឹងនៅរហូតដល់ខាងលិចភ្នំសន្ទុក។ ខ្ញុំចង់សួរលោកបញ្ជាក់ថា តើការងាររបស់លោកហ្នឹងនៅដែលលោកធ្វើហ្នឹងនៅចំទីតាំងទំនប់១មករា នៅលើខ្នងទំនប់តែម្តង ឬមួយក៏ការងារនៅតាមប្រឡាយដែលជាផ្នែកតូចៗនៃទំនប់ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ គឺផ្លាស់ប្តូរតាមភូមិ ត្រឡប់ផ្លាស់ ជួនអីគេដកពីនេះទៅ ទៅដាក់ខាង៦មករាអីចឹងទៅគេដកមកខាងណេះមក ផ្លាស់គ្នាចុះឡើងៗបាទ ផ្លាស់គ្នាចុះឡើងៗ។ ជួនអីខ្ញុំទៅខាង ផ្លាស់ទៅខាងកកោះអីចឹងទៅ ជួនអីខាងផ្គុងអីចឹងទៅ។ វាផ្លាស់ប្តូរគ្នា អត់ទៀងទេ។ កម្លាំងហ្នឹងអត់ទៀងទេ វិលធ្វើទំនប់នោះវិល កម្លាំង។ មិនមែនថាភូមិមួយដាក់តែតំបន់នេះហើយ នៅតែត្រង់ណេះ អត់ទេបាទ។ ផ្លាស់គ្នារហូត។

**ស៖** បាទ អីចេះសំណួររបស់ខ្ញុំ ខ្ញុំចង់ដឹងថា តើលោកធ្វើការនៅលើទំនប់១មករា ឬក៏នៅទីតាំងផ្សេងក្រៅពីទំនប់? ឧទាហរណ៍ដូចជាប្រឡាយដែលបន្តពីទំនប់១មករាជាដើម។

**ឆ៖** ធ្វើក្នុងតំបន់ទំនប់ហ្នឹងឯង ក្នុងប្រឡាយហ្នឹងឯង ក្នុងប្រឡាយទំនប់ហ្នឹងឯង អត់មានធ្វើក្រៅពីទំនប់ហ្នឹងទេ ក្នុងប្រឡាយទំនប់ហ្នឹងឯង តំបន់ទំនប់ហ្នឹង។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំចង់សួរបញ្ជាក់ពីការងារដែលលោកធ្វើ។ លោកចាប់ផ្តើមដំបូងលោកអាចបញ្ជាក់បានទេ ថាទីតាំងកន្លែងណាដែលលោកធ្វើ?

[០៩:៥៤:៥០]

**ឆ៖** បាទគឺធ្វើដំបូង ពីចាប់ពីដំបូងទៅគឺធ្វើចាប់ពី១មករាទៅបាទ ខ្ញុំដំបូងទៅដែរ។ ចាប់ពីហ្នឹងទៅ ធ្វើត្រង់មួយ -- ខាងជើង១មករា។

**ស៖** ខាងជើង១មករា មានន័យថាម៉េច? លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ គឺតាមទំនប់ឯង ទំនប់១មករា ប៉ុន្តែធ្វើខាងជើងស្ទឹងអ៊ីចឹងទៅ ហូរហែគ្នាតាមមាត់ប្រឡាយហ្នឹង ទៅជើងផ្លាស់ប្តូរៗគ្នាទៅបាទ។

**សៈ** លោកមានឈ្មោះភូមិ ឬក៏ទីតាំងស្អីមួយសម្រាប់សម្គាល់ទេ កន្លែងដែលលោកធ្វើការហ្នឹង?

**ឆ៖** តំបន់ភូមិខ្វែកបាទ ភូមិខ្វែក។

**សៈ** ភូមិខ្វែក?

**ឆ៖** បាទ ភូមិខ្វែក។

**សៈ** ប៉ុន្តែលោករៀបរាប់ខាងមុនអត់មានភូមិខ្វែកទេ។ លោកអាចបញ្ជាក់ថា ភូមិខ្វែកហ្នឹងវាមានទីតាំងនៅចំលើទំនប់១មករាហ្នឹងតែម្តង ឬក៏មានចម្ងាយឃ្លាតពីទំនប់១មករា?

**ឆ៖** បាទ គឺឃ្លាតប្រហែលជា១០០, ២០០ម៉ែត្រពីទំនប់ហ្នឹង តំបន់ភូមិខ្វែកហ្នឹង។

**សៈ** ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ សំណួរដែលខ្ញុំសួរគឺសំដៅទៅលើទីកន្លែង ឬក៏ទីតាំងជាក់លាក់ដែលលោកធ្វើការ ពីព្រោះខ្ញុំចង់ដឹងថា តើលោកធ្វើការនៅលើទំនប់១មករា ឬក៏នៅលើទីតាំងផ្សេងខុសពីទំនប់១មករា? អ៊ីចឹងកន្លែងដែលលោកធ្វើការហ្នឹង គឺចម្ងាយ២០០ម៉ែត្រពីទំនប់១មករា ឬមួយក៏មានន័យយ៉ាងម៉េច? លោកអាចបញ្ជាក់បានទេ?

[០៩:៥៧:០៣]

**ឆ៖** បាទ នៅជាប់នឹងទំនប់នេះ កន្លែងដែលជ្រក កន្លែងដែលនៅធ្វើហ្នឹង គឺនៅខាងក្រោមទំនប់នេះបាទ។ ខាងក្រោមប្រឡាយហ្នឹង ជាប់នៅនឹងឯង ជិតនិងជាប់នឹងទំនប់ ទីតាំងដែលនៅ។

**សៈ** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីការបែងចែងការងារទេ? ពីព្រោះលោកបាននិយាយថា លោកមានសមាជិកក្រុម៥០នាក់ ហើយលោកទទួលការងារយ៉ាងម៉េច ហើយបែងចែកយ៉ាងម៉េច? លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ គឺដល់ពេលនោះ គឺខ្ញុំបែងចែកទៅជាក្រុមៗ។ បាទ មួយក្រុម១០នាក់ មួយក្រុម១២នាក់អ៊ីចឹងទៅបាទ។ ចែកទៅជាក្រុម ប៉ុន្តែក្នុងក្រុមទាំងអស់ហ្នឹងឯង ខ្ញុំក្តាប់រាល់តែថ្ងៃតែអ៊ីចឹងឯង។

**សៈ** ទាក់ទងនឹងទំហំដីដែលលោកត្រូវធ្វើ ក្នុងកងរបស់លោកដែលមានគ្នាប្រហែល៥០នាក់ហ្នឹង គេឲ្យលោកធ្វើការក្នុងកម្រិតប៉ុនណា?

**ឆ៖** រួចពីហ្នឹងទៅ គេកម្រិតដាក់ក្នុងម្នាក់២គូបៗ បាទ។ ដាក់ អាហ្នឹងពីថ្នាក់លើមកដាក់ចុះឲ្យធ្វើអ៊ីចឹងហ្នងបាទ។

**ស៖** បាទ សំណួររបស់ខ្ញុំគឺទាក់ទងទៅនឹងកងទាំងមូល។ ខ្ញុំចង់ដឹងថា តើកងទាំងមូលហ្នឹង គេវាស់យ៉ាងម៉េច ដើម្បីឲ្យលោកបែងចែកបន្តទៅទៀត?

**ឆ៖** បាទ អាហ្នឹងក្នុងហ្នឹងគឺដូចឧទាហរណ៍ថា គេផែនការគេដាក់ចុះថា ក្នុងមួយថ្ងៃហ្នឹងគឺ ១០ ម៉ែត្របួនជ្រុង ក្នុង៥០នាក់ហ្នឹង។ ដល់នេះទៅចែកគ្នាតាមក្រុមហ្នឹង តិចៗម្នាក់ទៅចែកគ្នា បែងចែកក្នុងហ្នឹងឯង ការធ្វើនោះ កាប់ដីនោះបាទ។

[០៩:៥៩:១៤]

**ស៖** បាទ សូមអរគុណ។ លោកមានប្រសាសន៍អំមិញជាឧទាហរណ៍ ប៉ុន្តែខ្ញុំចង់ដឹងពីការវាស់វែងជាក់ស្តែងដែលថ្នាក់លើរបស់លោកបានចែកមកឲ្យលោក នូវទំហំការងារហ្នឹងណា។ លោកអាចកំណត់បានទេថា មានទំហំប៉ុនណា?

**ឆ៖** ការបែងចែកគឺតាមកម្លាំងតិច កម្លាំងច្រើន។ អ៊ីចឹងបែងចែក ឧទាហរណ៍ថា ១,៥គូបអ៊ីចឹងទៅ ជូនអី ២គូបអ៊ីចឹងទៅបាទ។ មនុស្សតាម ដូចថាក្រុមហ្នឹងមនុស្សមានឈឺមានអីអ៊ីចឹងទៅ វាដកកម្លាំងទៅ ថយអ៊ីចឹងទៅបាទ។ បែងចែកតាមកម្លាំង តាមដីហ្នឹង។

**ស៖** លោកយល់សំណួរខ្ញុំទេ ខ្ញុំសួរអំពីការវាស់សរុប តើគេវាស់ – ឧទាហរណ៍ថានៅទីតាំងមួយហ្នឹងមានបណ្តោយប៉ុន្មានទទឹង ប៉ុន្មានជម្រៅប៉ុន្មានដែលលោកត្រូវជីក ហើយឬក៏ខ្នងទំនប់ បើថាត្រូវដាក់នៅខ្នងទំនប់ហ្នឹង ត្រូវឲ្យមានខ្នងទំនប់ហ្នឹងក្បាលលើប៉ុន្មាន ជើងក្រោមប៉ុន្មានជាដើម។ តើលោកមានទទួលការងារបែបហ្នឹងទេ?

**ឆ៖** បាទ គឺមានទទួលបាទ។ ដល់នេះគេឲ្យបែងចែកក្នុង ឧទាហរណ៍ថាមួយមុខខ្ញុំហ្នឹង ធ្វើហ្នឹងគេវាស់ដីឲ្យ ឧទាហរណ៍ថា១០ម៉ែត្រអ៊ីចឹងទៅ មួយប្រឡោះហ្នឹងឯង គឺលើដាក់លើទំនប់ហ្នឹង ដាក់ទៅ។ ឧទាហរណ៍ថាខ្នងទំនប់ហ្នឹងទទឹងចំនួន២០ម៉ែត្រអ៊ីចឹងទៅ រែកដីចាក់លើហ្នឹងអ៊ីចឹងទៅ យើងប្រធានហ្នឹងឯង គឺគិតគូរឈូសកាយវាសក្នុងហ្នឹងឯងទៅ មួយកន្លែងយើងដែលវាស់១០ម៉ែត្រអ៊ីចឹងដាក់លើទំនប់ហ្នឹងទំហំ។ ហើយប្រឡាយហ្នឹងគឺជម្រៅ ដូចថា៥ម៉ែត្រអ៊ីចឹងទៅ យើងល្ងាចឡើងគេឲ្យវាស់អ៊ីចឹងហើយបាទ។

[១០:០១:០៧]

**ស៖** ខ្ញុំៗយល់ពីលក្ខណៈឧទាហរណ៍របស់លោក ប៉ុន្តែខ្ញុំចង់បានទិន្នន័យតួលេខជាក់ស្តែង ថាតើប្រឡាយដែលលោកជីកនោះមានជម្រៅប៉ុន្មាន ប្រវែងប៉ុន្មាន មានក្បាលខាងលើប៉ុន្មាន ហើយទំនប់ហ្នឹង

មានរង្វាស់ប៉ុន្មានជាក់ស្តែង? ពីព្រោះលោកជាមេកង អ៊ីចឹងខ្ញុំយល់ថា លោកអាចដឹងពីកិច្ចការទាំងអស់នេះ បើសិនជាលោកបានអនុវត្តជាក់ស្តែងនៅពេលនោះមែន។ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ គឺខ្នងទំនប់ខាងលិចគឺមាន៣០ -- ៤០ម៉ែត្របាទ ខ្នងទំនប់ៗខាងលិចដែលប្រើប្រាស់បើកឡានបើកអីលើហ្នឹងបាន។ ៤០ម៉ែត្រ ហើយនិងជម្រៅ -- ទទឹងប្រឡាយហ្នឹងចំនួនប្រហែលជា៥០ម៉ែត្របាទ មាត់ប្រឡាយធំហ្នឹងទទឹង៥០ម៉ែត្រ។ ហើយជម្រៅមិនដឹងប៉ុន្មានទេ ខ្ញុំមិនបានក្រឹត្យក្រមនឹងជម្រៅទេបាទ ប៉ុន្តែបើទំហំធំមាត់ប្រឡាយហ្នឹង គឺ៥០ម៉ែត្រហើយបាទ។

**ស៖** បាទ ហើយខ្ញុំ -- សំណួររបស់ខ្ញុំៗចង់សំដៅទៅលើទីតាំងកន្លែងដែលលោកធ្វើការជាក់លាក់ ខ្ញុំមិនសំដៅទៅលើទំនប់ ប្រឡាយដែលមានស្រាប់ដែលធ្វើហើយនេះទេ។ ខ្ញុំចង់ដឹងថា កន្លែងដែលលោកធ្វើការហ្នឹង គឺមានទទឹងប៉ុន្មាន ជម្រៅប៉ុន្មាន ហើយទំនប់ដែលលោកត្រូវជីកហ្នឹងមានខ្នងទំនប់ប៉ុន្មានកម្ពស់ប៉ុន្មាន ជើងក្រោមប៉ុន្មានជាដើម? ជាការវាស់វែង ដោយសារលោកជាមេកង អ៊ីចឹងលោកត្រូវវាស់វែងចែកបន្តទៅកូនកង កូនក្រុមរបស់លោកទៀត។ លោកចាំបានទេ ពីទំហំជាក់ស្តែងដែលលោកបានធ្វើការក្នុងរយៈពេលដែលលោកថា៣ខែហ្នឹង?

[១០:០៣:១៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំគិតថាសំណួរ<ច្រំ>ដែល<> ព្រោះគេសួរសាក្សីច្រើនដង ហើយសាក្សីគាត់ព្យាយាមឆ្លើយតាមដែលគាត់អាចធ្វើបានរួចទៅហើយ។ ដូច្នេះខ្ញុំគិតថា មេធាវីមិនគួរមកបង្រៀនណែនាំដល់សាក្សីអំពីអ្វីដែលគាត់ចាំ អ្វីដែលគាត់មិនចាំនោះឡើយ។ ដូច្នេះខ្ញុំបញ្ជាក់ម្តងទៀតថា សាក្សីហ្នឹង គាត់ឆ្លើយសំណួរហ្នឹងច្រើនដងរួចមកហើយ ហើយសំណួរហ្នឹងជាសំណួរដដែលៗ<។> ហើយខ្ញុំមិនដឹងថាមានគោលបំណងអ្វីដែលមេធាវីសួរសំណួរដដែលៗបែបនេះ។

**លោក គង់ សំអុន៖**

ខ្ញុំសូមឆ្លើយថា ខ្ញុំបានសួរសំណួរនេះ ដោយមិនទាន់បានចម្លើយ។ ដោយសារតែគ្មានចម្លើយនេះហើយ បានខ្ញុំសួរបញ្ជាក់គាត់ដដែលៗ ដើម្បីឲ្យគាត់ឆ្លើយនឹងសំណួររបស់ខ្ញុំ។ អ៊ីចឹងខ្ញុំសូមអនុញ្ញាត

លោកប្រធាន ឲ្យគាត់ឆ្លើយ។

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទេ។ មេធាវីមានសំណួរផ្សេងសួរទៅមុខទៀតចុះ ព្រោះសាក្សីយល់ -- ការយល់ដឹងរបស់គាត់ ឆ្លើយតបនឹងសំណួរនោះរបស់លោកបានត្រឹមតែប៉ុណ្ណឹងទេ។

[១០:០៤:៣១]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ទាក់ទងទៅនឹងទំហំការងារ លោកបានបញ្ជាក់អម្បាញ់មិញថា ជួនកាលមានការបែងចែកឲ្យម្នាក់២ម៉ែត្រ ហើយជួនកាលមាន១,៥ម៉ែត្រ។ ហើយនៅក្នុងសក្ខីរបស់លោកពីម្សិលមិញ លោកថាមានចែកឲ្យរហូតដល់ទៅ៤ម៉ែត្រគូបក្នុងម្នាក់។ អ៊ីចឹងលោកអាចបញ្ជាក់បានទេថា ចំនួនណាពិតប្រាកដដែលគេបែងចែកឲ្យសមាជិកម្នាក់ៗធ្វើការ?

**លោក យាន លន់៖**

**ឆ៖** បាទ គឺក្នុងហ្នឹងគឺទំហំដែលខ្ញុំនិយាយម្សិលហ្នឹង ដែលម្នាក់៤ម៉ែត្រគូបហ្នឹង អាហ្នឹងដូចថាខ្ញុំមិនបាននិយាយអស់ពីម្សិលមិញ។ គឺអាហ្នឹងដូចថាអ្នកជាប់ពិរុទ្ធ ជាប់ដូចថាមានពិន័យអី អាហ្នឹងគេដាក់អ៊ីចឹងបាទ។ ខ្ញុំម្សិលមិញខ្ញុំគិតមិនឃើញបាទ។ អ្នកដែលវាស់ដីឲ្យហ្នឹងអ៊ីចឹង ជាប់ពិន័យអី គេដាក់ច្រើនណាស់ទម្ងន់ ឲ្យរែកដីហ្នឹង៤គូបអីហ្នឹងបាទ អស់មិនអស់ រួចមិនរួចហ្នឹងបាទ។

**ស៖** បាទ សូមអរគុណ។ អ្នកណាជាអ្នកដាក់ពិន័យហ្នឹង?

**ឆ៖** បាទ គឺក្នុងនោះគឺខ្ញុំមិនបានដាក់ទេ ប៉ុនពីឃុំគេមកបាទ គេដាក់ពីឃុំមកបាទ បញ្ញត្តិពីឃុំទៅបាទ។

[១០:០៦:២៨]

**ស៖** ហើយប៉ុន្មាននាក់ដែរ ដែលត្រូវដាក់ពិន័យក្នុងមួយថ្ងៃៗ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ក្នុងមួយថ្ងៃៗ ជួនអីបើវាគ្មានមនុស្សធ្វើ បងប្អូនធ្វើខុសទៅ ក៏វាគ្មានជាប់វិន័យអីដែរ។ ហើយម្យ៉ាងទៀត បើធ្វើខុសទៅក៏ជាប់ច្រើនអ៊ីចឹងទៅ ដូចថាគ្នាហេរហត់ទៅ ទៅធ្វើមិនកើតទៅ យកគ្នាទៅដាក់ទោស ដាក់ពិន័យអ៊ីចឹងទៅបាទ។ អាហ្នឹងដោយមិនថាជាប់រាល់ថ្ងៃទេបាទ។ វាមានពេលមាន

វេលារបស់វា។

**ស៖** បាទ សូមអរគុណ។ ក្នុងក្រុមសមាជិកក្រុមរបស់លោក៥០នាក់ ក្នុងរយៈពេល៣ខែ ដែលលោកធ្វើការនៅទំនប់១មករាហ្នឹង មានអ្នកត្រូវទទួលពិន័យហ្នឹងប៉ុន្មាននាក់ដែរ? លោកចាំបានទេ?

**ឆ៖** បាទ គឺក្នុងភូមិខ្ញុំគឺអត់មានទេបាទ ពិន័យជាប់ពិន័យទោសអ៊ីចឹងៗ ធ្វើពុតធ្វើក្ដីអីអត់មានទេ ព្រោះមិនធ្វើពុតទេ ក៏ខ្ញុំក៏អត់ពុត គេក៏អត់ពុតទាំងតែអស់គ្នា ធ្វើទាំងអស់គ្នា ម្ល៉ោះហើយហាត់ហេវ ឈប់បាទ ក្នុងភូមិខ្ញុំ។

**ស៖** បាទ សូមអរគុណ។ ចុះម៉េចបានសំណួរទី១ ដែលគេសួរអំពីទំហំចំនួនការងារបែងចែកដល់សមាជិកក្រុម លោកឆ្លើយ៤គូបក្នុងមួយនាក់ពីម្សិលមិញ។ ពីព្រោះក្នុងក្រុមរបស់លោកថា អត់មានអ្នកណាត្រូវទទួលពិន័យ ដែលត្រូវឲ្យធ្វើការ៤គូបក្នុងមួយថ្ងៃនោះទេ។ លោកអាចបញ្ជាក់បានទេ វាមានការភ័ន្តច្រឡំ ឬការយល់ច្រឡំយ៉ាងដូចម្ដេចដែរ?

[១០:០៨:៣១]

**ឆ៖** បាទ គឺសូមទោស គឺម្សិលមិញគឺខ្ញុំយល់ច្រឡំហើយបាទ ខ្ញុំច្រឡំ វាភ្លេចភ្លាំងហើយបាទ។

**ស៖** ទាក់ទងទៅនឹងទំហំការងារដែលលោក ក្នុងក្រុមរបស់លោកបានធ្វើ ថាតើការងារដែលលោកត្រូវធ្វើហ្នឹង នៅក្នុងកន្លែងមួយលោកអាចបញ្ជាក់បានទេ សមិទ្ធិផលចុងក្រោយ នៅពេលដែលលោកធ្វើហើយ មុននឹងលោកផ្លាស់ទៅកន្លែងមួយទៀតហ្នឹង លោកមើលឃើញពីទំហំលទ្ធផលនៃការងារដែលលោកបានធ្វើឃើញហ្នឹងប៉ុនណាដែរ ជាផ្ទៃដី ឬក៏ជាប្រឡាយ ឬជាទំនប់ហ្នឹង?

**ឆ៖** បាទ គឺទំហំដែលដីដូចខ្ញុំថាហើយ កាប់ក្នុង -- ឧទាហរណ៍ថាប្រឡាយហ្នឹងទទឹង៥០ម៉ែត្រ ហើយជម្រៅវាឧទាហរណ៍ថា១០ម៉ែត្រអ៊ីចឹងទៅ ដល់នេះគិតបែងចែកជាគូបនៅក្នុង១០ម៉ែត្រ។ ក្នុង១០ម៉ែត្រហ្នឹងគឺបែងជាគូបក្នុងហ្នឹងឯង។ រែកក្នុងជម្រៅប្រឡាយហ្នឹង១០ម៉ែត្រហ្នឹង រែកឡើងមកបាទ មកដាក់លើខ្នងទំនប់ អា៤០ម៉ែត្រហ្នឹងបាទ រែកឡើងបាទ។

**ស៖** បាទ សំណួររបស់ខ្ញុំ ខ្ញុំចង់ដឹងថាលទ្ធផលចុងក្រោយលោកធ្វើបានប៉ុនណា ក្នុងកងរបស់លោក មុននឹងពេលដែលលោកផ្លាស់ទៅកន្លែងថ្មីមួយទៀត? ចាប់ពីចំណុចទី១ ដែលលោកបានធ្វើហ្នឹង លោកបានសម្រេចប៉ុន្មានម៉ែត្រក្នុងក្រុមរបស់លោក?

[១០:១០:២១]

**ឆ៖** បាទ គឺធ្វើដំបូងគឺក្នុងអស់រយៈកាល១០ថ្ងៃហ្នឹងបានវាទទឹងទំនប់ ហើយនិជម្រៅហ្នឹង វា

បានតែ១៥ម៉ែត្រទេបាទ ទទឹងលទ្ធផលដែលបានធ្វើនោះ ដែលធ្វើបាន។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការងាររបស់លោក ដែលលោកថាលោកធ្វើជាមេភូមិ ហើយក៏ធ្វើជាឈ្លបផងដែរ។ ហើយលោកបញ្ជាក់ថា លោកធ្វើឈ្លបនេះ គឺឈ្លបនៅក្នុងភូមិរបស់លោក។ ខ្ញុំចង់សួរថា តើលោកមានទំនាក់ទំនងជាមួយនឹងថ្នាក់ឃុំ ឬសង្កាត់ដែរទេ ក្នុងការងារសន្តិសុខផ្សេងៗ?

**ឆ៖** បាទ គឺឃុំគេចាត់ចាត់ចែងឲ្យធ្វើហ្នឹងបាទ ធ្វើការពារភូមិ គ្រប់តែភូមិហើយបាទ។ ប៉ុន្តែ មិនមែនខ្ញុំទៅការពារគ្រប់ភូមិទេ គឺគេចាត់តាំងភូមិណា គេការពារភូមិហ្នឹង។ ខ្ញុំការពារតែភូមិខ្ញុំបាទ ឈ្លបហ្នឹង គឺប្រធានឃុំគេចាត់តាំងបាទ។

**ស៖** បាទ មុននឹងពេលមេធាវី អង់តា សួរលោកអំពីតួនាទីរបស់លោកនៅក្នុងភូមិ លោកបាន ឆ្លើយថា ក្នុងការងារឈ្លបរបស់លោកហ្នឹង គឺលោកមានតាមដានដល់ទៅសមាជិកឃុំ-សង្កាត់ផងដែរ។ ខ្ញុំចង់ដឹងថា តើលោកធ្លាប់បានតាមដានករណីណាជាក់លាក់ដែរទេ?

**ឆ៖** បាទ គឺការងារនោះ គឺខ្ញុំមិនបានតាមដានជាក់លាក់ទេ មិនពិតប្រាកដទេបាទ។ មិនបាន តាមដានអ្នកណាមួយឲ្យបានពិតប្រាកដទេបាទ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១០:១៣:១០]

**ប្រធានអង្គជំនុំ៖**

បាទ ដំណើរការស្តាប់សក្ខីកម្មសាក្សី យាន លន់ បានដល់ទីបញ្ចប់ហើយ។ ហើយសវនាការជា បន្តនៅព្រឹកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្ស-នាម 2-TCCP-261។ ហើយក្នុងពេលធ្វើសវនាការ នឹងមានបុគ្គលិកអង្គការ ធី.ភី.អូ លោកស្រី ឆាយ ម៉ារីដែត អង្គុយអមដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ សូមភាគីជ្រាប។

អង្គជំនុំជម្រះសូមអរគុណលោក យាន លន់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់ សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាសាក្សីក្នុងរយៈពេលមួយថ្ងៃកន្លងមកនេះ ហើយសក្ខីកម្ម របស់លោកនឹងរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយការផ្តល់សក្ខីកម្មរបស់លោក បានដល់ទីបញ្ចប់ហើយ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ សូម

លោកជួបតែសំណាងល្អ មានសេចក្ដីសុខសេចក្ដីចម្រើន និងធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក យាន លន់ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ អរគុណលោក មឿន សុវណ្ណ មេធាវីប្រឹក្សាសាក្សី។ លោកមេធាវីអាចសម្រាកបានហើយ។

នាពេលនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:១៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-261 រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអី?

**លោកស្រី គង់ សៀក៖**

**ឆ៖** ខ្ញុំឈ្មោះ គង់ សៀក។

**ស៖** អរគុណលោកស្រី គង់ សៀក។ តើលោកស្រីកកើតនៅថ្ងៃខែឆ្នាំណា? លោកស្រីចាំដែរទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំកើតនៅឆ្នាំ១៩៥២។

[១០:៣៦:២៦]

**ស៖** អរគុណ។ ហើយទីកន្លែងរបស់លោកស្រីកើតនៅទីកន្លែងណា?

**ឆ៖** ខ្ញុំកើតនៅភូមិប្រាសាទ សង្កាត់ត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។

**ស៖** អរគុណ។ ចុះទីលំនៅសព្វថ្ងៃនេះ លោកស្រីរស់នៅទីកន្លែងណា?

**ឆ៖** ទីកន្លែងសព្វថ្ងៃ ខ្ញុំរស់នៅភូមិប្រាសាទដដែល។

**ស៖** តើលោកស្រីប្រកបមុខរបរអ្វីសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំប្រកបមុខរបររកស៊ីធ្វើស្រែចម្ការដដែល។

**ស៖** បាទ អរគុណ។ ហើយចុះឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកស្រីគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ គង់។ ម្ដាយបង្កើតរបស់ខ្ញុំឈ្មោះ សៀង។

**ស៖** អរគុណ។ ចុះប្ដីរបស់លោកស្រីឈ្មោះអី? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ប្ដីខ្ញុំឈ្មោះ ឡុង ពិន ហើយកូនខ្ញុំមានបីនាក់។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី គង់ សៀក។ ក្នុងឋានៈលោកស្រីជាដើមបណ្ដឹងរដ្ឋប្បវេណី ជាចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោកស្រី លោកស្រីមានសិទ្ធិថ្លែងរៀបរាប់ពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកស្រី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ សូមលោកស្រីជ្រាប។

[១០:៣៨:២៥]

ហើយដោយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី គង់ សៀក មុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ថា មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី រួមទាំងសហព្រះរាជអាជ្ញាមានពេលវេលាមួយវគ្គនៃថ្ងៃសវនាការ ក្នុងការសួរដេញដោលសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ មុននឹងផ្តល់វេទិកាទៅលោកស្រីមេធាវី ទី ស្រ៊ីនណា។ ខ្ញុំសូមធ្វើសេចក្តីសំណើមួយ ពីព្រោះថាមួយវគ្គនេះ<មានរយៈពេលខ្លីជាងវគ្គដែលផ្តល់ឲ្យភាគីការពារក្តីនៅពេលរសៀលដល់ទៅ>១០នាទី<ឯណោះ>។ អ៊ីចឹងខ្ញុំសូមអនុញ្ញាតពីលោកប្រធាន សុំឲ្យបាន១០នាទីបន្ថែម <ដើម្បីឲ្យសហភាតារបស់ខ្ញុំ> និងសហព្រះរាជអាជ្ញា<អាចសួរដេញដោយចប់សព្វគ្រប់>ផង<> លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

សូមអញ្ជើញបាទ!

[១០:៣៩:៤១]

**លោកស្រី ទី ស្រ៊ីនណា៖**

ជាបឋម នាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល និងសូមគោរពលោកស្រី គង់ សៀក។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** ខ្ញុំឈ្មោះ ទី ស្រ៊ីនណា ជាមេធាវីដែលនឹងតាំងសំណួរសួរលោកស្រីនាពេលបន្តិចទៀតនេះ។ លោកស្រីមានអារម្មណ៍ម៉េចដែរ អត់អី អាចឆ្លើយនឹងសំណួរបានតើ?

**លោកស្រី គង់ សៀក៖**

**ឆ៖** អត់អីទេ។

**ស៖** អ៊ីចឹងខ្ញុំសូមធ្វើការតាំងសំណួររបស់ខ្ញុំ។ ខ្ញុំសូមសួរលោកស្រីថាតើនៅពេលដែលលោកស្រីចូលធ្វើជាយោធារបស់ខ្មែរក្រហមហ្នឹងនៅពេលណាដែរលោកស្រី? លោកស្រីចាំបានឬទេ?

**ឆ៖** ចាស ខ្ញុំនៅ -- ចូលនៅធ្វើយោធានៅឆ្នាំ៧៥។

**ស៖** សូមអរគុណ។ ពេលដែលលោកស្រីចូលធ្វើហ្នឹង លោកស្រីបានរៀបអាពាហ៍ពិពាហ៍ហើយ ឬនៅ?

**ឆ៖** ខ្ញុំអត់ទាន់បានទេ នៅលីវ នៅក្រមុំទេ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:៤១:០២]

**ស៖** សូមអរគុណ។ ពេលដែលលោកស្រីចូលធ្វើការជាយោធាហ្នឹង លោកស្រីនៅក្នុងកងពលណាដែលលោកស្រី?

**ឆ៖** ចាស ខ្ញុំនៅកងពល៤៥០។

**ស៖** តើពេលនោះ គេឱ្យលោកស្រីធ្វើការនៅកន្លែងណាដែរ?

**ឆ៖** ចាស មុនដំបូង ខ្ញុំមកដល់គេឱ្យខ្ញុំនៅមន្ទីរពេទ្យឫស្សីកែវ។

**ស៖** អរគុណ។ តើពេលនោះ គេឱ្យលោកស្រីធ្វើអីដែរនៅមន្ទីរឫស្សីកែវនោះ?

**ឆ៖** នៅមន្ទីរឫស្សីកែវហ្នឹង គេឱ្យខ្ញុំធ្វើជាបុគ្គលិកដាំបាយម្តង ទៅចាក់ថ្នាំឱ្យយុទ្ធជនម្តង ផ្លាស់គ្នា។

**ស៖** តើលោកស្រីធ្វើការនៅទីនោះរហូតដល់បែករបបប៉ុល ពត ឬមួយក៏មានការផ្លាស់ប្តូរផ្សេងពីហ្នឹងទៀត ឬក៏យ៉ាងម៉េចដែរលោកស្រីការងារពេលនុ៎ង?

**ឆ៖** ការងារនៅពេលនៅមន្ទីរពេទ្យហ្នឹងឯង អត់មាន -- ដល់ពេលខ្ញុំធ្វើហ្នឹងឯង ដល់យូរទៅបានផ្លាស់ប្តូរ។ ផ្លាស់ប្តូរមកធ្វើស្រែវិញ។

**ស៖** ពេលដែលគេផ្លាស់ប្តូរហ្នឹង គេផ្លាស់ប្តូរលោកស្រីទៅកន្លែងណាដែរលោកស្រី?

**ឆ៖** ពេលដែលគេផ្លាស់ប្តូរហ្នឹង គឺគេផ្លាស់ប្តូរមកកន្លែងបឹងបាយ៉ាប ទួលគោក មកធ្វើស្រែ។

[១០:៤៣:០៦]

**ស៖** សូមអរគុណ។ តើលោកស្រីនៅធ្វើស្រែនៅទីនោះរហូត ឬក៏មានការប្តូរផ្លាស់ទៅកន្លែងណាផ្សេងទៀតដែរ ឬក៏យ៉ាងម៉េចដែរលោកស្រី?

**ឆ៖** ចាស ខ្ញុំដល់ធ្វើស្រែនៅកន្លែងហ្នឹងរួចហើយ បានគេផ្លាស់ប្តូរខ្ញុំពីកន្លែងហ្នឹងឯងមកបានមកនៅអូរបែកក្អមវិញ។

**ស៖** សូមអរគុណ។ ខ្ញុំសូមឱ្យលោកស្រីជួយរៀបរាប់អំពីស្ថានភាពរបស់លោកស្រីហ្នឹងនៅពេលដែលលោកស្រីនៅអូរបែកក្អមហ្នឹង តើគេឱ្យលោកស្រីធ្វើអីគេខ្លះ? ហើយលោកស្រីជួបនូវហេតុការណ៍អីគេខ្លះ នៅពេលដែលលោកស្រីធ្វើការនៅអូរបែកក្អមនោះ?

**ឆ៖** ចាស ខ្ញុំដែលគេផ្លាស់មកពីយោធាកងពលមក មកនៅក្នុងអូរបែកក្អមនោះចូលមកនៅអង្គភាព៧៥ តែគេឱ្យខ្ញុំធ្វើស្រែ ហើយគេឱ្យខ្ញុំចាំកណ្តុរតាមភ្លឺស្រែ។ ហើយខ្ញុំពិបាកណាស់នៅពេលនោះ គឺ

ខ្ញុំពិបាកខ្លាំងណាស់។ នៅហ្នឹងគេចម្រាញ់ខ្ញុំៗ ហើយគេឲ្យខ្ញុំហូបបាយឈរ ក៏គេឲ្យហូបមិនឆ្អែតដែរ ហើយគេឲ្យឈរទៀតចាស។

[១០:៤៥:២៩]

**ស៖** ចុះពេលណាដែលគេៗមានបញ្ជូនលោកស្រីចេញពីអូរបែកក្អមទៅណាផ្សេងទៀត ដែរឬទេ? ហើយបើសិនគេបញ្ជូនហ្នឹង គេបញ្ជូនលោកស្រីទៅណា នៅក្នុងអំឡុងពេលណា លោកស្រីចាំបានដែរឬទេ? សូមលោកស្រីជួយជម្រាបជូនអង្គជំនុំជម្រះអំពីដំណើរការនៃការបញ្ជូនលោកស្រីហ្នឹង យ៉ាងដូចម្ដេចដែរ?

**ឆ៖** ចាស ខ្ញុំគេបញ្ជូនខ្ញុំទៅកំពង់ឆ្នាំងហ្នឹងឯងក៏ ទៅឲ្យធ្វើការនៅព្រលានយន្តហោះ។

**ស៖** សូមអរគុណ។ លោកស្រីចាំបានទេ គេឲ្យលោកស្រីទៅព្រលានយន្តហោះហ្នឹងក្នុងឆ្នាំណាដែរ?

**ឆ៖** នៅក្នុងឆ្នាំ៧៧។

**ស៖** សូមអរគុណ។ ពេលដែលគេឲ្យលោកស្រីទៅក្នុងឆ្នាំ៧៧ហ្នឹង ពេលហ្នឹងលោកស្រីទៅតែម្នាក់ឯង ឬក៏ទៅជាក្រុម ឬក៏យ៉ាងម៉េចដែរលោកស្រី?

**ឆ៖** ចាសពេលហ្នឹងគេបញ្ជូនខ្ញុំទៅពីរឡាន ទៅជាកងតែម្ដង ទៅពីរឡានទៅក្រុងកំពង់ឆ្នាំង។ ដល់ទៅដល់ហ្នឹង គេឲ្យខ្ញុំ ទៅដល់កំពង់ឆ្នាំងហ្នឹងគេឲ្យខ្ញុំនៅធ្វើព្រលានយន្តហោះហ្នឹង គឺជីកប្រឡាយ។

[១០:៤៦:១៣]

**ស៖** សូមអរគុណ។ លោកស្រីថា លោកស្រីត្រូវគេបញ្ជូនទៅចំនួនពីរឡានទៅកំពង់ឆ្នាំង អ៊ីចឹងលោកស្រី? អ៊ីចឹងខ្ញុំចង់សុំសួរថា តើពេលដែលគេឲ្យលោកស្រីទៅពីរឡានហ្នឹង នៅក្នុងឡានហ្នឹង សុទ្ធមានៗជាស្ត្រីសុទ្ធសាធ ឬមួយក៏មានលាយឡំជាមួយនឹងបុរសដែរ?

**ឆ៖** ក្នុងពេលនោះទៅជាស្រីសុទ្ធសាធ អត់មានលាយឡំនូវបុរសទេ។

**ស៖** ចុះលោកស្រីមានដឹងថា មូលហេតុអីបានជាគេបញ្ជូនលោកស្រីទៅកំពង់ឆ្នាំងហ្នឹងដែរទេ? ទៅព្រលានយន្តហោះហ្នឹងដែរឬទេ?

**ឆ៖** នៅក្នុងទីនោះ ដែលគេបញ្ជូនខ្ញុំទៅកំពង់ឆ្នាំងហ្នឹងគឺ ខ្ញុំអត់ដឹងរឿងអីសោះ ដឹងគេបញ្ជូនទៅម៉េចទេ ដឹងគេចម្រាញ់ម៉េច ខ្ញុំអត់ដឹង។

**ស៖** សូមអរគុណ។ អ៊ីចឹងបើ -- ឥឡូវខ្ញុំចង់សួរលោកស្រីពាក់ព័ន្ធជាមួយនឹងមេកងពលលោក

ស្រីវិញ។ ពេលដែលលោកស្រីត្រូវបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង គេមានបញ្ជូនមេកងពលលោកស្រីទៅដែរ ឬក៏យ៉ាងម៉េចដែរលោកស្រី? ទៅទាំងក្រុម ទាំងកងពលហ្នឹងទៅទាំងអស់គ្នាតែម្តង ឬមួយក៏យ៉ាងម៉េច?

**ឆ៖** ចាស ពេលគេបញ្ជូនខ្ញុំមក កងពលអត់មានមកជាមួយទេ គឺមកតែខ្ញុំតែនារី ពួកខ្ញុំតែម្តង កងវរៈ៥៣ មកតែមួយវរៈទេ។

[១០:៤៨:១៤]

**ស៖** មកតែ--

**ឆ៖** មកតែវរៈ៥៣ហ្នឹងឯង។

**ស៖** ខ្ញុំសូមសួរថា តើមេកងពលរបស់លោកស្រីមានឈ្មោះអីគេដែរ លោកស្រី?

**ឆ៖** ចាស កងពលខ្ញុំឈ្មោះ បងសួង។

**ស៖** ចុះគាត់ទៅណាដែរលោកស្រី?

**ឆ៖** ចាស ដោយគេបញ្ជូនខ្ញុំមកនៅអូរបែកក្អមមក តែខ្ញុំអត់ដឹងគាត់ទៅណាទេ ប៉ុន្តែខ្ញុំមកនៅអូរបែកក្អមខ្ញុំធ្វើការទៅ ខ្ញុំឮប្រធានវរៈខ្ញុំប្រជុំប្រាប់ខ្ញុំ ប្រាប់ខ្ញុំថា "មិត្តឯងរាល់គ្នានេះឯង សុទ្ធតែជាប់និន្នាការហើយ ពីព្រោះកងពលមិត្តឯងគេចាប់យកទៅដាក់គុកទួលស្លែង ដាក់គុកព្រៃសអស់ហើយ។ ឥឡូវមិត្តឯងនេះ ត្រូវជាប់ឥទ្ធិពលគេហ្នឹងឯង គេក្បត់អស់ហើយ។ ដើមឈើគឺគេ អាធំវាដួលមកហើយ គឺវាសង្កត់អាក្រោមហើយ។ ដូច្នេះមិត្តឯងខំប្រឹងប្រែងធ្វើការទៅ បើមិត្តឯងមិនប្រឹងប្រែងធ្វើការទេ ទោះបីមិត្តឯងអង្គុយបង្ហូរទឹកភ្នែកនឹកម៉ែនឹកឪ នឹកភូមិនឹកស្រុកប៉ុនណា ក៏មិត្តឯងមិនបានជួបម៉ែឪមិត្តឯងដែរ"។

[១០:៥០:០៨]

**ស៖** សូមអរគុណលោកស្រី។ ឥឡូវខ្ញុំសូមឈានចូលប្រធានបទទាក់ទងទៅនឹងព្រលានយន្តហោះវិញ។ មុននឹងបន្តិចលោកស្រីបានលើកឡើងថា ក្រុមលោកស្រីហ្នឹង ត្រូវបានគេបញ្ជូនទៅព្រលានយន្តហោះ។ ពេលដែលលោកស្រីទៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង គេឲ្យលោកស្រីធ្វើយ៉ាងម៉េចដែរលោកស្រី? គេឲ្យលោកស្រីធ្វើអីខ្លះដែរនៅទីនុ៎ង? លោកស្រីអាចជួយរៀបរាប់អំពីដំណើរដើមទងនៃស្ថានភាពដែលលោកស្រីទៅដល់កំពង់ឆ្នាំង ទៅដល់ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងដំបូងវា លោកស្រីជួបអីគេខ្លះ? ហើយមានហេតុការណ៍អីគេកើតខ្លះដែលលោកស្រីអាចចងចាំបាន អាចជម្រាបជូន

អង្គជំនុំជម្រះ? សូមឲ្យលោកស្រីជួយរៀបរាប់បន្តិចមកអំពីស្ថានភាពរបស់លោកស្រីនៅពេលនុ៎ង។

**ឆ៖** ចាស ខ្ញុំសូមរៀបរាប់ជូនអង្គជំនុំជម្រះ។ តែក្នុងនេះ គឺខ្ញុំទៅកំពង់ឆ្នាំងហ្នឹង គេឲ្យខ្ញុំធ្វើជីកប្រឡាយ ហើយគេប្ដូរមកឲ្យខ្ញុំដេរស្លឹក។ ហើយពីដេរស្លឹក គេដកឲ្យខ្ញុំទៅរមាស ទៅលើស៊ីម៉ង់ត៍ ហើយក្នុងនោះ គឺខ្ញុំពិបាកណាស់ក្នុងខ្លួនរបស់ខ្ញុំ។ តាមតែគេចាត់ចែងឲ្យខ្ញុំធ្វើ ខ្ញុំចេះទៅតាមគេហើយ ខ្ញុំអត់ហ៊ានតថ្លៃ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរពាក់ព័ន្ធពេលដែលលោកស្រីទៅដល់ព្រលានយន្ដហោះនោះដំបូង គេមានឲ្យលោកស្រីធ្វើប្រវត្តិរូបអីដែរឬទេ ពេលនុ៎ង?

**ឆ៖** ចាស គេអត់ទាន់ឲ្យធ្វើទេ ដល់ពេលនៅយូរទៅបានគេសួរ គេតាមដានសួរពីប្រវត្តិរូប។

[១០:៥១:៥៥]

**ស៖** ចុះលោកស្រីមានដឹងទេ តើគេធ្វើប្រវត្តិរូបហ្នឹងធ្វើដើម្បីអី?

**ឆ៖** ចាស គេធ្វើប្រវត្តិរូបហ្នឹងគេចម្រាញ់យើង គឺថាគេសួរយើង តើយើងនៅពីមុនមកម៉ែឪយើងបានមានធ្វើទាហាន ឬធ្វើស័ក្តិ១ ស័ក្តិ២ដែរដឹង ឬធ្វើអីខ្លះ។ បើសិនណាជាយើងឆ្លើយបានធ្វើ គឺគេដកយើងយកទៅ មិនដឹងយកទៅណាទេ។ តែយើងអត់បានឆ្លើយថា យើងបានធ្វើទេ។

**ស៖** សូមអរគុណ។ ទាក់ទងទៅនឹងការធ្វើប្រវត្តិរូបនេះ គេធ្វើជា -- គេតែងតែធ្វើជាប្រចាំ ឬមួយក៏គេធ្វើតែម្ដងហ្នឹងទេលោកស្រី?

**ឆ៖** ចាស ពេលណាដែលគេចម្រាញ់យើង គេចង់សួរប្រវត្តិរូបយើងគេចង់ដកយើង ថាយើងសកម្មភាពល្អ មិនល្អ គេចាប់ផ្ដើមធ្វើហើយ គេចាប់ផ្ដើមសួរដេញដោលហើយ។

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់លោកស្រីឡើងវិញបន្តិច។ ការធ្វើប្រវត្តិរូបនេះ តើគេឲ្យលោកស្រីធ្វើតែម្ដងហ្នឹង ឬមួយក៏ឧបមាថាមួយអាទិត្យក្រោយ ឬ៣ខែក្រោយគេធ្វើប្រវត្តិរូបជូនលោកស្រីទៀត ឬក៏យ៉ាងម៉េចដែរលោកស្រី?

**ឆ៖** ចាស គេធ្វើប្រវត្តិរូបនេះ បើតាមខ្ញុំដឹង បើប្រវត្តិរូបរបស់ខ្ញុំផ្ទាល់គេតាមដានតាំងពីសហករណ៍មក រហូតគេខ្សែបណ្ដាញគេរហូតមកដល់សមរភូមិមុខ។ ចាស គេតាមដានសួររហូតទៅ ខ្ញុំថាអត់មានទាហាន អត់មានប៉ូលិស មានចៅហ្វាយស្រុកចៅហ្វាយអីទេ គឺហើទៅ។ ក៏ខ្ញុំនៅជាប់ហ្នឹង សមរភូមិនេះទៅ។

[១០:៥៤:០២]

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមសួរលោកស្រីពាក់ព័ន្ធជាមួយនឹងលក្ខខណ្ឌការងាររបស់លោកស្រីបន្តិច។ អម្បាញ់មិញលោកស្រីបានជម្រាបថា ពេលដែលលោកស្រីមកដល់ដំបូង គេឲ្យលោកស្រីជីកប្រឡាយ ហើយនិងលាយស៊ីម៉ង់ត៍។ អ៊ីចឹងឥឡូវខ្ញុំចង់សុំសួរលោកស្រីថា ពេលដែលលោកស្រីមកដល់ដំបូងហ្នឹង គេឲ្យលោកស្រីជីកប្រឡាយ តើលោកស្រីពេលជីកប្រឡាយហ្នឹង គេកំណត់ឲ្យលោកស្រីធ្វើយ៉ាងដូចម្ដេចដែរលោកស្រី? អាចជួយរៀបរាប់ឲ្យលម្អិតបន្តិចបានដែរឬទេ?

**ឆ៖** ចាស មុនដំបូងដែលមកដល់ហ្នឹង គេឲ្យទៅជីកប្រឡាយហ្នឹង គឺជីកទៅទាំងយប់។ មកដល់ល្ងាចហ្នឹង ថ្ងៃហ្នឹងល្ងាចហ្នឹង យប់ហ្នឹងគេឲ្យទៅ។ ឲ្យជីកហ្នឹងគេវាស់ម៉ែត្រឲ្យជីក។ ប៉ុន្តែវាស់ម៉ែត្រឲ្យជីកហ្នឹង គេជីករួមគ្នាទាំងអស់។ ជីកជាមួយគ្នា លើកជាមួយគ្នាហ្នឹង។

**ស៖** ចុះគេកំណត់ម៉ោងការងារឲ្យលោកស្រីយ៉ាងដូចម្ដេចដែរពេលនុ៎ង? យើងធ្វើប៉ុន្មានពេលដែរ ឬក៏យើងធ្វើតែមួយពេល ហើយយើងឈប់សម្រាករង់ចាំស្អែកចាំធ្វើទៀត ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ពេលដែលទៅជីកប្រឡាយហ្នឹង គឺគេកំណត់ម៉ោង កំណត់ពេលដែរ។ ដែលពេលយប់គឺម៉ោងប្រាំបួន គឺឡើងមកផ្ទះវិញ មកកន្លែងវិញ។ ចាស ពេលព្រឹកឡើងម៉ោងប្រាំ គឺចុះទៅការដ្ឋានវិញ។ ម៉ោងដប់មួយឡើងមកហូបបាយ ម៉ោងមួយល្ងាចគឺចុះទៅ ទល់ម៉ោងប្រាំល្ងាចបានឡើងមកវិញ។

[១០:៥៥:៥៣]

**ស៖** ពេលលោកស្រីជីកប្រឡាយហ្នឹងលំបាកអត់ទេ ឬមួយក៏ស្រួលធម្មតា ឬក៏ម៉េច? លោកស្រីជួយរៀបរាប់បន្តិចមើល៍ ថាតើវាមានលក្ខណៈយ៉ាងម៉េចដែរស្ថានភាពនៅក្នុងការជីកហ្នឹងស្រួលសម្រាប់លោកស្រីដែរ ឬក៏យ៉ាងម៉េចដែរលោកស្រី?

**ឆ៖** ចាស នៅក្នុងជីកប្រឡាយហ្នឹង មិនមានស្រួលប៉ុន្មានទេ។ ការជីក ការធ្វើការហ្នឹង គេបង្ខំយើងឲ្យជីកហើយ ហើយយើងចេះតែប្រឹងទៅជាមួយមិត្តយើងទាំងប៉ុន្មានចេះតែនាំគ្នាខំប្រឹងទៅ ទោះបីតែមិត្តយើង ឬក៏ខ្លួនខ្ញុំក្ដីបែកដៃ ពងដៃយ៉ាងណា ក៏ខ្ញុំមិនហ៊ានឈប់ដែរ នៅតែខំប្រឹងធ្វើ។ ជីកមិនហ៊ានឈប់ទេ ប្រឹងប្រែងទោះបីពងដៃ ក៏នៅតែខំប្រឹង ប្រឹងធ្វើប្រឹងលើក ប៉ុណ្ណឹងចាស។

**ស៖** ចុះអំឡុងពេលដែលលោកស្រីជីកប្រឡាយហ្នឹង ការស្នាក់នៅ ការរស់នៅហ្នឹងយ៉ាងម៉េចដែរ គេផ្ដល់ជម្រកឲ្យសមរម្យដែរឬទេ? ការរស់នៅដូចមានស្ថានភាពយ៉ាងម៉េចដែរលោកស្រី ការរស់នៅវិញ?

**ឆ៖** ចាស ការរស់នៅ កន្លែងគេយកខ្ញុំទៅកន្លែងហ្នឹង ការរស់នៅវាមិនមែនដូចយើងសព្វថ្ងៃ

រស់នៅបានស្រួល ដេកបានស្រួលទេ។ ពេលយើងមកវិញ យើងដេកអី ទឹកមានងូតមាន ប៉ុនទឹកល្អក់។ ងូតហើយអីហើយ យើងមកហើយ ងូតក៏គ្មានសាប៊ូគ្មានអីកក់ដែរកាលហ្នឹងនោះ។ ហើយយើងមក -- ងូតទឹកងូតអីរួចដេកទៅ ដេកកន្លែងមន្ទីរហ្នឹងឯង គ្មានមុង គ្មានអីចង ហើយកន្ទេលអីក៏គ្មានដេកគួរសមដែរ កន្ទេលនោះ កន្ទេលកញ្ចាស់រហាក់រហែកទេ នាំគ្នាក្រាលដេក គ្មានមុងគ្មានអីទេ ចេះតែនាំគ្នាក្រាលដេកទៅ ក្រោកឡើងទៅធ្វើការទៀតទៅ ចាសប៉ុណ្ណឹង។

[១០:៥៧:៤៥]

**ស៖** សូមអរគុណ។ ពាក់ព័ន្ធជាមួយនឹងអនាម័យវិញ តើអំឡុងពេលហ្នឹង យើង -- កន្លែងដែលលោកស្រីរស់នៅហ្នឹង មានអនាម័យដែរឬទេ? ហើយស្ថានភាពពេលនុ៎ងយ៉ាងម៉េចដែរ?

**ឆ៖** ចាស ស្ថានភាពពេលហ្នឹងដែលខ្ញុំនៅនោះ មិនសូវមានអនាម័យប៉ុន្មានទេ ព្រោះអីបើសិនជាមានអនាម័យ វាអាចមានសាប៊ូមានអីកក់រុះ។ តែកាលហ្នឹង គឺគ្មានអនាម័យគ្មានអី មូសក៏មូស សាប៊ូក៏គ្មានកក់ បាយទឹកក៏គេឲ្យហូប គេដួសដាក់នឹងចានដែកទៅ ក៏គ្មានស្អីគ្រប់ស្អីៗដែរ។ ហូបគ្មានអនាម័យដែរទេ។

**ស៖** ចុះអំឡុងពេលហ្នឹង ខ្លួនប្រាណរបស់លោកស្រីហ្នឹងមានធុំក្លិនអីដែរឬទេ? ហើយចុះអ្នកនៅជុំវិញលោកស្រីហ្នឹង គេមានធុំក្លិនដែរ ឬមួយក៏អត់ទេ ឬយើងរស់នៅឡូកឡំគ្នា ឬក៏យ៉ាងម៉េចដែរលោកស្រី?

**ឆ៖** ចាស ពេលដែលខ្ញុំរស់នៅហ្នឹង ជាមួយមិត្ត -- រស់នៅតែជាមួយមិត្តនារីគ្នាខ្ញុំទាំងកងហ្នឹង គឺវាមិនមានអនាម័យអីទេ។ ដល់ៗយើងបានស្អាត បានល្អទេអង្កាល់ហ្នឹង វាគ្មានសាប៊ូហើយ មិត្តនារីយើងមានពេលដើររដូវ ដើរអីមកនោះក៏ វាគ្មានអីបោក គ្មានអីគក់ ហើយគ្មានអីបានស្អាត បានធុំល្អទេ ខោអាវអី គឺគ្មានបានធុំល្អទេ គឺស្អុយហើយ។

**ស៖** ចុះពេលនោះមានមូស ឬក៏សត្វល្អិតផ្សេងៗមករំខានការដំណេករបស់លោកស្រីអីដែរឬទេ ឬក៏លើខ្លួនប្រាណរបស់លោកស្រីអីដែរឬទេ?

[១០:៥៩:៤៥]

**ឆ៖** ចាស អង្កាល់ហ្នឹងមូសៗក៏យើងមិនដឹងធ្វើម៉េច មូសមករោមនឹងខ្លួន នឹងដៃ និងជើងអីទៅ គឺយើងគ្រាន់តែបក់បន្តិចបន្តួចនឹងអាវ នឹងអីទៅ បក់ទៅប៉ះត្រង់ណា យើងដេកមិនលក់អីទៅ ក៏ទៅកាយសំរាមបន្តិចបន្តួចទៅបង្ហុយៗអីទៅ ប៉ុណ្ណឹង ថាឲ្យមានអីចងមុងជាអនាម័យអី អត់មានទេ។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមបន្តទៅទាក់ទងទៅនឹងការលើស៊ីម៉ង់ត៍វិញ។ តើលោកស្រី -- គេបញ្ជូនក្រុមលោកស្រីហ្នឹងទៅលីស៊ីម៉ង់ត៍ទាំងអស់គ្នា ឬក៏ទៅតែលោកស្រីម្នាក់ទេ ឬក៏យ៉ាងម៉េចដែរលោកស្រី? ហើយទៅលីហ្នឹង គឺទៅលីនៅកន្លែងណាដែរ?

**ឆ៖** ចាស ដែលគេបញ្ជូនខ្ញុំទៅលីស៊ីម៉ង់ត៍នៅខាងរមាសហ្នឹង គឺទៅមួយកង មិនទៅតែខ្ញុំទេ។ ទៅមួយកងតូច ចាស។ ដល់ពេលខ្ញុំទៅលីស៊ីម៉ង់ត៍នៅកន្លែងនោះ គឺខ្ញុំលី ខ្ញុំលំបាកណាស់នៅក្នុងលីស៊ីម៉ង់ត៍ហ្នឹង។ ហើយខ្ញុំកាលហ្នឹងខ្ញុំលីទៅ គេដាក់ឲ្យខ្ញុំលីមក មុនដំបូងលីទៅ ដើរទាតែម្តងខ្ញុំ។ ចាស រហូតដល់ខ្ញុំលីហើយឈឺដើមទ្រូង ហើយនារីខ្លះទៀតដែលគ្នាខំប្រឹងប្រែងការងារធ្ងន់ៗពេក លីស៊ីម៉ង់ត៍ហ្នឹងឯង ប៉ះអ្នកណាគ្នារាំងរដូវ គ្នារាំងហើយគ្នាឈឺដើមទ្រូង គ្នាមានអ្នកទាស់ក៏មានដែរ ដែលរាំងរដូវហ្នឹង ដែលការងារធ្ងន់ៗពេក។

[១១:០១:២៨]

**ស៖** នៅក្នុងមួយថ្ងៃ តើលោកស្រីលីស៊ីម៉ង់ត៍ប៉ុន្មានបាវដែរ លោកស្រីចាំបានដែរឬទេ? បើទោះបីលោកស្រីមិនចាំចំនួន លោកស្រីអាចជម្រាបជូនថា ការលីចុះលីឡើងហ្នឹងមានប៉ុន្មានជើង ដែលមើលទៅពេញមួយថ្ងៃពេញ ឬក៏ត្រឹមតែកន្លះថ្ងៃ ត្រូវឈប់លីតែម្តង ឬក៏ម៉េច?

**ឆ៖** ចាស លីស៊ីម៉ង់ត៍ហ្នឹង គឺតាមពេល តាមម៉ោងដូចយើងធ្វើការដឹកប្រឡាយដែរ។ ម៉ោងប្រាំចាប់ផ្តើមនាំគ្នាលី លីហើយគេឲ្យសម្រាក។ ដល់ក្នុងមួយព្រឹកហ្នឹងគេឲ្យសម្រាកតែ១៥នាទីទេ ចាប់ផ្តើមលីទៀតរហូតដល់ម៉ោងដប់មួយបានឈប់។ ថ្ងៃម៉ោងមួយចាប់ផ្តើមធ្វើទៀត រហូតដល់ម៉ោងប្រាំ បានយើងឈប់ដែរ លីស៊ីម៉ង់ត៍ហ្នឹង។ ហើយក្នុងមួយថ្ងៃៗមិនមែនលីបានតិចទេ ច្រើនដែរម្នាក់ៗ ប៉ុនខ្ញុំមិនបានរាប់ មិនបានរាប់ថា យើងម្នាក់គឺលីបានមួយថ្ងៃហ្នឹងបាន២០បេ ឬ៣០បេ ខ្ញុំមិនបានរាប់ទេ ប៉ុន្តែលីមួយថ្ងៃៗ ម្នាក់ៗគឺចូលហើយ ពី១០បេទៅ២០បេ ៣០បេ មួយថ្ងៃៗ។

**ស៖** អ៊ីចឹងទាក់ទងទៅនឹងចំនួនបេស៊ីម៉ង់ត៍វិញ ខ្ញុំចង់សុំសួរលោកស្រីថា ស៊ីម៉ង់ត៍ដែលមានត្រូវលីហ្នឹងមានច្រើន ឬក៏តិច? ហើយមានចំនួនប្រហែលប៉ុន្មានដែរ បើលោកស្រីអាចរកនឹកមើលថាតើចំនួនបេស៊ីម៉ង់ត៍ហ្នឹងវាមានប៉ុន្មានដែរសរុប ដែលមុននឹងលោកស្រីលី? តើមើលទៅមានចំនួនប៉ុន្មាន ហើយគ្នាប៉ុន្មាននាក់ ដែលត្រូវទៅលីស៊ីម៉ង់ត៍ហ្នឹងទាំងអស់ហ្នឹង? មានគ្នាប៉ុន្មាននាក់ដែរ?

[១១:០៣:១១]

**ឆ៖** ដែលទៅលីស៊ីម៉ង់ត៍ហ្នឹង គ្នាប្រហែលជាចំនួន៣០នាក់ ទៅលីស៊ីម៉ង់ត៍។ ហើយស៊ីម៉ង់ត៍

ហ្នឹង ទៅលីហ្នឹង មិនមែនលីតែមួយថ្ងៃរួចទេ គឺមួយខ្សែរទេះភ្លើងហ្នឹងវាមានច្រើនបារ៉ុង។ ចាស មួយខ្សែរទេះភ្លើងហ្នឹង វាមាន៥០បារ៉ុង ៦០បារ៉ុង មួយខ្សែរទេះភ្លើងហ្នឹង។ ហើយលើកមានពីកន្លះខែ គឺបានរួចបានរួចមួយខ្សែរទេះភ្លើងហ្នឹង។

**ស៖** ខ្ញុំសូមសួរបកទៅលើចំណុចមួយដែលលោកស្រីថា ពេលដែលលោកស្រីមកលីស៊ីម៉ង់ត៍ដំបូង លោកស្រីបានធ្វើដំណើរ -- លីអត់រួច ដូចជាដើរដំណើរទាអ៊ីចឹង បានន័យថាលោកស្រីមិនអាចលើកនឹងទម្ងន់នៃស៊ីម៉ង់ត៍ហ្នឹង។ ចុះទម្ងន់នៃស៊ីម៉ង់ត៍ហ្នឹង វាក្នុងមួយបេហ្នឹង វាផ្ទុកទម្ងន់ប្រហែលជាប៉ុន្មានគីឡូដែរ លោកស្រី?

**ស៖** ចាស ស៊ីម៉ង់ត៍ក្នុងមួយបេហ្នឹងឯង វាមាន៥០គីឡូ។ ៥០គីឡូហ្នឹងវាមិនថាស្រាលប៉ុន្មានទេ។ ៥០គីឡូ យើងជាស្រី យើងដាក់ទៅដើរទាហើយ។ ចេះតែដើរទាប៉ុនណា ក៏យើងខំប្រឹងដែរ ព្រោះយើងនៅការគ្រប់គ្រងរបស់គេ បើយើងមិនប្រឹងប្រែង គឺគេយកយើងទៅសម្លាប់។ យើងខ្លាចអាត្រង់ហ្នឹងឯង ទោះបីយើងដើរទា យើងដើរម៉េច ទោះបីឈឺខ្នង ឈឺចង្កេះ ឈឺសរសៃម៉េច ក៏យើងនៅតែខំប្រឹងដែរ យើងមិនហ៊ានតថ្លៃជាមួយគេទេ។

[១១:០៤:៤២]

**ស៖** សូមអរគុណលោកស្រី។ ពេលដែលលោកស្រីដើរដំណើរទាអ៊ីចឹង លោកស្រីមានត្រូវបានការស្ដីបន្ទោសពីអ្នកមើលការចំពោះក្រុមលោកស្រីដែលលីស៊ីម៉ង់ត៍ហ្នឹងដែរឬទេ? ឬមួយក៏គ្រាន់តែយើងមានស្ថានភាពបែបហ្នឹង គេគ្រាន់សួរសុខទុក្ខយើងថា ឲ្យយើងសម្រាកសិនអី ឬក៏ ឬមួយក៏គេស្ដីឲ្យវិញ ឬក៏យ៉ាងម៉េចដែរលោកស្រី?

**ឆ៖** ដល់ពេលខ្ញុំដើរទារហ្នឹងឯង មានគេប្រធានក្រុមគេថាឲ្យដែរ គេថាឲ្យខ្ញុំថា យី! គេៗទៀតមិត្តៗដទៃគេលីរួច ចុះខ្លួនឯងហ្នឹងក៏លីអីក៏មិនរួច ក៏ខ្សោយខ្លាំងម្ល៉េះ ក៏ដើរទារតតេះតតះអ៊ីចុះឯងហ្នឹង។ ខ្ញុំក៏បានថា ខ្ញុំថា ចុះបើខ្ញុំដើរមិនរួច ខ្ញុំមិនធ្លាប់លី ដល់ពេលខ្ញុំលីមក ខ្ញុំទន់ចង្កេះហើយ ខ្ញុំដើរទា។ ដល់គេបាត់មាត់ទៅដែរ ចាស។

**ស៖** អម្បាញ់មិញ លោកស្រីបានលើកឡើងថា ការទៅលីស៊ីម៉ង់ត៍ហ្នឹងរយៈពេល១៤ថ្ងៃជាប់គ្នាតែម្ដង។ អ៊ីចឹងក្រោយពេលលីស៊ីម៉ង់ត៍ចប់ តើគេឲ្យលោកស្រីធ្វើអ្វីតទៅទៀតដែរ លោកស្រីចាំបានដែរឬទេ?

**ឆ៖** ដល់ពេលលីស៊ីម៉ង់ត៍ចប់អស់មួយខ្សែរទេះភ្លើងហ្នឹង គេឲ្យខ្ញុំមកនៅព្រលានយន្តហោះវិញ

មកនៅជីកប្រឡាយដដែលវិញ។

[១១:០៦:១២]

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំសូមឱ្យលោកស្រីជួយប្រៀបធៀបបន្តិចមើល ថាតើការងារដែលជីកប្រឡាយ ហើយនិងការងារដែលលោកស្រីលីស៊ីម៉ង់ត៍ហ្នឹង តើការងារទាំងពីរហ្នឹង មួយណាមានស្ថានភាពធ្ងន់ធ្ងរជាងសម្រាប់លោកស្រី ឬមួយក៏យ៉ាងម៉េចដែរលោកស្រី?

**ឆ៖** ចាស ការងារជីកប្រឡាយ ហើយនិងការងារលើកស៊ីម៉ង់ត៍ហ្នឹង គឺវាធ្ងន់ធ្ងរដូចគ្នា មិនជាស្រាល ឬធ្ងន់យ៉ាងណាមួយទេ គឺប្រហែលគ្នា។ លីស៊ីម៉ត៍ក៏វាធ្ងន់ វាគ្រាំគ្រាខ្លួន ហើយទៅជីកប្រឡាយក៏វាៗគ្រាំគ្រាខ្លួនដូចតែគ្នាហ្នឹង ពីព្រោះជីកប្រឡាយវាដី ប៉ះត្រង់ណាជ្រាយទៅ ប៉ះត្រង់ណាដីរឹងទៅ។ ជីកបែកដៃបែកជើងហើយទៅ ហើយយើងនាំគ្នាលើកសែងលើកឡើងលើមក វាធ្ងន់ដូចតែគ្នាដែរ ចាស។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកស្រីពាក់ព័ន្ធជាមួយនឹងកន្លែងលោកស្រីជីកប្រឡាយហ្នឹង ហើយតើកន្លែងហ្នឹងវាមានចម្ងាយប៉ុន្មានពីការដ្ឋានៗព្រលានយន្តហោះហ្នឹង តើវាមានចម្ងាយប្រហែលប៉ុន្មាន លោកស្រីអាចមើលឃើញដែរឬទេ ស្ថានភាពនៅក្នុងការដ្ឋានរបស់ព្រលានយន្តហោះទាំងមូល? លោកស្រីអាចមើល សម្លឹងទៅឃើញទិដ្ឋភាពហ្នឹងដែរឬក៏យ៉ាងម៉េចដែរ លោកស្រី? ហើយបើសិនជាលោកស្រីសម្លឹងឃើញ តើលោកស្រីឃើញស្ថានភាពយ៉ាងម៉េចដែរ លោកស្រីអាចជួយជម្រាបជូនអំពីស្ថានភាពនៅក្នុងការដ្ឋានហ្នឹងជូនអង្គជំនុំជម្រះឱ្យបានដឹងបន្តិចមក លោកស្រី?

[១១:០៧:៥៨]

**ឆ៖** ចាស នៅក្នុងជីកប្រឡាយហ្នឹង គឺនៅក្នុងព្រលានយន្តហោះហ្នឹងឯង។ វាអត់មាននេះទេ វាជុំវិញទាំងអស់ហ្នឹង វាជុំវិញហ្នឹងឯងចាស។ ជីកប្រឡាយ គេក៏ជីក យើងក៏ជីក យុទ្ធជន យុទ្ធនារីជីកជាប់គ្នានោះឯង ហែទៅ។ ហើយអាគេ យើងជីកក៏ជីកទៅ ហើយអាគេ អាគេពង្រាបដីហ្នឹង គេពង្រាបផ្សេងទៅ អាឡានពង្រាបដីហ្នឹង។ ឡានពង្រាបដីហ្នឹងផ្សេងទៅ អាគេរោយថ្មក៏គេរោយផ្សេងទៅ អាយើងជីកប្រឡាយនោះ យើងជីកដោយឡែកទៅ តាមកងតាមក្រុមហ្នឹងជាប់គ្នាហ្នឹង ពេញតែព្រលានហ្នឹងទៅ។

**ស៖** សូមអរគុណ។ ខ្ញុំចង់សូមសួរលោកស្រីពាក់ព័ន្ធទៅនឹងស្ថានភាពរបស់មនុស្សវិញ។ មនុស្ស ដែលធ្វើការនៅក្នុងការដ្ឋានហ្នឹង បើតាមការសង្កេតរបស់លោកស្រីហ្នឹង លោកស្រីសង្កេតឃើញយ៉ាងម៉េចដែរ ទាក់ទងទៅនឹងរូបរាងកាយរបស់មនុស្ស ឬក៏កម្មករដែលធ្វើការនៅក្នុងការដ្ឋានហ្នឹងលោក

ស្រី? ទាំងលោកស្រី ទាំងមនុស្សដែលនៅធ្វើការក្នុងការដ្ឋានហ្នឹង រូបរាងកាយរបស់គាត់យ៉ាងម៉េចដែរ លោកស្រី ពេលនុ៎ង?

**ឆ៖** ចាស តាមខ្ញុំសង្កេតទៅនៅក្នុងព្រលានយន្តហោះទាំងអស់ហ្នឹង គឺៗថាទាំងរូបខ្ញុំ ទាំងរូបខ្ញុំគេ ទាំងនារីយុទ្ធជនទាំងអស់ហ្នឹង គឺស្ថានភាពរបស់គាត់ ទាំងខ្ញុំទាំងគេ គឺមិនមែនជាធាត់ មានសាច់មានឈាមដូចគេទេ គឺសុទ្ធតែស្គមហើយ នៅតែក្បាល ហើយនិងក្បាលជង្គង់ទេ។ ដើរវ៉ាន់ៗហើយ ហើយការងារគឺចិត្ត គឺចេះតែប្រឹងខ្លាចស្លាប់ គឺខំនាំគ្នាចេះតែធ្វើហើយ ធ្វើទៅហើយទោះបីបែកដៃបែកជើង ទោះបីគ្រុនឈឺបន្តិចបន្តួចក៏អត់ហ៊ានដែរ អត់ហ៊ានឈប់ទេ។ ហើយខ្លួនស្គម គឺគ្មានកម្លាំងទេ ទាំងគេទាំងខ្ញុំគឺគ្មានកម្លាំងទេ ប៉ុនចេះតែទៅ។

[១១:០៩:៥៥]

**ស៖** សូមអរគុណលោកស្រី។ នៅក្នុងអំឡុងពេលដែលលោកស្រីធ្វើការនៅក្នុងព្រលានយន្តហោះហ្នឹង លោកស្រីមានប្រទះឃើញមន្ទីរសន្តិសុខអីនៅជិតៗហ្នឹងដែរឬទេ?

**ឆ៖** ចាស នៅក្នុងព្រលានយន្តហោះហ្នឹង គឺខ្ញុំមិនបានមើលសព្វគ្រប់ទេ ឃើញមន្ទីរសន្តិសុខអី ខ្ញុំអត់មានបានឃើញ អត់បានដឹងទេ។

**ស៖** សូមអរគុណ។ អ៊ីចឹងពេលដែលលោកស្រីធ្វើដំណើរពីកន្លែងជីកប្រឡាយ ទៅកន្លែងលីស៊ីម៉ង់ត៍ ក៏ដូចជាពេលលោកស្រីធ្វើដំណើរត្រឡប់មកវិញអី លោកស្រីមានដែលប្រទះឃើញកន្លែងណាមួយ ឬក៏មន្ទីរសន្តិសុខអីដែលអាចលោកស្រីដឹង ឬក៏ឮពីនរណាប្រាប់អី ដែលធ្លាប់ឮអ៊ីចឹងទេលោកស្រី? គេមានធ្លាប់ប្រាប់ថាមានមន្ទីរសន្តិសុខអីដែរឬទេ?

**ឆ៖** ចាស កាលខ្ញុំទៅលីស៊ីម៉ង់ត៍នៅរមាសហ្នឹង ខ្ញុំជិះឡានត្រឡប់មកវិញ មានមិត្តតែកុងឡានម្នាក់ គាត់ប្រាប់ខ្ញុំ គាត់ថា "នេះ! មិត្តយើងនេះ! មន្ទីរសន្តិសុខមួយដែរនៅកន្លែងនេះ ចាស។ ហើយរហូតដល់ខ្ញុំជិះ ជិះឡានហ្នឹងត្រឡប់មកទៀត -- មកដល់ជិតដល់ព្រលានវិញហើយ នៅជើងភ្នំវត្តព្រះធាតុហ្នឹងឯងក៏ខ្ញុំបានក្រឡេកឃើញទៅ មើលទៅខាងកើតទៅ មកក្រឡេកឃើញឡានមួយ ហើយនិង -- ដែលគេចាប់មីងៗនៅក្នុងហ្នឹងឯង គេចាប់ដាក់ឡាន ខ្ញុំឃើញសន្តិសុខមួយឈរស្ពាយកាំភ្លើង គឺបញ្ជាឲ្យមីងៗអីឡានហើយ ក៏ខ្ញុំគ្រាន់បានឃើញប៉ុណ្ណឹង ក៏ខ្ញុំជិះឡានហួសមក។ ប៉ុណ្ណឹងចាស។

[១១:១១:៥៦]

**ស៖** សូមអរគុណ។ ខ្ញុំសូមធ្វើការបញ្ជាក់ឡើងវិញបន្តិច ដោយសារខ្ញុំរៀងភ័ន្តច្រឡំបន្តិច។ សូម

សួរលោកស្រីថា ពេលដែលលោកស្រីឃើញ គេប្រាប់ ថាតែកុងឡានប្រាប់លោកស្រីថា មានមន្ទីរសន្តិសុខមួយអ៊ីចឹង -- ហើយមួយទៀតអំមិញលោកស្រីបានលើកឡើងថា មានការចាប់ឲ្យស្ត្រីហ្នឹងឡើងឡាន រុញឲ្យឡើងឡាន។ មន្ទីរសន្តិសុខហ្នឹងផ្សេងពីកន្លែងឡើងឡានហ្នឹង ឬក៏កន្លែងតែមួយ?

**ឆ៖** មន្ទីរសន្តិសុខហ្នឹង គឺនៅជិតរមាសហ្នឹង ចាសនៅជិតវ៉ារមាស។ ចាស ដល់មកទៀត មកដល់ជិតព្រលានហ្នឹង ក្នុងព្រលានហ្នឹងឯង អាជិតព្រលាន ខាងកើតព្រលានហ្នឹងឯង បានឃើញគេ -- កន្លែងហ្នឹងឯងមួយទៀត។ ឃើញកន្លែងមួយទៀតហ្នឹងដូចខ្ញុំថាហ្នឹង ខ្ញុំថា ឃើញគេឲ្យមីងៗឲ្យឡានហ្នឹង គេបញ្ជាឲ្យឡើងឡានដែរ ឃើញគេស្ពាយកាំភ្លើងម្នាក់ហ្នឹង គេបញ្ជាឲ្យឡើងឡាន ខ្ញុំក៏បានឃើញតែប៉ុណ្ណឹងឯង ខ្ញុំជិះឡានរហូតមក។

**ស៖** សូមអរគុណ។ ពេលដែលគេបញ្ជាឲ្យស្ត្រីទាំងនោះ មីងៗហ្នឹងឡើងឡានហ្នឹង តើអ្នកដែលបញ្ជាហ្នឹង គាត់មានកាន់ឧបករណ៍ -- មានកាន់អាវុធ ឬក៏ដៃទទេលោកស្រី ពេលនុ៎ង?

**ឆ៖** ចាស គាត់កំពុងបញ្ជាហ្នឹង ខ្ញុំឃើញគាត់ស្ពាយកាំភ្លើងមួយដើម។

**ស៖** សូមអរគុណលោកស្រី។ ទាក់ទងទៅនឹងការដែលហៅមីងៗឡើងឡានហ្នឹង ខ្ញុំចង់សូមសួរទៀតថា តើពេលហ្នឹងមីងៗដែលគេឲ្យឡើងឡានហ្នឹង ឡើងតែមីងៗហ្នឹងទេ ឬមួយក៏មានក្មេង ក្មេងៗត្រូវគេឲ្យឡើងដែរ ឬក៏យ៉ាងម៉េច? ឬក៏មានតែស្ត្រីហ្នឹងទេ?

**ឆ៖** ចាស នៅពេលនោះ ខ្ញុំឃើញទាំងម្ដាយ ទាំងកូនហ្នឹងថា មានម៉ែ មានកូនហើយ។ ស្ត្រីមានកូនៗគាត់មាន កូន មានម៉ែ មានក្មេង មេម៉ាយក៏មាន កូនក៏មាន។

[១១:១៤:០២]

**ស៖** សូមអរគុណ។ តើស្ត្រីទាំងនោះហ្នឹង បើតាម -- លោកស្រីមានដឹងទេថា តើពួកគាត់មានតួនាទីអ្វីដែរ ឬក៏មានប្រព្រឹត្តខុសអីដែរ បានជាគេបញ្ជូនពួកគាត់ឡើងឡាន?

**ឆ៖** ខ្ញុំអត់ដឹងដែរ រឿងគាត់ខុសអី គឺខ្ញុំអត់ដឹង ប៉ុន្តែខ្ញុំឃើញ ឃើញ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកស្រីពាក់ព័ន្ធជាមួយនឹងកិច្ចប្រជុំ ថាតើនៅក្នុងអំឡុងពេលដែលលោកស្រីធ្វើការនៅព្រលានយន្តហោះហ្នឹង គេមានបើកកិច្ចប្រជុំអីដែរឬទេ ពេលនុ៎ង? ហើយកិច្ចប្រជុំហ្នឹងគេនិយាយពីអីខ្លះដែរ លោកស្រី?

**ឆ៖** ចាស នៅក្នុងធ្វើព្រលានយន្តហោះហ្នឹង មានកងខ្ញុំ ក្រុមខ្ញុំហ្នឹងឯង មានតែប្រជុំទិតៀនគ្នាពីរឿងការងារហ្នឹង គេថា "មិត្តឯងមិនធ្វើការ គេខំប្រឹងជំរុញចលនាយើងធ្វើការ។ ទោះបីជាយ៉ាងណា ក៏

យើងមិនអាចមិនទៅធ្វើការដែរ ដាច់ខាតទៅធ្វើការ" គ្រាន់តែប្រជុំបំពាក់បំប៉នស្មារតីប៉ុណ្ណឹងឯង។

[១១:១៥:៣៨]

**ស៖** សូមអរគុណ។ លោកស្រី ខ្ញុំសូមបញ្ជាក់បន្តិច ទាក់ទងទៅនឹងការប្រជុំទិតៀនហ្នឹង លោកស្រីដែលប្រទះឃើញ ឬក៏ធ្លាប់ដឹងអំពីថាតើអ្នកដែលគេត្រូវទិតៀន ថាគាត់ធ្វើការមិនល្អអីចឹង ថាតើមានអីកើតឡើងចំពោះបុគ្គលហ្នឹងដែរឬទេ?

**ឆ៖** ចាស ដែលគេប្រជុំទិតៀនយើងធ្វើការហ្នឹងឯង។ យើងជាយុទ្ធជនធម្មតាហ្នឹងឯង តែប្រធានកង ប្រធានក្រុមគេប្រជុំហើយ ទិតៀនយើងហើយ គេថាយើងម៉េច ក៏យើងអត់ហ៊ានតថ្លៃជាមួយគេទេ ទោះបីយើងឈឺយ៉ាងណាបន្តិចបន្តួច ក៏យើងប្រឹងប្រែងទៅទៀតហើយ យើងអត់ហ៊ានឈរជាមួយគេទេ ដូចថាអត់ហ៊ានតជាមួយគេ។

**ស៖** សូមអរគុណ ខ្ញុំសូមបញ្ជាក់សំណួរខ្ញុំឡើងវិញបន្តិច។ ខ្ញុំចង់សូមសួរលោកស្រីថា លោកស្រីមានដែលធ្លាប់ដឹង ឬក៏ធ្លាប់ឮ ឬក៏ធ្លាប់ឃើញបុគ្គលដែលត្រូវបានគេទិតៀននៅក្នុងអង្គប្រជុំ ត្រូវបានគេទិតៀន ទិតៀនគាត់ហើយ តើបុគ្គលហ្នឹង មានអីកើតឡើងចំពោះបុគ្គលនោះដែរឬទេ?

[១១:១៧:០២]

**ឆ៖** ចាស ដែលលើកអង្គប្រជុំទិតៀនបុគ្គលមួយហ្នឹងៗ ដូចខ្ញុំបានឆ្លើយប្រាប់ហើយ ខ្ញុំថា អត់ហ៊ាននឹងគេទេ។ ទោះបីគេទិតៀន គេថាប៉ុនណា ក៏យើងអត់ហ៊ានតថ្លៃមួយមាត់ដែរ។ សុខចិត្តថា ឈឺប៉ុនណា ក៏ក្រោកវារទៅធ្វើជាមួយគេទៀតហើយ អត់ហ៊ានទេ ចាស។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកស្រីហ្នឹង មិនមានករណីរបស់លោកស្រី គឺករណីអ្នកដែលនៅជុំវិញលោកស្រីណា លោកស្រី។ ទាក់ទងទៅនឹងបុគ្គលិកដែលត្រូវបានគេទិតៀននៅពេលប្រជុំ លោកស្រី មានដែលជួបអ្នកហ្នឹងទេ។ មានដែលពេលប្រជុំមួយលើកណា ដែលត្រូវគេទិតៀនលោកណាមួយអី លោកស្រីមានដែលជួបប្រទះរឿងហ្នឹងទេ?

**ឆ៖** ចាស ទោះបីនៅកងជិតគ្នាក្ដី ក៏ខ្ញុំអត់ដែលបានចូលរួមដែរ ដែលអត់បានដឹង បានឮពីរឿងកងគេទេ។ តែពេលនោះ គឺដឹងពីក្នុងកងខ្លួនរបស់ខ្លួន បានដឹង។ បើថាកងដទៃទៀត យើងអត់មានទៅបានដឹងបានឮជាមួយគេទេ គេអត់មានឲ្យយើងចូលរួម ឲ្យយើងលូកដៃលូកជើងជាមួយគេបានដឹងរឿងហេតុរបស់គេទេ។ សូម្បីគេទាញយកមនុស្សនោះឯងទៅសម្លាប់ ក៏គេមិនឲ្យយើងដឹងដែរ។

[១១:១៨:១៩]

**ស៖** សូមអរគុណ។ ខ្ញុំនឹងតាំងសំណួរពាក់ព័ន្ធជាមួយនឹងចំណុចមួយចំនួនដែលលោកស្រីបានរៀបរាប់នៅក្នុងពាក្យបណ្ដឹងរបស់លោកស្រី។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រើប្រាស់ឯកសាររបស់ដើមបណ្ដឹង -- ពាក្យបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមាន ERN លេខ 00587138 ជាភាសាខ្មែរ ហើយនិង 00587137 ជាភាសាបារាំង, លេខ 00106930 និង លេខ 8 ជាភាសាអង់គ្លេស។ លោកស្រី នៅក្នុងពាក្យបណ្ដឹងនោះ លោកស្រីបានបញ្ជាក់ថា លោកស្រីមានការភ័យខ្លាច និងតក់ស្លុតណាស់ ពេលឃើញគេចាប់មនុស្សម្ដងៗ ពីរទៅបីឡានយកចេញទៅ។ ខ្ញុំសូមសួរលោកស្រីថា តើការចាប់មនុស្សពីរទៅបីឡានចេញទៅហ្នឹង គឺចាប់ចេញពីព្រលានយន្តហោះកំពង់ឆ្នាំង ឬក៏ចាប់ចេញពីកន្លែងណាផ្សេង? លោកស្រីអាចជួយបំភ្លឺកន្លែងហ្នឹងបន្តិចបានដែរឬទេ?

[១១:១៩:៤៦]

**ឆ៖** ចាស ខ្ញុំ សំណួររបស់ខ្ញុំដែលខ្ញុំឆ្លើយនោះ គឺខ្ញុំអត់បានឃើញផ្ទាល់ទេ ដែលគេចាប់ផ្ទាល់ដាក់ឡានហ្នឹង គឺខ្ញុំអត់ឃើញទេ។ តែខ្ញុំមកពីព្រលានយន្តហោះកំពង់ឆ្នាំងវិញ គឺខ្ញុំមកនៅអូរបែកក្អម។ ខ្ញុំនៅតាមថ្នល់នឹងអូរបែកក្អមហ្នឹងឯង ខ្ញុំអាចបានឃើញឡានមានមួយថ្ងៃហ្នឹង ឡានពីរ ក្រោយឡើងទៀតឃើញឡានបី ប៉ុន្តែសុទ្ធតែឡានឃ្លុប។ ប៉ុន្តែពួកមិត្តខ្ញុំអាចសន្និដ្ឋានថា ឡានឃ្លុបនេះគឺជាឡានអ្នកទោសហើយ គេចាប់យកទៅទៀតហើយ គ្រាន់តែនាំគ្នាដឹងតែប៉ុណ្ណោះទេ បើថាឲ្យឃើញចាប់ដាក់ឡានផ្ទាល់គឺអត់ឃើញទេ តែឃើញឡានឃ្លុបទៅគឺសុទ្ធសាច់តែអ្នកទោសហើយ *(ឮមិនច្បាស់)* ប៉ុណ្ណោះឯងទេ។

**ស៖** សូមអរគុណ។ អម្បាញ់មិញខ្ញុំមានការភ័ន្តច្រឡំបន្តិច ដោយសារពីដំបូងលោកស្រីថា មិនបានឃើញទេ ក្រោយមកលោកស្រីថាបានឃើញឡានឃ្លុប។ អ៊ីចឹងខ្ញុំសូមបញ្ជាក់តិចថា តើលោកស្រីបានឃើញឡានឃ្លុបនោះឬក៏អត់?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! ឆ្លើបតប!

**លោកស្រី គង់ សៀក៖**

**ឆ៖** ឡានឃ្លុបហ្នឹងគឺខ្ញុំមិនបាននេះទេ គឺខ្ញុំឃើញ ដូចខ្ញុំនៅ ដូចខ្ញុំប្រាប់ សំណួរគាត់ហើយ ខ្ញុំថាគ្រាន់តែឃើញខ្ញុំនៅតាមថ្នល់នេះឯង ខ្ញុំឃើញឡានឃ្លុបគេបើកតាមថ្នល់មក ឃើញឡានឃ្លុប គឺខ្ញុំថា គឺឡានឃ្លុបមកទៀតហើយ ប្រាកដជាគេចាប់មនុស្សយកមកទៀតហើយមិត្តយើង។ អ៊ីចឹងទៅខ្ញុំមានអារម្មណ៍ភ័យក្នុងខ្លួនខ្ញុំ។ ខ្ញុំថាឡានឃ្លុបនេះច្បាស់ជាគេចាប់មនុស្សយកទៅទៀតហើយ ហើយខ្លួនឯង

ភ័យអារម្មណ៍នឹកឃើញថា មិនដឹងតែយើងជាយ៉ាងណាដែរទេ ដូចគេដែរក៏មិនដឹងទេ។ គ្រាន់តែប៉ុណ្ណឹងឯងអារម្មណ៍ខ្ញុំនោះ។

[១១:២១:៣៤]

**សួរដោយលោកស្រី ទី ស្រ៊ីនណា៖**

**ស៖** សូមអរគុណ។ ទាក់ទងទៅនឹងទំព័រដដែលហ្នឹង -- ឯកសារដដែលលេខ ERN ដដែល ហើយត្រង់ចំណុចមួយផ្សេងទៀតដែលលោកស្រីបានលើកឡើងថា លោកស្រីបានឃើញគេយកមនុស្សទៅឆក់នឹងខ្សែភ្លើងដោយសារកំហុសបន្តិចបន្តួច។ សំណួររបស់ខ្ញុំសុំសួរថា តើលោកស្រីឃើញហ្នឹងឃើញនៅកន្លែងណាដែរលោកស្រី?

**ឆ៖** ចាស អង្គាល់ដែលខ្ញុំឃើញ ដែលគេឆក់ខ្សែភ្លើងហ្នឹង គឺខ្ញុំបានប្រាប់គាត់រួចហើយ គឺខ្ញុំនៅព្រលានយន្តហោះ ពេលហ្នឹងគឺខ្ញុំឈប់ពីសម្រាកការងារ គឺខ្ញុំទៅហូបបាយនៅសហករណ៍ ក៏ខ្ញុំតម្រៀបជួរគ្នាទៅហូបបាយទៅ មិត្តយើងបានគាត់កេះខ្ញុំប្រាប់ខ្ញុំថា គេឆក់ខ្សែភ្លើងមិត្តយើងទៀតហើយនោះ នៅក្រោមដើមស្វាយនោះ។ ដល់ពេលខ្ញុំមើលទៅតាមគាត់ទៅ ឃើញមនុស្សហ្នឹងពីរនាក់ ម្នាក់អង្គុយមួយម្នាក់ឈរមួយប៉ុណ្ណឹងឯង។

**ស៖** សូមអរគុណ។ ចុះលោកស្រីបានដឹងពីមូលហេតុអ្វីបានជាគេឆក់ខ្សែភ្លើងបុគ្គលហ្នឹងដែរឬទេ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងពីមូលហេតុគេទេ ពីព្រោះគេជាយុទ្ធជន ហើយគេនៅកងផ្សេង ខ្ញុំជាកងផ្សេង ប៉ុន្តែគ្រាន់តែដើរទៅហូបបាយ គ្រាន់តែឃើញ គ្រាន់តែកេះគ្នាមើលប៉ុណ្ណឹងឯងទេ អត់ហ៊ានមើលគេ ហើយក៏អត់ហ៊ានដឹងរឿងគេដែរទេ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរថា តើលោកស្រីមានស្គាល់ឈ្មោះ រ៉ន ដែរឬទេ?

[១១:២២:២៣]

**ឆ៖** ឈ្មោះ រ៉ន កាលដែលខ្ញុំនៅធ្វើការជាមួយកងពល៤៥០ហ្នឹង គាត់នៅដាំបាយឲ្យខ្ញុំហូបអីចឹង។ នៅដាំបាយឲ្យខ្ញុំហូប ដល់ពេលនេះទៅ គេចាប់គាត់យកទៅគុកទួលស្លែង ខ្ញុំអត់បានដឹងគេចាប់ទេ ប៉ុន្តែដល់ក្រោយឡើងមក មិត្តម៉េត ដែលគាត់ឡើងបកស្រាយអង្គាល់មុននោះ គាត់នាំខ្ញុំទៅគុកទួលស្លែង មើលគុកទួលស្លែងគាត់ប្រាប់ខ្ញុំទេ គ្រាន់បានប្រាប់ខ្ញុំថា "នេះ បងរ៉ន កងយើង ដែលកងយើង គាត់ដាំបាយឲ្យយើងហូប ឥឡូវគេចាប់គាត់មកគុកទួលស្លែងហើយ" គ្រាន់គាត់ប្រាប់ខ្ញុំទេ។ ខ្ញុំគ្រាន់តែឃើញ

រូបថតហ្នឹងនៅគុកទួលស្លែងហ្នឹងទេចាស។

**ស៖** អ៊ីចឹងមានន័យថា លោកស្រីបានឃើញរូបថតគាត់នៅគុកទួលស្លែង ក្រោយពេល១របប ខ្មែរក្រហម ឬក៏មុន -- ក្នុងអំឡុងពេលហ្នឹង ឬក៏ម៉េចលោកស្រី?

**ឆ៖** ចាស បងរ៉ន ហ្នឹងគាត់នៅកងពល៤៥០ហ្នឹង គាត់នៅក្នុងអំឡុងរបបខ្មែរក្រហមហ្នឹងឯង គាត់នៅដាំបាយឲ្យខ្ញុំហូប ខ្ញុំធ្វើទ័ព គាត់ក៏ទ័ព ប៉ុន្តែខ្ញុំធ្វើស្រែ គាត់ដាំបាយ។ ចាស ដល់ក្រោយឡើងខ្ញុំបែកគ្នាមក ហើយមិនដឹង បងរ៉ន ហ្នឹងគាត់ទៅណា តែដល់ខ្ញុំមកសាលាក្ដីនេះឯង ដល់ពេលជិះឡានដើរមើលគុក តាមគុកទួលស្លែងអ៊ីចឹងទៅ មិត្តម៉េត ហ្នឹងគឺមិត្តអង្គភាព៤៥០ដូចខ្ញុំដែរ ក៏គាត់ប្រាប់ខ្ញុំថា "នេះបងនេះ បងរ៉ន គេចាប់មកដាក់គុកទួលស្លែងហ្នឹងឯង"។ គាត់ដឹងប្រវត្តិ បងរ៉ន ហ្នឹង គាត់ថា "នេះរូបថតគាត់" គឺខ្ញុំបានឃើញអាហ្នឹងមែន រូបថតគាត់ ១បង្ហាញខ្ញុំ។ តែប៉ុណ្ណោះឯង ខ្ញុំអត់មានដឹងអីណាទៀតទេ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកស្រីបកទៅលើស្ថានភាពព្រលានយន្តហោះបន្តិច ទាក់ទងទៅនឹងការដើរហើរការនិយាយស្ដីនៅក្នុងព្រលានយន្តហោះ ពេលដែលលោកស្រីកំពុងធ្វើការ ថាតើពេលហ្នឹងគេ លោកស្រីអាចនិយាយគ្នា ប្រាស្រ័យទាក់ទងគ្នាលេងជាមួយនឹងមិត្តរួមការងារ ក៏ដូចជាអាចដើរឆ្លងទៅក្រុមមួយផ្សេងមួយទៀតបានដែរឬទេ? ពីកងមួយទៅកងមួយ អាចធ្វើអ៊ីចឹងបានដែរឬទេ ជំនាន់ -- អំឡុងពេលហ្នឹង?

[១១:២៥:២៥]

**ឆ៖** ចាស កាលហ្នឹងទោះបីជាមិត្ត -- បាននិយាយគ្នាតែមិត្តក្នុងកងជាមួយគ្នា១ឯងទេ ក្នុងកងក្នុងក្រុមគ្នាឯង បានប៉ាននិយាយ។ តែកងដទៃទៀតគឺអត់ប៉ាននិយាយទេ សូម្បីតែបងប្អូនបង្កើត ប្អូនប្រុសបង្កើត ទោះបីឃើញមុខគ្នាក៏អត់ប៉ាននិយាយដែរ ចាស អត់មានឲ្យនិយាយគ្នាបានទេ។ និយាយបានតែកងក្នុងកងគ្នាឯងនេះឯង។ ហើយនោះអត់ប៉ាន ពីក្រុមមួយទៅក្រុមអត់ប៉ានដើរទេ អត់ប៉ាននិយាយសោះ។

**ស៖** មូលហេតុអ្វីបានជាលោកស្រីមិនអាចដើរឆ្លងកាត់និយាយបានទៅលើ រវាងកងមួយទៅកងមួយហ្នឹង?

**ឆ៖** ចាស បានជាខ្ញុំមិនប៉ានដើរ ពីព្រោះវិន័យរបស់គេតឹងណាស់។ វិន័យរបស់គេ១អត់ឲ្យយើងដើរហើរផ្ដេសផ្ដាស ហើយគេអត់ឲ្យដើរទាក់ទងគ្នា។ ចាស គេមិនឲ្យដើរទេ គេវិន័យរបស់គេកាលណាយើងដើរ គេដាក់វិន័យយើងប្រឹបឥឡូវហើយ ឬក៏គេថាយើងសេរី មិនស្ដាប់បង្គាប់របស់គេ គេ

ចាប់យើងយកទៅដាក់សន្តិសុខឯណាឯណីទៀតទៅ យើងខ្លាចអាហ្នឹង យើងអត់ប៊ាន តែគេថាយ៉ាងម៉េច គឺយើងនៅហើយ។ ងូតទឹករួចគឺយើង -- បើថាទៅធ្វើការ១ បើឡើងពីធ្វើការវិញ គឺដេកហើយអត់មាននិយាយឲ្យគ្នាទេ អត់ប៊ានទេ។

[១១:២៦:៤៩]

**ស៖** សូមអរគុណ ខ្ញុំសូមសួរសំណួរចុងក្រោយមួយពាក់ព័ន្ធជាមួយនឹងក្រុមគ្រួសាររបស់លោកស្រីវិញ។ អំឡុងពេលហ្នឹង សួរថាតើលោកស្រីមានអាចទៅ១សួរសុខទុក្ខ -- ឪពុកម្ដាយរបស់លោកស្រីហ្នឹងនៅជុំគ្នាជាមួយ១នឹងលោកស្រី ឬក៏នៅផ្សេងពីលោកស្រី? ហើយតើពេលហ្នឹងលោកស្រីអាចដើរ -- ទៅសួរសុខទុក្ខក្រុមគ្រួសាររបស់លោកស្រីបានដែរឬទេ?

**ឆ៖** ចាស តាំងពីខ្ញុំ តាំងពីឆ្នាំ៧៥ ដែលខ្ញុំចូលមកនៅធ្វើយោធា ក្នុងឆ្នាំ៧៥ នេះឯង រហូត ៧៥, ៧៦, ៧៧ មក ខ្ញុំមិនដែលបានទៅជួបម៉ែឪខ្ញុំទេ។ គេមិនឲ្យទៅ ដូចខ្ញុំនិយាយអ៊ីចឹង គឺថាខ្ញុំ គេមិនឲ្យទៅទេ "មិត្តឯងប្រឹងតែធ្វើការទៅ ទោះមិត្តឯងបង្ហូរទឹកភ្នែកក្លាយជាឈាម ក៏គេមិនឲ្យទៅជួបម៉ែឪស្រុកភូមិដែរ" ចាស រហូតខ្ញុំមិនដែលបានជួប រហូតដល់ពេលរត់ ដែលយួនបុកចូលភ្នំពេញមក រហូតដល់រត់ចូលភ្នំ ឡើងភ្នំមក បានក្រោយឡើងទៀត រំសាយគ្នាអស់ហើយ បានចូលស្រុកភូមិវិញ បានឃើញម៉ែឪ។

[១១:២៧:៥៣]

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណចំពោះការឆ្លើយរបស់លោកស្រីដោយ -- ការឆ្លើយដ៏ក្បោះក្បាយរបស់លោកស្រីហើយនិងសូមអរគុណលោកប្រធាន ខ្ញុំសូមផ្ទេរវេទិកាជូនទៅខាងសហព្រះរាជអាជ្ញា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បន្តទៅនេះ ផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោយចំពោះដើម្បីបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**សៈ** សូមជម្រាបសួរលោកស្រី ខ្ញុំមានសំណួរតែពីរបីប៉ុណ្ណោះ ផ្អែកទៅលើអ្វីដែលសហការីខ្ញុំទើបតែបានសួរលោកស្រីនៅព្រឹកនេះ។ ខ្ញុំសូមត្រឡប់ក្រោយបន្តិច គឺទៅដល់ពេលដែលលោកស្រី ចូលកងពល៤៥០ គឺនៅក្នុងឆ្នាំ<១៩៧៥>។ តើលោកស្រីអាចប្រាប់បានទេ ថាតើក្នុងឆ្នាំ<១៩៧៥> ហ្នឹងនៅថ្ងៃខែណាដែរ ដែលលោកស្រីចូលកងពល ៤៥០នោះ?

**លោកស្រី គង់ សៀក៖**

**ឆ៖** ខ្ញុំសូមជម្រាបប្រាប់មិនបានទេ ថ្ងៃខែ ខ្ញុំមិនចំណាំទេ ខ្ញុំចំណាំតែឆ្នាំ៧៥ តែខែមិនដឹងខែណា ខ្ញុំអត់ចំណាំបានដែរ។

[១១:២៩:៣៥]

**សៈ** លោកស្រីចាប់ផ្តើមធ្វើការនៅមន្ទីរពេទ្យឫស្សីកែវ ភ្លាមៗក្រោយពេលដែលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ<> អ៊ីចឹងមែនទេ?

**ឆ៖** ចាស ដែលខ្ញុំចូលនៅក្នុងមន្ទីរពេទ្យឫស្សីកែវហ្នឹង គឺខ្មែរក្រហមចូលក្នុងទីក្រុងភ្នំពេញពេញអស់ហើយ គេឲ្យខ្ញុំនៅក្នុងមន្ទីរពេទ្យឫស្សីកែវហ្នឹងឯង គឺពេទ្យកងពល៤៥០។

**សៈ** តើបងស្ងួន ដែលលោកស្រីបាននិយាយ<មុននេះ>ជាប្រធានកងពល៤៥០ នៅពេលនោះ<លោកស្រី>ធ្វើការនៅមន្ទីរពេទ្យឫស្សីកែវ<>មែនទេ?

**ឆ៖** បងស្ងួន ដែលខ្ញុំបាននិយាយប្រាប់ហ្នឹង គឺគាត់អត់មានបានចូលនៅក្នុងមន្ទីរពេទ្យឫស្សីកែវទេ តែគាត់គ្រាន់តែក្តាប់ពីលើ ប៉ុន្តែមានអ្នកប្រធានដែលក្តាប់នៅមន្ទីរពេទ្យឫស្សីកែវហ្នឹងឯង គឺមានប្រធានដោយឡែកពីគាត់ទៀត ហើយគាត់នៅខាងនោះឯង។

**សៈ** តើលោកស្រីអាចប្រាប់ប្រធានមន្ទីរពេទ្យនោះ ឈ្មោះអីបានទេ?

**ឆ៖** ចាស ប្រធានមន្ទីរពេទ្យនៅក្នុងពេទ្យឫស្សីកែវហ្នឹងឯង គឺឈ្មោះ ខុម មួយគឺស្រី។ មួយទៀត គឺឈ្មោះ ពាន់។ ពាន់ ហ្នឹងគឺប្រុស។ ហើយមួយទៀត គឺឈ្មោះ វុធ។ គាត់ក្តាប់នៅក្នុងមន្ទីរពេទ្យហ្នឹង។

[១១:៣១:៣៣]

**សៈ** តើលោកស្រីអាចជម្រាបបានទេថា តើមានអ្វីកើតឡើង ចំពោះ បងស្ងួន នោះ?

**ឆ៖** ចំពោះកងពល បងស្ងួន ហ្នឹង ខ្ញុំ ក៏ខ្ញុំនៅឆ្ងាយពីគាត់ដែរ។ ខ្ញុំបែកពីគាត់ហើយ តែខ្ញុំដឹងគ្រាន់តែដឹងគាត់ថា គាត់ជាប្រធានកងពល គាត់ប្រធានកងពល៤៥០ ហ្នឹងឯង។ ហើយដល់ពេលក្រោយ

ឡើងមក មិនដឹងជាគេយកទៅណាយកទៅណី ខ្ញុំអត់ដឹងទេ។

**ស៖** កន្លងមកលោកស្រីបាននិយាយអំពីការ<>ប្រជុំប្រធានកងវរសេនាធំនៅក្នុងកងពល៤៥០។ ដូច្នេះ ខ្ញុំចង់ដឹងថា តើការប្រជុំមេកងវរ<សេនាធំ>ហ្នឹងគេធ្វើឡើងនៅពេលណាដែរ?

**ឆ៖** ប្រជុំកងធំ ប្រជុំកងពល ខ្ញុំមិនដែលប្រជុំផង។

**ស៖** ប៉ុន្តែ តើលោកស្រីមានបានដឹងអំពីកិច្ចប្រជុំរបស់មេបញ្ជាការកងវរសេនាធំដែលលោកស្រីបាននិយាយនៅព្រឹកមិញហ្នឹង លោកស្រីមានដឹងពីការប្រជុំហ្នឹងទេ?

**ឆ៖** អារឿងប្រជុំកងធំ កងវរៈ ខ្ញុំដែលគេបញ្ជូនមកអូរបែកក្អម ដូចខ្ញុំបាននិយាយហ្នឹង មកអូរបែកក្អម ដែលគាត់បានលើកឡើងប្រជុំខ្ញុំនោះឯង ដូចខ្ញុំប្រាប់ថា គេឲ្យខ្ញុំខំធ្វើការនោះឯង។ ឲ្យខំធ្វើការទៅ ពីព្រោះកងពលមិត្តឯងគេចាប់យកទៅអស់ហើយ។ ខ្ញុំសូមបញ្ជាក់ថា គាត់ប្រជុំខ្ញុំដែលមកអូរបែកក្អមហ្នឹងឯងគាត់ថា កងពលមិត្តឯងគេចាប់យកទៅអស់ហើយ។ ដូច្នេះ មិត្តឯងរាល់គ្នានេះឯង ដែលខ្ញុំយកមកនេះអី មិត្តឯងជាប់ឥទ្ធិពល ព្រោះអីដើមឈើ ដូចខ្ញុំថាអ៊ីចឹង "ដើមឈើកាលណាតែអាធំវាបាក់មកហើយ គឺវាសង្កត់អាតូចហើយ។ ដូច្នេះ មិត្តប្រឹងប្រែងខំធ្វើការទៅ មិនបាច់សតិអារម្មណ៍អីទៀតទេ"។ គេគ្រាន់តែប្រាប់ប៉ុណ្ណឹង គេលើកអង្គប្រជុំនោះ។

**ស៖** តើការប្រជុំដែលគេនិយាយប្រាប់លោកស្រីអម្បាញ់មិញអំពីដើមឈើហ្នឹង <>គេធ្វើឡើង<>នៅក្នុងថ្ងៃខែឆ្នាំណាដែរ?

[១១:៣៤:០៦]

**ឆ៖** ចាស ក្នុងឆ្នាំខែថ្ងៃហ្នឹង ខ្ញុំអត់ដឹងទេ ប៉ុន្តែគេប្រជុំហ្នឹង ដែលគេ -- ដែលខ្ញុំមកនៅហ្នឹងអូរបែកក្អមហ្នឹងគឺឆ្នាំ៧៧ ហើយ។

**ស៖** តើ<ថ្នាក់ដឹកនាំ>ដែលគេនិយាយ<ថាត្រូវចាប់នោះគឺ>បងស្ងួង ហ្នឹងមែនទេ?

**ឆ៖** មេហ្នឹង គាត់មិនមែនអ្នកចាប់ទេ។ គាត់ហ្នឹង គាត់ឈ្មោះ បងវីន ហ្នឹងឯង ពួកគាត់គណៈវរៈខ្ញុំ ភូមិភាគនិរតី។

**ស៖** <លោក>ស្រីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង គឺយើងមានឯកសារ <E3/1892>, <ERNជាភាសា>ខ្មែរមានលេខ 00012693, អង់គ្លេសមានលេខ 00769596, បារាំងមានលេខ <00763449>។ គឺជាចម្លើយសារភាពមន្ទីរស-២១។ <ចំណងជើង>ទំព័រដើមដែល

ខ្ញុំទើបតែនិយាយយោងនោះ គឺ<"ចម្លើយសារភាពមន្ទីរស-២១ របស់ ជា ណន ហៅ សួង ហើយ ចម្លើយសារភាពហ្នឹង ត្រូវបានគាត់<>សរសេរដោយ<>ផ្ទាល់មុនពេលដែល<>គេធ្វើទារុណកម្ម។" ដូច្នេះតាមដែលលោកស្រីដឹងហ្នឹង ថាតើ ជា ណន ហៅ សួង ហ្នឹងគឺជាបងស្លួងដែលលោកស្រីទើបតែនិយាយមុនហ្នឹងមែនទេ?

**ឆ៖** គឺបងស្លួងហ្នឹង គឺខ្ញុំ -- អារឿងជាប់គុក ខ្ញុំអត់ដឹងទេ ដឹងគាត់ជាប់គុកដែលគេយកទៅគាត់អី ក៏ខ្ញុំអត់ដឹងទេ ខ្ញុំដឹងពីប្រធានខ្ញុំដែលខ្ញុំមកនៅឯបែកក្អម គាត់និយាយប្រាប់ខ្ញុំប៉ុណ្ណឹង។

**ស៖** តើលោកស្រីដឹងទេ ហេតុអ្វីបានជាគេផ្ទេរ<លោកស្រី>ពីមន្ទីរពេទ្យឫស្សីកែវទៅអូរបែកក្អមវិញ?

**ឆ៖** គេផ្ទេរពីឫស្សីកែវមកអូរបែកក្អមវិញពីព្រោះ ខ្ញុំដូចខ្ញុំថាអីចឹង ដូចខ្ញុំថាកងពលគេចាប់យកទៅអស់ហើយ គេចាប់ខ្ញុំហ្នឹងគឺជាប់និន្នាការ គេយកមកឲ្យធ្វើការ គេចម្រាញ់នៅកន្លែងហ្នឹងឯង។

[១១:៣៧:៥០]

**ស៖** តើលោកស្រីគិតថាការដែលគេផ្លាស់លោកស្រីមកអូរបែកក្អមហ្នឹង គឺជាការដាក់ទណ្ឌកម្ម<>ដល់លោកស្រីមែនទេ?

**ឆ៖** ចាស គេផ្លាស់ខ្ញុំមកពីកងពលហ្នឹង ពេលគេយកមកដល់អូរបែកក្អមហ្នឹង គឺគេពិន័យហើយ គេពិន័យឲ្យខ្ញុំធ្វើការៗហួសពីកម្លាំងកាយចិត្ត។ គេឲ្យខ្ញុំធ្វើហ្នឹងគឺគេឲ្យធ្វើស្រែទាំងថ្ងៃ ទាំងយប់ ហើយគេឲ្យហូបបាយក៏មិនឆ្អែត គេឲ្យខ្ញុំហូបបាយឈរ ហើយហូបមិនឆ្អែតហើយ គេឲ្យហូបឈរទៀត ហើយគេឲ្យធ្វើការយប់ហើយ គេឲ្យធ្វើថ្ងៃទៀត ហើយគេឲ្យចាំកណ្តុរ គេឲ្យដេកតាមភ្លឺស្រែទេ។

**ស៖** នៅក្នុងព័ត៌មានបន្ថែមរបស់លោកស្រីៗគឺ <D22/2509A ERNជាភាសា>អង់គ្លេសមានលេខ 01069308, បារាំងមានលេខ 00587137, ខ្មែរមានលេខ 00587138។ លោកស្រីបាននិយាយថា គេបញ្ជូនលោកស្រីទៅព្រលានយន្តហោះ មកពីអូរបែកក្អម ព្រោះថា "<>ព្រោះខ្ញុំជាប់និន្នាការយោធាកងពល៤៥០ដែលត្រូវបានចាប់ខ្លួនទៅឃុំនៅទួលស្លែង"។ ដូច្នេះ ខ្ញុំចង់សួរលោកស្រីថា <ការ>ដែលគេបញ្ជូនលោកស្រីទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង ព្រោះតែលោកស្រីជាប់និន្នាការជាមួយកងពល៤៥០ ដែលត្រូវបានគេចាប់ខ្លួន<នោះ> តើអីចឹងមែនទេ?

**ឆ៖** ចាស ដែលគេបានបញ្ជូនខ្ញុំមកអូរបែកក្អមហ្នឹង ព្រោះបានខ្ញុំជាប់និន្នាការនៅកងពល៤៥០ហ្នឹង។ បានគេចាប់ខ្ញុំមកធ្វើការលត់ដំនៅក្នុងអូរបែកក្អមហ្នឹង នៅព្រលានយន្តហោះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:៤០:២៣]

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំនៅសល់សំណួរពីរបីទៀតដើម្បីសួរលោកស្រី។ នៅក្នុងព័ត៌មានបន្ថែមគឺ <D22/2509A> លោកស្រីនិយាយថា លោកស្រីធ្វើការនៅព្រលានយន្តហោះ" "ប្រហែលជាកន្លះឆ្នាំមុនពេលគេបញ្ជូនត្រឡប់មកអូរបែកក្អមវិញ"។ តើវាជាការត្រឹមត្រូវដែរឬទេ ដែលថាលោកស្រីធ្វើការនៅព្រលានយន្តប្រហែលជា៦ខែ មុនពេលគេបញ្ជូនត្រឡប់មកអូរបែកក្អមវិញ?

**ឆ៖** ចាស ខ្ញុំបានថាអ៊ីចឹងមែន ព្រោះខ្ញុំទៅព្រលានយន្តហោះបាន៦ខែ គេបញ្ជូនខ្ញុំមកនៅអូរបែកក្អមវិញ។

**ស៖** ហើយការងារកន្លងមក ដែលលោកស្រីបានរៀបរាប់ថា លោកស្រីធ្វើការនៅព្រលានយន្តហោះហ្នឹង តើការងារដែលលោកស្រីធ្វើនៅព្រលានយន្តហោះជាការងារដែលលោកស្រីជ្រើសរើស ឬក៏គេបញ្ជា<>លោកស្រីឲ្យធ្វើការ?

**ឆ៖** ចាស ខ្ញុំអត់មានហ៊ានជ្រើសរើសយកខ្លួនឯងទេ។ គឺការងារនេះសុទ្ធតែគេបញ្ជា គេបញ្ជាយើងទាំងអស់។

**ស៖** តើលោកស្រីអាចប្រមាណមើល ថាតើមានមនុស្សប៉ុន្មាននាក់ដែរធ្វើការនៅការដ្ឋានព្រលានយន្តហោះ?

**ឆ៖** ចាស តាមខ្ញុំចូលទៅធ្វើនៅក្នុងព្រលានយន្តហោះហ្នឹង ព្រលានយន្តហោះកំពង់ឆ្នាំង គឺធំណាស់ ហើយតែបើចំនួនមនុស្សវិញគឺច្រើនណាស់ មិនមែនរយនាក់ទេ គឺពាន់នាក់។ ព្រលានយន្តហោះហ្នឹងច្រើន ទាំងយុវជន ទាំងនារី គឺច្រើនពេញព្រលានហ្នឹង។

[១១:៤៣:៥៤]

**ស៖** <បើតាមលោកស្រីដឹង> តើ<ពលករ>ទាំងអស់ដែលធ្វើការនៅព្រលានយន្តហោះហ្នឹងជាមនុស្សមកពីកងពល៤៥០ ឬក៏ជាមនុស្សមកពីកងពលផ្សេង<ផងដែរ>?

**ឆ៖** ចាស កងពលដែល -- អ្នកដែលធ្វើនៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង គឺមិនមែនជាកងពល មួយកងពលទេ គឺច្រើនកងពលណាស់ ទៅចូលរួមគ្នានៅកន្លែងហ្នឹងឯងនោះ។ ទាំងកងពល ៤៥០ ទាំងកងពលឯណាឯណីទៀត គឺខ្ញុំមិនអាចបានស្គាល់កងពលគេទេ គឺច្រើនចូលរួមគ្នានៅកន្លែងហ្នឹង។ គេយកទៅជុំគ្នាកន្លែងហ្នឹង។

**លោក ចូសេហ្វ អេនគ្រូ ប៊ីយលី៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអរគុណ<លោកស្រី>ដើមបណ្ដឹងរដ្ឋប្បវេណី។

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ចប់ ដោយសារខ្ញុំអស់ម៉ោង។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ បាទឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលតទៅ រហូតដល់ម៉ោងដប់ -- រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និង អ្នកជំនាញដល់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ ឈប់នៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ. មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោយសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៤៤ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុនផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី អង្គជំនុំជម្រះប្រគល់វេទិកាជូនទៅចៅក្រម ដើម្បីតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញលោកចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ខ្ញុំមានសំណួរខ្លីៗបន្តជូនលោកសាក្សី ជូនសាក្សី។ ដើមបណ្ដឹងបានបញ្ជាក់ថាឃើញ<ពល

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ករ> ឬក៏អ្នកធ្វើការពីរនាក់ត្រូវបានគេឆក់ខ្សែភ្លើង។ តើអាចប្រាប់តុលាការបានទេថា លោកស្រីបានឃើញអ្វីខ្លះដោយផ្ទាល់ភ្នែកនោះ?

តើលោកស្រីស្ដាប់សំណួរបានទេ មិនច្បាស់ <>ចង់ឲ្យខ្ញុំសួរម្ដងទៀតឬទេ?

**ប្រធានអង្គជំនុំ៖**

លោកស្រីចៅក្រម សូមតាំងសំណួរជាថ្មីម្ដងទៀត!

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** តើពិតដែរឬទេ <ពេល>ព្រឹកមិញនេះ (សូមទោស)។ តើលោកស្រីឮខ្ញុំទេ? <> ខ្ញុំមិនបានឮការបកប្រែទេ<។> តើដើមបណ្ដឹងរដ្ឋប្បវេណី<>ឮខ្ញុំ<ហើយមែន>ទេ?

ព្រឹកមិញនេះលោកស្រីបានបញ្ជាក់ថា លោកស្រីបានឃើញមនុស្សពីរនាក់ ដែលត្រូវគេឆក់ខ្សែភ្លើង។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[១៣:៣៦:៣៣]

**លោកស្រី គង់ សៀក៖**

**ឆ៖** ចាស ខ្ញុំបានឃើញពិតមែន។

**ស៖** សូមលោកស្រីពន្យល់តុលាការ ថាលោកស្រីបានឃើញអ្វីខ្លះដែលជាក់លាក់? តើអ្នកណាធ្វើអ្វីនៅក្នុងហេតុការណ៍នោះ?

**ឆ៖** ចាស ក្នុងហេតុការណ៍នោះគឺខ្ញុំដូចបានជម្រាបព្រឹកមិញ ខ្ញុំថាខ្ញុំមកពីការដ្ឋានជីកប្រឡាយវិញ ខ្ញុំមកដល់មន្ទីរ ខ្ញុំនាំគ្នា មិត្តខ្ញុំទៅរៀបបាយ ទៅតម្រៀបជួរទៅហូបបាយ។ ដល់ពេលទៅហូបបាយបានខ្ញុំដើរទៅឃើញគេធ្វើសកម្មភាពនៅក្រោមដើមស្វាយអីពីរនាក់ តែមិត្តខ្ញុំគាត់និយាយប្រាប់ខ្ញុំថា "នំ! មិត្តឯងមើលគេឆក់ខ្សែភ្លើងមិត្តនោះទៀតហើយ" អ៊ីចឹងប៉ុណ្ណឹងទៅ នាំគ្នាដើរទៅហូបបាយហួសទៅ។ តែប៉ុណ្ណឹងឯង។

**ស៖** តើលោកស្រីអាចពន្យល់ប្រាប់តុលាការបានទេថា តើគេឆក់ខ្សែភ្លើង<>ដោយរបៀបណា?

[១៣:៣៧:៤៤]

**ឆ៖** ចាស ខ្ញុំរឿងឧបករណ៍ប្រើប្រាស់ឆក់ហ្នឹងឯង ក៏ខ្ញុំមិនបានឃើញដែរ ប៉ុន្តែមិត្តខ្ញុំគ្រាន់តែមិត្តយើងដើរជាមួយគ្នា គ្រាន់តែគាត់កេះប្រាប់ខ្ញុំ ក៏ខ្ញុំបានអើតមើលទៅ ក៏ឃើញគេឈរពីរនាក់នៅហ្នឹង

ក្រោមដើមស្វាយហ្នឹងឯង មួយឈរមួយអង្គុយ។ តែមិត្តបានគ្រាន់តែប្រាប់ខ្ញុំថា "នុ៎! គេគេឆក់ខ្សែភ្លើង" ខ្ញុំគ្រាន់តែបានមើលហើយ ក៏ខ្ញុំមិនបានឧបករណ៍ប្រើប្រាស់ម៉េច ធ្វើយ៉ាងណាខ្ញុំអត់ដឹងទេ ដើរហួសបាត់ហើយ។

**ស៖** តើអាចប្រាប់ខ្ញុំបានទេ តើលោកស្រីនៅចម្ងាយប៉ុន្មានពីកន្លែងដែលគេឆក់ខ្សែភ្លើង<> នោះ? ហើយដែលលោកស្រីបានមើលឃើញ នៅពេលដែលលោកស្រីឃើញ តើលោកស្រីនៅចម្ងាយប៉ុន្មានពីកន្លែងនោះ ដោយប៉ាន់ប្រមាណមើល តើប្រហែលចម្ងាយប៉ុន្មាន?

**ឆ៖** ខ្ញុំប៉ាន់ចម្ងាយដែលពីផ្លូវខ្ញុំដើរ ហើយនិងកន្លែងគេធ្វើបាបមនុស្សហ្នឹងឯង ប្រហែលពីប្រហែលតែ១០ម៉ែត្រទេ។

**ស៖** តើមានអ្វីនៅបាំង មានដើមឈើ ឬក៏មានព្រៃគុម្ពោតដែលបាំងមិនឲ្យឃើញច្បាស់ទេ? ឬក៏លោកស្រីបានមើលទៅឃើញច្បាស់ ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ថ្ងៃ ពេលនោះខ្ញុំដើរជាមួយមិត្តមែន គឺគេ ដែលគេធ្វើមនុស្សហ្នឹងឯង គឺមានដើមស្វាយមួយបាំង។

[១៣:៣៩:៣៤]

**ស៖** តើលោកស្រីពិតជាបានឃើញសកម្មភាព<>អ្វីខ្លះនៅពេលនោះ?

**ឆ៖** ចាស ដូចខ្ញុំបាននិយាយប្រាប់ហើយ ខ្ញុំថាខ្ញុំឃើញតែប៉ុណ្ណឹងឯង ដែលខ្ញុំដើរទៅស៊ីបាយឃើញគេឈរមួយ អង្គុយមួយ ហើយមិត្តខ្ញុំបានប្រាប់ថានោះគេឆក់ខ្សែភ្លើងទៀតហើយ។ ប៉ុណ្ណឹងឯង ខ្ញុំអត់បានមើលអីទៀតទេ ខ្ញុំមិនសូវហ៊ានមើលផង ខ្ញុំដើរហួសទៅបាត់ហើយ។

**ស៖** តើខ្ញុំយល់ច្បាស់ដែរឬទេថា<មនុស្ស>ហ្នឹង គឺគេដាក់ឲ្យដេក<>នៅក្រោមដើមស្វាយ<>?

**ឆ៖** ចាស ពេលហ្នឹងដែលខ្ញុំដើរទៅ គឺឃើញគាត់អង្គុយ ដូចខ្ញុំថាអ៊ីចឹង អង្គុយមួយ ឈរមួយ។

**ស៖** តើអ្នកណាជាអ្នកឆក់ខ្សែភ្លើងទៅលើជនរងគ្រោះនោះ?

**ឆ៖** ចាស ឈ្មោះខ្ញុំអត់ស្គាល់ទេ គឺដែលយុទ្ធជនទាំងពីរហ្នឹងឯង គឺជាអង្គភាពខុសគ្នា។

[១៣:៤១:១១]

**ស៖** តើលោកស្រីបានឮអ្នកណាម្នាក់ស្រែក ឬក៏យំអ្វីដែរឬទេ? ឬក៏គ្រាន់តែហេតុការណ៍ហ្នឹងមើលទៅឃើញស្ងាត់ជាធម្មតា ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ខ្ញុំដើរទៅហ្នឹង គឺអត់មានអ្នកណាយំស្រែកអីទេ ឃើញឈរតែពីរនាក់ គឺស្ងាត់នៅ

កន្លែងតែពីរនាក់ហ្នឹងឯង។

**ស៖** ដើម្បីឲ្យខ្ញុំយល់ស្ថានភាពនេះ តើមិត្តរបស់លោកស្រី<កំពុងប្រាប់នោះ លោកស្រីក៏មើលទៅ>ឃើញមនុស្សពីរនាក់<ទើបត្រូវគេឆក់ខ្សែភ្លើង ឬឆក់ខ្សែភ្លើងរួចហើយ។ តើអ៊ីចឹងមែនទេ>?

**ឆ៖** ចាស ដល់ពេលហ្នឹងខ្ញុំដើរទៅ ទៅហូបបាយទាំងអស់គ្នា តម្រៀបជួរទាំងអស់គ្នាហ្នឹងឯង គេបានកេះស្រែកប្រាប់ខ្ញុំ ខ្ញុំក្រឡេកមើលភ្លាមទៅ ឃើញដូចនៅក្រោមដើមស្វាយតែពីរនាក់ហ្នឹងឯង។គឺអត់មានឃើញអីទៀតទេ ឃើញតែប៉ុណ្ណឹង។

**ស៖** ឥឡូវសំណួរខ្ញុំចុងក្រោយ<។ ពី>ចម្ងាយ១០ម៉ែត្រ<>តើមនុស្ស<ដែលលោកស្រីឃើញនោះ>ស្លាប់<ហើយ> ឬ<នៅ>រស់<ទេ>?

**ឆ៖** ចាស មនុស្សដែលអង្គុយ ដែលមួយឈរ ហើយមួយអង្គុយហ្នឹងឯង គឺគាត់អត់ទាន់ស្លាប់ទេ គាត់នៅអង្គុយសង្រួមនៅហ្នឹងឯង។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទផ្សេង ប៉ុន្តែសំណួរខ្លីទេ លោកស្រីបានបញ្ជាក់ថា ការងារមួយក្នុងចំណោមការងារផ្សេងទៀតនៅការដ្ឋាននោះ គឺត្រូវ<លី>បាវស៊ីម៉ង់ត៍ ៥០គីឡូក្រាម តើអ៊ីចឹងដែរឬទេ?

**ឆ៖** ចាស ខ្ញុំបានគេឲ្យទៅសែងស៊ីម៉ង់ត៍នៅរមាស មួយបាវ៥០គីឡូ។

[១៣:៤៣:៤៩]

**ស៖** តើលោកស្រីចាំទេ នៅពេលនោះលោកស្រីមានទម្ងន់ប៉ុន្មានគីឡូក្រាម<ដែរ>?

**ឆ៖** ខ្ញុំនៅពេលនោះ ខ្ញុំមិនដែល មិនបានមានគីឡូ មានអីថ្លឹងខ្លួនឯងទេ អត់ដែលដឹងផង មិនដឹងប៉ុន្មានគីឡូៗ អត់ដឹងទេ។

**ស៖** តើលោកស្រីដឹងទេ សព្វថ្ងៃនេះទម្ងន់ប៉ុន្មានគីឡូ ខ្លួនលោកស្រី?

**ឆ៖** ខ្លួនខ្ញុំ រាល់ថ្ងៃខ្ញុំបានឡើងទៅ៦០គីឡូ។

**ស៖** <កាលពីគេប្រើឲ្យលីស៊ីម៉ង់ត៍នោះ>តើ<>លោកស្រីស្រាលជាង<> ឬក៏ទម្ងន់ធ្ងន់ជាង<សព្វថ្ងៃនេះ>?

**ឆ៖** កាលដែលខ្ញុំ គេឲ្យទៅលីស៊ីម៉ង់ត៍ ខ្លួនខ្ញុំតូចទេ ខ្លួនខ្ញុំមិនធាត់ដូចសព្វថ្ងៃនេះ ដូចចាស់សព្វថ្ងៃគឺធាត់ អង្កាល់នៅពីក្មេង គឺស្គម ហើយត្រូវនឹងអាហារហូបមិនគ្រប់គ្រាន់ទៀត គឺស្គមមានទី-- ដូចថាស្គមណាស់ មិនអាចនឹងយើងថា សព្វថ្ងៃតស៊ូនឹងការងារហ្នឹងមិនបានទេ បើតាមយើងស្គម ប៉ុន្តែឥឡូវ

សម័យនោះ បើយើងមិនធ្វើ គឺងាប់។

**ស៖** តើលោកស្រីអាចប្រាប់តុលាការបានទេ តើ<>គេឲ្យ<>លីបាវស៊ីម៉ង់ត៍<ដែលមួយបាវៗ នោះមានទម្ងន់ធ្ងន់ជាងខ្លួនលោកស្រីផងនោះ មួយថ្ងៃ>រយៈពេលប៉ុន្មានម៉ោង? <>

**ឆ៖** ចាស អង្កាល់គេឲ្យពួកកងខ្ញុំដែលទៅលីស៊ីម៉ង់ត៍ហ្នឹងឯង គេអត់មានឲ្យសែងពីរនាក់ទេ គេឲ្យមួយបាវគឺម្នាក់ឯងៗតែម្តង ចាស។ បើខ្លួនខ្ញុំផ្ទាល់ ដូចខ្ញុំថាព្រឹកមិញហើយ ខ្ញុំថាដាក់ទៅ គឺខ្ញុំដើរទា ពេលខ្ញុំដើរទាទៅ មានគេទិតៀនឲ្យខ្ញុំ គេថា “យី! មិត្តឯង អីក៏ខ្សោយម្ល៉េះ! គ្រាន់តែឲ្យលីបាវស៊ីម៉ង់ត៍ ប៉ុណ្ណឹងឯង មិត្តឯងធ្វើដើររខេករខាកទៅហើយ។ បើខ្ញុំ ដូចថាបើរខេករខាកម៉េច បើខ្ញុំមិនដែលលីផង។ ទើបមកសាកហ្នឹងឯង ឲ្យខ្ញុំធ្វើម៉េចទៅ!”។ អ៊ីចឹង ខ្ញុំបានតថ្លៃនឹងគេប៉ុណ្ណឹងឯង ខ្ញុំអត់ហ៊ានតថ្លៃទៅទៀត ទេចាស។

**ស៖** ហើយតើការងារ<លីស៊ីម៉ង់ត៍>ហ្នឹង ធ្វើ<ប្រាំពីរ ឬប្រាំបី>ម៉ោង ក្នុងមួយថ្ងៃ<មែនដែរឬ ទេ>?

**ឆ៖** ចាស ដែលធ្វើការហ្នឹង ស៊ីម៉ង់ត៍ ដូចខ្ញុំថាហើយថាស៊ីម៉ង់ត៍ហ្នឹង មកដល់មួយខ្សែរថភ្លើង ហ្នឹងឯង វាមាន៥០បារ៉ុង ហើយគេឲ្យខ្ញុំលីចាប់ពីម៉ោងប្រាំព្រឹក រហូតដល់ថ្ងៃត្រង់ម៉ោងដប់មួយ បានឲ្យ ឈប់។ ចាស ហូបបាយរួចម៉ោងមួយគេឲ្យចូលទៀត រហូតដល់ម៉ោងប្រាំល្ងាច បានគេឲ្យឈប់។ ម្ល៉ៃៗ គឺអត់មានឲ្យឈប់ទេ គឺឈប់ពីពេលម៉ោងដប់មួយហូបបាយទេ ហូបបាយហើយ ឡើងដល់ម៉ោង វាល់ ល្ងាចទៀត។

[១៣:៤៧:០៥]

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទមួយចំនួនទៀត ជាសំណួរខ្លីទេ។ លោកស្រីបានបញ្ជាក់ថា <>មានការប្រជុំនៅថ្នាក់<>កងវរសេនាធំ <ហើយ>លោកស្រីបានចូលរួម<ក្នុងកិច្ចប្រជុំនោះផងដែរ តើត្រឹមត្រូវទេ?>។

**ឆ៖** ប្រជុំ នៅប្រជុំនៅកងវរសេនាធំហ្នឹងឯង គឺខ្ញុំនិយាយព្រឹកមិញហើយ ខ្ញុំថា គេដកខ្ញុំចេញ មក ដកខ្ញុំចេញពីកងពលមក គឺឲ្យខ្ញុំមកនៅអង្គរក្សអូរបែកក្អមហ្នឹងឯង អង្គរក្ស៧៥។ ចាស គេបាន ប្រជុំប្រាប់ខ្ញុំ ថាពួកខ្ញុំធ្វើការប៉ុណ្ណឹងហ្នឹងហើយ ធ្វើការ ដូចខ្ញុំប្រាប់ហើយថា ខ្ញុំធ្វើការហត់នឿយខ្លាំង ណាស់។ មួយថ្ងៃៗមិនដែលបានឈប់ទេ។ ខ្ញុំហូប -- ក្រោកពីម៉ោងបី ខ្ញុំនិយាយព្រឹកមិញ ក៏ខ្ញុំអត់បាន និយាយដែរ តែប៉ុណ្ណោះ ខ្ញុំសូមនិយាយប្រាប់ចៅក្រមហើយ ក្រោកពីម៉ោងបី គឺគេផ្តុកញ្ចែច្រេច ឲ្យពួកខ្ញុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅតម្រង់ជួរ។ តម្រង់ជួររួចហើយ ម៉ោងបួន ឲ្យខ្ញុំឡើងមកស្រែ។ ឡើងមកស្រែរួចហើយ ម៉ោងដប់មួយ ឲ្យខ្ញុំហូបបាយ ហូបបាយរួចហើយ ដល់ពេលម៉ោងមួយឲ្យខ្ញុំចុះទៅទៀត។ ចុះទៅទៀត ត្រឡប់មកវិញ ម៉ោងប្រាំ ឲ្យខ្ញុំឡើងចុះទៅទៀត នៅចាំកណ្ដុរតាមវាលស្រែ។ ហើយដល់ពេលនោះ គេឡើងមកប្រជុំ គេប្រជុំប្រាប់ខ្ញុំ គេថា "មិត្តឯង កងពលមិត្តឯងក្បត់អស់ហើយ គេចាប់កងពលមិត្តឯងយកទៅអស់ហើយ។ ឥឡូវនេះ មិត្តឯងមកធ្វើការនៅកន្លែងនេះ គឺមិត្តឯងខំប្រឹងប្រែងមែនទែន បើមិត្តឯងមិនប្រឹងប្រែងទេ មិត្តឯងបង្ហូរទឹកភ្នែកក្លាយទៅជាឈាម ក៏មិត្តឯងមិនបានទៅជួបស្រុកភូមិ និងម៉ែឪរបស់មិត្តឯងដែរ"។

[១៣:៤៩:០០]

**ស៖** តើលោកស្រីចាំដែរឬទេ<ថា>គេបានចាក់ខ្សែអាត់អ្វីឲ្យស្ដាប់ដែរឬទេ នៅពេលប្រជុំនោះ?

**ឆ៖** ពេលប្រជុំហ្នឹង គឺអត់មានខ្សែអាត់អីទេ គេគ្រាន់តែប្រជុំ គេនិយាយតែមាត់ហ្នឹងណា។

**ស៖** ដើម្បីឲ្យច្បាស់ ខ្ញុំមិនចង់និយាយថាគេថតខ្សែអាត់អំពីការប្រជុំនោះទេ ខ្ញុំចង់សួរថា តើគេបានចាក់ខ្សែអាត់ថតសំឡេងអ្នកណាឲ្យយើងស្ដាប់នៅក្នុងពេលប្រជុំហ្នឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោកស្រី គង់ សៀក៖**

**ឆ៖** ចាស នៅពេលដែលគេប្រជុំហ្នឹង គឺអត់មានចាក់ខ្សែអាត់ ចាក់អីថតសំឡេងអីទេ។ គឺគេប្រជុំហ្នឹង គឺមិត្តយើងអង្គុយតម្រៀបជួរទាំងអស់គ្នានោះឯងទៅ អង្គុយទៅ គេលើកអង្គប្រជុំទៅ គេឈរគេប្រជុំប្រាប់យើងទៅ។ គេថាដូចខ្ញុំថាអីចឹងឯង។

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ឥឡូវនេះ ខ្ញុំមកដល់សំណួរចុងក្រោយពីរ ឬបី។ តើលោកស្រីអាចប្រាប់ខ្ញុំបានទេថា ហេតុអ្វីបានជាលោកស្រីចូលបម្រើកងទ័ព?

**ឆ៖** អង្កាល់ដែលខ្ញុំបានចូលមកបម្រើកងទ័ពនៅក្នុងឆ្នាំ៧៥ ហ្នឹង គឺអង្កាល់ហ្នឹងខ្ញុំនឹកឃើញថាម៉ែឪខ្ញុំនៅខាងភូមិសហករណ៍ហ្នឹងឯង គឺគាត់លំបាកវេទនាពេកទៅ ចាស គាត់លំបាកវេទនាពេកក៏ខ្ញុំ -- ប្អូនខ្ញុំដែលចូលមកធ្វើទ័ពមុនខ្ញុំនៅមុនខ្ញុំ ដល់ដាច់ភ្នំពេញ៧៥ នេះឯងមកក៏ប្អូនខ្ញុំទៅលេងភូមិ ចាស ដល់ពេលទៅលេងភូមិទៅ ដល់ខ្ញុំនៅការងារខាងក្រោយវាលំបាកណាស់។ លំបាកត្រង់ម៉ែ លំបាកត្រង់ឪ

បងប្អូន មីងមាខ្ញុំទាំងអស់លំបាកនោះ គឺគេបង្អត់បាយ គេមិនឲ្យបាយហូប គេមិនឲ្យអំបិលហូប បាយហូបមិនឆ្អែត រាល់ថ្ងៃម៉ែខ្ញុំធាត់ប៉ុនខ្ញុំ ដល់ពេលធ្វើការព្រលប់ចេញ --អ៊ំនែ! ព្រលឹមចេញ ព្រលប់ចូល ដល់ពេលនេះទៅគាត់ស្គមៗដូចថា នៅទីថា នៅទី ក្បាលដោះគាត់នេះឯង ត្រមែងៗ រាងបែកសាច់ គាត់ស្គមដណ្តប់ឆ្អឹងអស់ទៅ ខ្ញុំនឹកឃើញថា ខ្ញុំមើលទៅនៅសហករណ៍វាមិនបានរស់ទេដឹង ព្រោះខ្ញុំឃើញប្អូនខ្ញុំទៅ ក៏ខ្ញុំតាមប្អូនខ្ញុំមកនៅសមរភូមិនៅកង៤៥០ហ្នឹង។

[១៣:៥១:៤៣]

**ស៖** ហើយដើម្បីឲ្យយើងចង់ឲ្យយល់ពីខ្លឹមសារ ហើយយើងចង់ឲ្យបានចម្លើយច្បាស់លាស់នៅពេលនេះ តើបន្ទាប់ពីលោកចូលបម្រើកងទ័ព តើ<លោកស្រីនៅធ្វើយោធារហូតដល់ឆ្នាំ១៩៧៩មែនទេ > ហើយលោកស្រី<មានតួនាទីជាអ្វីដែរ>? <គឺ>ចាប់ផ្តើមពីឆ្នាំ១៩៧៥<>មានតំណែងអ្វី<ហើយតមកទៀតមាននាទីជាអ្វី>?

**ឆ៖** ចាស ដែលខ្ញុំបានមកបម្រើនៅក្នុងកងទ័ព៤៥០ហ្នឹងឯង ខ្ញុំមកដល់ទីកន្លែងរបស់ខ្ញុំគឺគេឲ្យខ្ញុំមកនៅកន្លែងមន្ទីរកងពល៤៥០ហ្នឹង។ ក្រោយពីកងពល៤៥០ហ្នឹងឯងបាត់មេធំៗអស់ទៅ ខ្ញុំមិនដឹងគាត់ទៅណា អង្កាល់ខ្ញុំនៅកន្លែងមន្ទីរពេទ្យកងពលហ្នឹងឯង ខ្ញុំនៅឃើញគាត់នៅ ដល់ពេលក្រោយឡើងទៀតមិនដឹងឆ្នាំណា ខ្ញុំមិនបានចាំឆ្នាំទេ ប៉ុន្តែខ្ញុំនៅយូរទៅស្រាប់តែកងពលហ្នឹងក៏បាត់ កង ដែលប្រធានខ្ញុំប្រធានពេទ្យ ប្រធានអីហ្នឹងក៏បាត់អស់រលីង។ បាត់អស់រលីងទៅ នៅតែយុទ្ធជនធម្មតានៅក្នុងពេទ្យហ្នឹងឯង ក៏អ្នកជំងឺក៏មិនដឹងទៅឯណាមកឯណាក៏បាត់អស់ទៅ ក៏ខ្ញុំនៅប៉ុន្មានកង មួយកងតូចហ្នឹងឯង ក្នុងពេទ្យហ្នឹងឯង គេបញ្ជូនខ្ញុំមកឲ្យនៅបឹងបាយ៉ាបធ្វើស្រែ។ ចាស ដល់ពេលនៅក្នុងបឹងបាយ៉ាបធ្វើស្រែហ្នឹងឯង ធ្វើស្រែទៅ ស្រាប់តែ គេថា ហ៏! ដកពួកខ្ញុំនារី៥៣នេះឯង មកនៅអូរបែកក្អមចាស។ មកនៅអូរបែកក្អមនេះឯងគេបញ្ចូលនៅអង្គភាព១៧៥១ គឺកាត់ដេរ។ ហ្នឹងបានខ្ញុំមកនៅ មកធ្វើទុក្ខ ធ្វើទារុណកម្មខ្ញុំ គេឲ្យហូបបាយក៏មិនឆ្អែត គេឲ្យធ្វើការទាំងយប់ ទាំងថ្ងៃហ្នឹង ដូចខ្ញុំបានជម្រាបប្រាប់ហើយប៉ុណ្ណឹងឯង។ ហើយរហូតដល់ខ្ញុំនៅហ្នឹងឯងនោះហើយ គេ -- បានគេ -- ឆ្នាំ៧៧ បានគេបញ្ជូនខ្ញុំទៅកំពង់ឆ្នាំង។ បញ្ជូនខ្ញុំទៅនៅកំពង់ឆ្នាំងបាន ៦ខែបានគេបញ្ជូនខ្ញុំត្រឡប់មកនៅអូរបែកក្អមវិញ។ ដល់ត្រឡប់មកនៅអូរបែកក្អមវិញបានប៉ុណ្ណឹងឯង បានប្រហែល ២ខែ ៣ខែហ្នឹង ខ្ញុំគេឲ្យខ្ញុំទៅ -- ឲ្យខ្ញុំមកនៅកំពង់ត្រឡាចលើ កំពង់ឆ្នាំងដែរ កំពង់ត្រឡាចលើ ខេត្តកំពង់ឆ្នាំងហ្នឹងដែរ។ ហើយគេឲ្យខ្ញុំមកលីគ្រាប់និងកាំភ្លើងដាក់ពីរទេះភ្លើងមកនឹងឃ្លាំង ដាក់នឹងឃ្លាំងគេហ្នឹងឯង។ ចាស ដល់ពេលខ្ញុំលីដាក់ទៅ -- ខ្ញុំ

ទៅនឹងបាន ៥ថ្ងៃ ពេលបាន ៥ថ្ងៃ ក៏ស្រាប់តែឃើញកងទ័ពវៀតណាមចូលមកភ្នំពេញថ្ងៃរសៀលម៉ោងបី ស្រាប់តែឃើញរថក្រោះចេញពីភ្នំពេញ បើកទៅតាមផ្លូវជាតិលេខ៥ហ្នឹងឯង ឃើក១ ពេលយប់នេះឯងក៏ស្រាប់តែឮគ្រាប់កាំភ្លើងផ្ទុះ ខ្ញុំក៏ភ័យ ខ្ញុំអត់បាននៅចូលរួមជាមួយពួកមិត្តអស់នោះទេ តែខ្ញុំរត់ចូលព្រៃរហូត។ ចាស រត់ចូលព្រៃចូលភ្នំរហូត ប៉ុណ្ណឹងឯង។

[១៣:៥៤:៥៦]

**ចៅក្រម ក្លូឌា ហ្វែនស៍៖**

សូមអរគុណ។ ហើយខ្ញុំបញ្ចប់ការតាំងសំណួររបស់ខ្ញុំពេលនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់ --

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំមានសំណួរតែមួយទេ ដើម្បីសូមបំភ្លឺពីលោកស្រី។ តើលោកស្រីរៀបការក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក្រោយរបបកម្ពុជាប្រជាធិបតេយ្យ<?> ហើយប្ដីរបស់លោកស្រីមានមុខងារអ្វីនៅក្នុងជួរកងទ័ពទេ?

**លោកស្រី គង់ សៀក៖**

**ឆ៖** ចាស កាលសម័យហ្នឹង គឺខ្ញុំអត់ទាន់មានប្ដីទេ។ ដល់តែខ្ញុំរត់មកដល់ស្រុកភូមិខ្ញុំវិញ បានខ្ញុំមានប្ដី។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីដែលដំបូងនេះជូនទៅសហមេធាវីការពារក្ដី នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ <>លោកស្រីអាយុ២៣ឆ្នាំ នៅពេលដែលចូលកងទ័ពបដិវត្តន៍កម្ពុជា តើអ៊ីចឹងត្រូវដែរឬទេ?

[១៣:៥៦:៤១]

**លោកស្រី គង់ សៀក៖**

**ឆ៖** ខ្ញុំមិនបានរាប់រៀប ចំណាំជាឆ្នាំខ្ញុំ គឺកើតនៅ១៩៥២ ហើយដល់ពេលឆ្នាំកំណើតខ្ញុំ មិនដឹងជា២៣ មិនដឹងម្តេប៉ុន្មានដែរ ខ្ញុំមិនបានចាំអាកន្លែងខ្ញុំចូលមកប៉ុន្មាន តែចាំតែឆ្នាំ។

**ស៖** <តាមរយៈពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី>លោកស្រីបាននិយាយអំពីបងប្អូនប្រុសដែលនៅក្នុងកងពល៤៥០<ដែរ> គាត់<ឈ្មោះ>គង់ ខុម។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** នាមត្រកូលគាត់អត់មានឈ្មោះ គង់ ទេ គឺប្អូនប្រុសខ្ញុំហើយ គឺឈ្មោះ ខុម គឺ ម៉ូម ខុម។

**ស៖** តើ<>ប្អូនប្រុសរបស់លោកស្រីនោះ ចូលកងទ័ពដើម្បីវាយប្រយុទ្ធនឹង លន់ នល់ នោះ នៅពេលណា?

**ឆ៖** ខ្ញុំចូលកងទ័ពដែលវាយប្រយុទ្ធនឹង លន់ នល់ នោះ ប្រធានភូមិគេអាចបញ្ជូនមកចាត់តាំងបង្ខំឲ្យមក គឺនៅឆ្នាំ៧៣ រហូតដល់ពេលមកដល់ ៧៤-៧៥ គឺដាច់ភ្នំពេញ គឺប្អូនខ្ញុំមកនៅភ្នំពេញនេះតែម្តង។

**ស៖** តើលោកស្រីដឹងទេ ហេតុអ្វីបានជាប្អូន<ប្រុសរបស់លោក>ស្រីចូលកងទ័ពដើម្បីវាយប្រយុទ្ធនឹង លន់ នល់?

**ឆ៖** រឿងចូលកងទ័ពប្រយុទ្ធនឹង លន់ នល់ ខ្ញុំអត់ដឹងរឿងហេតុអីទេ ប៉ុន្តែបើប្រធានភូមិគេបញ្ជូនមកហើយ។ អង្កាល់ហ្នឹងយើងអត់ហ៊ានទៅទេ យើងអត់ហ៊ានប្រឆាំងនឹងគេទេ គឺត្រូវតែមក។

[១៣:៥៨:៥០]

**ស៖** តើគាត់ជាប្អូនប្រុសតែម្នាក់របស់លោកស្រីដែលគាត់ចូលកងទ័ពបដិវត្តន៍នោះ<មែនទេ>?

**ឆ៖** ប្អូនប្រុសខ្ញុំមានតែម្នាក់ហ្នឹង។

**ស៖** តើប្អូនប្រុសរបស់លោកស្រី គាត់ជួបបញ្ហាអ្វីទេ នៅក្នុងកងពល៤៥០? តើគាត់នៅបន្តជាសមាជិករបស់កងពលហ្នឹងរហូតដល់ឆ្នាំ១៩៧៩ ដែរឬទេ?

**ឆ៖** ប្អូនប្រុសរបស់ខ្ញុំ អង្កាល់ដែលពេលដែលខ្ញុំនៅក្នុងមន្ទីរពេទ្យហ្នឹង គឺប្អូនប្រុសខ្ញុំហ្នឹងឯងគេចាត់តាំងឲ្យគាត់វៃឆ្នាំង តែគាត់អត់មានទាន់ជួបប្រទះគេយកទៅធ្វើបាបឯណាទេ គាត់នៅវៃឆ្នាំងហ្នឹងដល់ពេលក្រោមក ដល់គេចាប់កងពល កងអីទៅណាទៅណីទៅ ក៏ខ្ញុំរត់បែកគ្នាមក។ ប្អូនក៏បែក រត់ដោយប្អូនខ្ញុំ ខ្ញុំក៏រត់ដោយខ្ញុំទៅមិនដឹងទៅណាទៅណីវិញ។

[១៣:៥៩:៥៩]

**ស៖** តើគាត់នៅតែជាសមាជិករបស់កងពល៤៥០ រហូតដល់ឆ្នាំ<១៩៧៩> ដែរឬទេ?

**ឆ៖** ចាស គាត់និយាយម្តងទៀត ខ្ញុំដូចមិនយល់ទេ។

**ស៖** តើប្អូនប្រុសរបស់លោកស្រី ដូចលោកស្រីដែរទេ <គឺ>នៅ<ជាសមាជិក>កងពល ៤៥០ រហូតដល់ឆ្នាំ១៩៧៩ ដែរឬទេ?

**ឆ៖** ហ្នឹងគឺគាត់នៅអត់ដល់ទេ អត់ដល់៧៩ ហ្នឹងអត់ដល់ទេ កាលនៅឆ្នាំ៧៥ ហើយ។ ដល់៧៦ ហ្នឹងឯង ក៏បែកគ្នាអត់រលឹងទៅ ប្អូនទៅដោយប្អូនទៅ មិនដឹងគេទៅខាងណា គេចាត់តាំងទៅខាងណា ខ្ញុំអត់ដឹង។ តែខ្ញុំគេចាត់តាំងមកដោយឡែកមក ក៏មកតែឯងដោយឡែកទៅ អត់មាន១ថា ជួបជុំបងប្អូនទៀតទេ។

**ស៖** តើនៅពេលដែលគាត់ចាកចេញពីកងទ័ពបដិវត្តន៍កម្ពុជា ពីកងពល៤៥០ នៅពេលដែលគាត់ឈប់បម្រើការពីកងទ័ពនោះ?

**ឆ៖** ចាស ដល់ពេលដែលគាត់ឈប់បម្រើពីកងទ័ពហ្នឹង ដល់ពេលខ្ញុំត្រឡប់មកដល់ស្រុកភូមិវិញហើយបានមកជួបប្អូនខ្ញុំនៅក្នុងភូមិវិញ គឺកាលហ្នឹង មិនដឹង ចិតសិបប៉ុន្មានទេ ខ្ញុំរត់មកស្រុកភូមិវិញ គឺ ៧៩ ហើយ ដែលរត់ដល់ភូមិ -- អ៎! ឆ្នាំ៨០ ហើយ ៨០ ខ្ញុំចូលមកដល់ស្រុកភូមិ។

[១៤:០១:៣៧]

**ស៖** តើលោកស្រីដឹងដែរឬទេ តើគាត់បានចាកចេញពីកងពល៤៥០ មុនពេលរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់ទៅឬយ៉ាងណា?

**ឆ៖** កាលហ្នឹងគាត់មិនមែនចេញនេះទេ គាត់ចេញនៅក្នុងកន្លែងគេចាប់រប៉ាត់រប៉ាយនេះឯង គឺបែកគ្នាក្នុងពេលហ្នឹងឯងទៅ រហូត។

**ស៖** ខ្ញុំយល់អំពីចំណុចនេះលោកស្រី។ តើលោកស្រី<ចាំទេ ថា>ធ្វើការនៅមន្ទីរពេទ្យកងពលហ្នឹង អស់រយៈពេលប៉ុន្មានខែដែរ? <>

**ឆ៖** ខ្ញុំនៅធ្វើការនៅមន្ទីរពេទ្យកងពលហ្នឹងឯង គឺខ្ញុំនៅអស់រយៈ១ឆ្នាំ។

**ស៖** តើលោកស្រីចាប់ផ្ដើមធ្វើការនៅមន្ទីរពេទ្យកងពលភ្លាមៗក្រោយពេលដែលលោកស្រីចូលក្នុងកងទ័ពបដិវត្តន៍ឬ?

**ឆ៖** ដែលខ្ញុំចូលនៅមន្ទីរពេទ្យកងពល៤៥០ ហ្នឹងឯង គឺខ្ញុំមកពីក្រោយជាមួយប្អូនខ្ញុំហ្នឹង គឺគេបញ្ចូលនៅក្នុងមន្ទីរពេទ្យកងពលហ្នឹងឯង គឺជាយុទ្ធជនធម្មតា គេឲ្យបម្រើការងារនៅក្នុងហ្នឹងឯង គឺគេឲ្យគេផ្លាស់ឲ្យខ្ញុំ ប៉ះណាគេឲ្យដាំបាយទៅ ប៉ះត្រង់ណាគេ ជាបុគ្គលិករបស់គេ ១ឲ្យដើរចាក់យុទ្ធជនដែលមានជំងឺនៅក្នុងហ្នឹងឯង ដែលឈឺនៅក្នុងមន្ទីរពេទ្យហ្នឹងឯង។

[១៤:០៣:៤០]

**ស៖** តើលោកស្រីចាំអំពីកងអនុសេនា -- កងវរសេនាតូច៤៥៣ ដែរឬទេ?

**ឆ៖** ចាៗម៉េចខ្ញុំ--

**ស៖** តើលោកស្រី<ជាសមាជិក>កងវរសេនាតូច៤៥៣<ក្នុងកងពល៤៥០>មែនទេ?

**ឆ៖** គឺខ្ញុំ គឺកាលហ្នឹង គឺខ្ញុំស្ថិតនៅក្នុងកងពល ៤៥០។ ចាស ខ្ញុំស្ថិតនៅក្នុងកងពល៤៥០ តែអង្គភាពនារីខ្ញុំគឺ វរៈ៥៣។

**ស៖** តើលោកស្រីចាំសមមិត្ត ឌឿន ដែលជាអនុបញ្ជាការវរ<សេនាតូចលេខ>៥៣ ដែរឬទេ?

**ឆ៖** មិត្តហ្នឹង ខ្ញុំអត់ស្គាល់ទេ ខ្ញុំអត់ដែលស្គាល់ទេចាស។ វរៈ៥៣ ខ្ញុំស្គាល់តែមិត្តខ្ញុំផ្សេងទេដែលគាត់ក្ដាប់ខ្ញុំវរៈ៥៣នេះឯង មានតែមិត្តគត់ ហើយនិងមិត្តជា ទេ បើថាមិត្តដែលគាត់ថាមិញ ខ្ញុំអត់ដែលស្គាល់ទេ។

**ស៖** តើ<លោក>ស្រីចាំឈ្មោះ ណាំ ហើយនិង សេង ដែល<ជាសមាជិក>នៅក្នុងវរ<សេនាតូចលេខ>៥៣ដែរឬទេ? <>ឈ្មោះ ណាំ <>និង<ឈ្មោះ>សេង<>?

**ឆ៖** ចាស ខ្ញុំអត់ដែលស្គាល់ទេ ខ្ញុំអត់ដែលដឹងទេ។

**ស៖** នៅពេលដែល<លោក>ស្រីធ្វើការនៅមន្ទីរពេទ្យកងពលហ្នឹង តើ<នៅពេលយប់លោក>ស្រីគេង<>នៅកន្លែងណាដែរ? នៅមន្ទីរពេទ្យតែម្ដង ឬក៏នៅកន្លែងផ្សេង?

**ឆ៖** ធ្វើការនៅក្នុងមន្ទីរពេទ្យហ្នឹងឯង គឺមានមន្ទីរអ្នកជំងឺផ្សេង គឺមន្ទីរអ្នកបុគ្គលិកដែលអ្នកបម្រើហ្នឹងផ្សេង។

**ស៖** តើ<លោកស្រី>ចាំទេ នៅពេលដែល<លោកស្រី>ធ្វើការនៅមន្ទីរពេទ្យនោះ តើ<លោក

ស្រីទទួលបាន>របប<ហូប>ប៉ុន្មានដែរ? ថាតើ<លោកស្រី> និងមិត្តរួមការងាររបស់<លោកស្រី> ទទួលបាន<បាយ>ក្នុងមួយថ្ងៃៗ<>ប៉ុន្មានដែរ?

[១៤:០៦:៥៣]

**ឆ៖** ចាស ខ្ញុំធ្វើការនៅក្នុងមន្ទីរពេទ្យហ្នឹង កន្លែងហ្នឹងគឺថាការងាររស់នៅ ជីវភាពរស់នៅ អ្នកជំងឺក៏ដូចបុគ្គលិកអ្នកបម្រើដែរ គេដាក់របបឱ្យមិនបានគ្រប់គ្រាន់ទេ តែគេឱ្យព្រឹក គេឱ្យហូបបាយ គឺដួសទៅរបបបានប្រហែលពីរវែកម្នាក់ហ្នឹង បានតែពីរវែកម្នាក់ឯង ប៉ះត្រង់ណាបុគ្គលិកខ្ញុំអ្នកបម្រើអ៊ីចឹងមើលអ្នកជំងឺមកជុំគ្នាវ៉ៃដួងមកជុំគ្នាឯង មិនបានមើលឃើញលួចបាយអ្នកជំងឺគ្នាហ្នឹងឯង ចាក់យកបន្តិចយកទៅហូបទៀត ខ្ញុំមិនបានមើលឃើញ ព្រោះអីជីវភាពអត់គ្រប់គ្រាន់ឱ្យហូបមិនឆ្អែត។ ពេទ្យក៏ដូចជាអ្នកជំងឺដែរ គេអត់ឱ្យហូបឆ្អែតទេ។ ហូប ព្រឹកឡើងហូបបាយ បើមិនគ្រប់គ្រាន់ ល្ងាចឡើងហូបបបរបានមួយពោះចានម្នាក់។ ចាស ហើយអ្នកជំងឺហ្នឹង កន្លែងមកពី -- មិនមែនមកឈឺដេកពេទ្យកន្លែងហ្នឹងឯងអី គ្មានមកពីសមរភូមិណាទេ គឺធ្វើស្រែៗជុំវិញកន្លែងក្រុងភ្នំពេញហ្នឹងឯង តាមបឹងមួយៗគឺគេឱ្យធ្វើស្រែ កងពលហ្នឹង គេឱ្យធ្វើស្រែ ពេលនេះគាត់គ្រុនសន្និ គ្រុនក្តៅ គ្រុនអី ដឹកមកដេកមន្ទីរ ណែនពេទ្យហ្នឹងឯង រួចតែដោយសារអត់បាយ និងធ្វើស្រែ អត់បាយហ្នឹងឯង។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសទេ គឺថានៅពេលដែល<លោកស្រី>ឈប់ធ្វើការនៅមន្ទីរពេទ្យកងពល គេបញ្ជូន<លោកស្រី>ទៅអូរបែកក្អម គឺទៅក្នុងកងការពារ៧៥។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំឈប់ធ្វើការនៅមន្ទីរពេទ្យហ្នឹងឯង ខ្ញុំមកនៅបឹងបាយ៉ាប ខ្ញុំចេញពីបឹងបាយ៉ាបមក គេដឹកឡានខ្ញុំ ដឹកឡានយកមកបញ្ចូលនៅកងពលសេនាធិការអង្គភាព៧៥នៅអូរបែកក្អមចាស។

[១៤:០៨:៥៨]

**ស៖** តើកងទ័ពមកពីកងពល៤៥០ហ្នឹងមានប៉ុន្មាននាក់<>មកឈរជើងនៅអូរបែកក្អមហ្នឹង?

**ឆ៖** ចាស កងពលដែល -- អង្គភាពនារីខ្ញុំនេះដែលមកពីកងពល៤៥០ មានវរសេនាតូចៗហ្នឹងគឺវា ខ្ញុំមិនដឹងដែរមួយវរសេនាតូច។ មានវរសេនាតូច ខ្ញុំតែងឮគេថាបីកង។ បីកងហ្នឹងបើគិតជាកងតូចមួយគឺមាន៣០នាក់ ចាស។

**ស៖** តើមូលហេតុអ្វីទើបគេចាត់តាំង<លោកស្រី>ឱ្យមកធ្វើការនៅក្នុងកងការពារហ្នឹងទៅវិញ?

**ឆ៖** ចាស កាលនោះ ខ្ញុំមិនដឹងដែរដែលគេបញ្ជូនខ្ញុំមកពីកងពល៤៥០ គេយកនារីខ្ញុំទាំងមួយវរ

សេនាតូចមកនៅអូរបែកក្អមហ្នឹងឯង។ ខ្ញុំអត់ដឹងទេ មកពីនោះគឺខ្ញុំឡើងឡានមកខ្ញុំចេះតែ គេហៅឲ្យមក ហើយ ហៅឡើងឡានចេះតែឡើងឡានតាមគេហើយ។ ដល់ពេលខ្ញុំមកដល់ណេះទៅ ដូចខ្ញុំប្រាប់ពីព្រឹកមិញហើយ ខ្ញុំថា ដល់មកដល់ណេះបានខ្ញុំដឹង បានគេប្រជុំលើកឡើងប្រាប់ខ្ញុំ។ បានខ្ញុំដឹងថា កងពលខ្ញុំហ្នឹង គេក្បត់អស់ហើយ គេចាប់យកទៅអស់ហើយ។ ដូច្នេះនៅតែមិត្តនារីឯងទាំងអស់គ្នាជាយុទ្ធជននេះឯង។ ដើមឈើតែកាលណាអាធំវាបាក់លើហើយ គឺអាតូចអី វាសង្កត់មកលើអាតូចហើយ។ ដូច្នេះគេហៅមិត្តឯងហ្នឹង គឺគេយកមកហើយ ឲ្យធ្វើការងារហើយ។ ចាស ប៉ុណ្ណឹងឯង។

[១៤:១០:៥៥]

**ស៖** ប៉ុន្តែតើគេមានប្រាប់<លោកស្រី>ទេថា ហេតុអ្វីបានជាគេបញ្ជូន<លោកស្រី>មកអង្គភាព<ការពារ> ៧៥ នោះ?

**ឆ៖** កាលខ្ញុំចេញមកពីកងពលហ្នឹង គេអត់មានប្រាប់ខ្ញុំទេ។ គ្រាន់តែគេថាឲ្យមិត្តយើងឡើងឡានទៅ ផ្លាស់ៗហើយ យើងផ្លាស់ទៅទៀត។ គេអត់មានប្រាប់ថាម៉េចៗ គេអត់មានប្រាប់ទេ។ ដល់ពេលខ្ញុំមកដល់ណេះឯង បានខ្ញុំប្រាប់ថា បើនៅអូរបែកក្អមហ្នឹងឯង បានប្រធានវរៈរបស់ខ្ញុំហ្នឹង បានគេប្រាប់ខ្ញុំ គេប្រជុំប្រាប់ខ្ញុំ។ ដូចខ្ញុំប្រាប់ហើយ ខ្ញុំប្រាប់ហើយប្រាប់ទៀតហ្នឹង ខ្ញុំថា ប្រាប់ថាកងពលខ្ញុំ គឺមេៗខ្ញុំគេចាប់យកទៅអស់ហើយ។ ដូច្នេះមិត្តឯង គឺបានគេចាប់មិត្តឯងយកមកណេះឯង។ គេមិនក្តាប់ថាឲ្យ ដូចខ្ញុំប្រាប់អ៊ីចឹង ថាដើមឈើធំតែគេបាក់បាក់មកហើយ វាសង្កត់អាតូចហើយ។ ដូច្នេះខ្ញុំមិនដឹងថាម៉េចទេ បើគេថាអ៊ីចឹងឯង។ យកខ្ញុំមកចម្រាញ់ការងារហ្នឹង ឲ្យខ្ញុំធ្វើការ ឲ្យខ្ញុំលត់ដំ ឲ្យខ្ញុំហូបបាយក៏មិនឆ្អែត ដេកក៏មិនបានពេញភ្នែក។ ហើយខ្ញុំគិតមើលទៅ ខ្ញុំជានារី ហើយហូបបាយមិនឆ្អែតហើយ ដេកមិនបានពេញម៉ោងទៀត។ ម៉ោងបី ផ្លុំកញ្ចែឲ្យខ្ញុំក្រោក តម្រង់ជួរ ទាល់តែម៉ោងបួនភ្លឺព្រាលៗ បានគេឲ្យចេញទៅស្រែ ឲ្យចេញទៅដកនៅស្រែនៅអូរបែកក្អមហ្នឹងឯង។ ដកស្ទូង ជញ្ជូនទូលលើក្បាល។ អង្កាល់ណោះគ្មានឧបករណ៍ រទេះគោអីនឹងបរដាក់ស្រែទេ មានតែក្បាលទេទូល។ រកគេតរកូតទាំងអស់គ្នាហ្នឹងឯង។

[១៤:១២:៣៥]

**ស៖** តើបញ្ហាការកងពល៤៥០ហ្នឹង មានទីតាំងនៅកន្លែងណាដែរ? ហើយតើកងទ័ពកងពល ៤៥០ហ្នឹង បោះទីតាំងនៅកន្លែងណាដែរ<>នៅទីតាំងអូរបែកក្អមនោះ?

**ឆ៖** ចាស កងពល៤៥០ហ្នឹងកាលដែលពីមុនមក ដូចខ្ញុំថាអ៊ីចឹងនៅតាមគីឡូលេខ៦ ច្រាំងចំរេះ

ទីតាំងរបស់គាត់ហ្នឹង។ តាមហ្នឹងហើយ តាមគីឡូលេខ៦ តាមច្រាំងចំរេះ របស់គាត់ គាត់នៅតាមហ្នឹងឯង តាមបឹងបាយ៉ាបបឹងអីហើយ ទីតាំងរបស់គាត់ គាត់នៅតាមនោះឯង។ គាត់អត់មានមកនៅអូរបែកក្អមទេ។ អូរបែកក្អមនេះ ពេលគេបញ្ជូនខ្ញុំមកបានគេបញ្ចូលនៅអង្គភាព៧៥ហ្នឹង។ កងសេនាធិការហ្នឹងគេចេញមកពីកងពលហើយ អង្គភាព៧៥ហ្នឹងគេចូលសេនាធិការហើយ។

**ស៖** តើត្រឹមត្រូវទេ ប្រសិនបើខ្ញុំនិយាយថាកងពល៤៥០ហ្នឹងមានកងទ័ពប្រហែល៥.៥០០នាក់ ឬក៏៦.០០០នាក់? តើ<លោកស្រី>គិតថាចំនួននេះត្រូវទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងដែរ រឿង៥.០០០ ឬ ៦.០០០ គឺខ្ញុំមិនដឹងទេ ព្រោះខ្ញុំដឹងថាកងពល គឺខ្ញុំដឹងថា កងពលដឹងថាច្រើន ប៉ុន្តែច្រើនមិនដឹងច្រើនប៉ុនណា ខ្ញុំមិនដែលដឹងដែរ ព្រោះខ្ញុំជាយុទ្ធជនសុទ្ធសាធ គឺខ្ញុំមិនសូវជាចេះគិតរឿងចំនួនកងពលទេ។ ខ្ញុំចេះតែពីរឿងថា គេឲ្យធ្វើការ ចេះតែធ្វើប៉ុណ្ណឹង។

[១៤:១៤:៣៣]

**ស៖** ឥឡូវយើង<ឧទាហរណ៍>ថាកងពល៤៥០ មានគ្នាប្រហែល៥.៥០០ ឬក៏ ៦.០០០នាក់អ៊ីចឹងទៅ។ តើកងទ័ព<>ហ្នឹង<ភាគច្រើនស្នាក់>នៅកន្លែង<ណា>ដែរ? <តើទីបញ្ជាការដ្ឋានកងពលនៅឯណា? តើ>កងទ័ពហ្នឹង នៅពេលយប់ហ្នឹង ដេកនៅកន្លែងណាដែរ? <>

**ឆ៖** ចាស នៅក្នុងកងពលហ្នឹងឯង អារឿងដេក អារឿងរស់នៅ គឺអង្គភាពដោយឡែក កងគេដោយឡែក កងវរសេនាធំគេដោយឡែក កងវរសេនាតូចគេដោយឡែក។ អ៊ីចឹងហើយ ម្យ៉ាងវិញទៀត គឺគេជាយុទ្ធជន គឺខ្ញុំអត់បានទៅរួមរស់ជាមួយ និងប្រាស្រ័យទាក់ទងជាមួយទេ តែខ្ញុំរស់នៅតែមិត្តនារីគ្នាខ្ញុំ ប្រាស្រ័យទាក់ទងគ្នាខ្ញុំតែមួយកងតូច ឬក៏មួយវរសេនាតូចប៉ុណ្ណឹង គឺខ្ញុំបានរួមរស់ជាមួយ តែដល់ពេលកងពល គឺខ្ញុំអត់មានរួមរស់ទេ ព្រោះគេជាយុទ្ធជន ខ្ញុំអត់មានទាក់ទងទេ។

**ស៖** តើលោកស្រីអាចប្រាប់បានទេ ថាតើស្ថានភាពរស់នៅក្នុងអង្គភាព<កងការពារលេខ>៧៥ <>ការរស់នៅមានលក្ខណៈយ៉ាងម៉េចដែរ? តើ<លោកស្រី>មានមុង <>មានកន្ទេលអ្វីត្រឹមត្រូវគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** ចាស ខ្ញុំដល់ពេលមកនៅហ្នឹងកន្លែងអូរបែកក្អមកង៧៥ហ្នឹង សម្រាកហ្នឹងតាមផ្ទះប្រជាជនដែលគាត់ជម្លៀសនៅតែកូនផ្ទះមួយៗ ចាសនៅសល់កូនផ្ទះមួយៗហ្នឹង គាត់ជម្លៀសចេញ គេជម្លៀសទៅ ដែលគេកងទ័ពគេចូលមក គេជម្លៀសប្រជាជនចេញពីភ្នំពេញអស់ទៅ គឺនៅផ្ទះខ្លះ ហើយដល់ខ្ញុំមកនៅអូរបែកក្អមហ្នឹងឯងនៅមានកូនផ្ទះខ្លះតូច ផ្ទះខ្លះធំ បើគេឲ្យនៅតាមផ្ទះហ្នឹងឯងចាស។

ហើយ

ប៉ុន្តែនៅតែផ្ទះទេ តែកន្ទេលខ្នើយអីគ្មានទេ ហើយមុងអីក៏គ្មានដែរ អត់មានទេ។

[១៤:១៦:៤៦]

**ស៖** ដូច្នេះស្ត្រីៗដែលមកពីអង្គភាព៧៥ហ្នឹង គឺគាត់ស្នាក់នៅតាមផ្ទះប្រជាជន<បោះបង់ចោល>នៅម្តុំអូរបែកក្អមអីចឹងមែនទេ?

**ឆ៖** ចាស អង្គភាពខ្ញុំមកពី៤៥០មកនៅ៧៥ហ្នឹងឯងគឺ -- ខ្ញុំសូមសួរម្តងទៀត គាត់សួរម្តងទៀត ខ្ញុំភ្លេចហើយ។

**ស៖** អត់អីទេលោកស្រី ខ្ញុំសួរម្តងទៀត តើកម្មាភិបាលនារីនៅក្នុងអង្គភាព៧៥ហ្នឹង គឺគាត់មកស្នាក់នៅៗតាមផ្ទះនៅជុំវិញអូរបែកក្អម អីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំមកពីកងពល៤៥០ គឺអង្គភាពខ្ញុំ គឺខ្ញុំមកនៅកន្លែងឯង គឺមេប្រធានរបស់ខ្ញុំ គឺមិនមានប្រធានមកពីភូមិឧត្តរដូចគ្នាទេ គឺខាងនិរតីទេដែលគេយកមកដាក់ខ្ញុំនៅកន្លែងនេះ។ ខាងនិរតីមេៗខ្ញុំហ្នឹង គឺគាត់ក្តាប់ខ្ញុំហើយ គឺនៅជាមួយគ្នាទាំងអស់។

**ស៖** ប៉ុន្តែ<លោកស្រី>ចាំទេថា <>នៅអង្គភាព៧៥<ហ្នឹង លោកស្រីស្នាក់នៅផ្ទះដែល>គេបោះបង់ចោលហ្នឹង ប៉ុន្មានអាទិត្យ ប៉ុន្មានខែដែរ<>?

**ឆ៖** ខ្ញុំមកនៅអង្គភាព៧៥ នៅអូរបែកក្អមហ្នឹង ខ្ញុំនៅធ្វើស្រែបានមួយរវស្សាដែរ។

**ស៖** តើក្នុងឆ្នាំណាដែរលោកស្រី?

**ឆ៖** ខ្ញុំមិនបានចាំឆ្នាំទេ ខ្ញុំកាលហ្នឹងខ្ញុំមិនសូវប៉ិនប្រសប់រឿងឆ្នាំ៧៥, ៧៦ផង ខ្ញុំមិនសូនបានប៉ិនចាំផង។ ខ្ញុំគ្រាន់តែថាដឹងពេលដែលថា ធ្វើស្រែមួយវស្សា គឺដឹងថាមួយវស្សាអីចឹង ធ្វើម៉ាៗបានស្ទូងហើយ គឺបានច្រូតប៉ុណ្ណឹង។

[១៤:១៩:៤០]

**ស៖** ហើយបន្ទាប់មកទៀត បើតាមខ្ញុំយល់ អ្នកស្រីទៅធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង។ តើ<លោកស្រី>ចាំទេថាគេបញ្ជូន<លោកស្រី>ទៅកំពង់ឆ្នាំង៦ខែហ្នឹងនៅពេលណា? នៅពេលចុងរដូវ<វស្សា> ឬក៏នៅដើមរដូវ<ប្រាំង> ឬក៏នៅចុងរដូវ<ប្រាំង>? <លោកស្រី>ចាំទេ?

**ឆ៖** ចាស ដែលខ្ញុំនៅអូរបែកក្អម ដែលគេបញ្ជូនខ្ញុំទៅព្រលានយន្តហោះហ្នឹងឯង គឺឆ្នាំ៧៧ ហើយបើខែ គឺខ្ញុំអត់ដឹងខែទេ ប៉ុនខ្ញុំចំណាំថា ខែហ្នឹង គឺខែ<ចេត្រ>។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើនៅខែ<ទី>១ ឆ្នាំ<១៩៧៧> ឬក៏នៅជិតដល់ខួបថ្ងៃ១៧ មេសា តើ<លោកស្រី>អាចចាំឲ្យច្បាស់ទេថាតើក្នុងថ្ងៃណា ឬក៏ក្នុងសប្តាហ៍ណានៅក្នុងឆ្នាំ<១៩៧៧> នៅពេលដែលគេបញ្ជូន<លោកស្រី>ទៅព្រលានយន្តហោះនោះ?

**ឆ៖** ចាស ដូចខ្ញុំឆ្លើយប្រាប់អំមិញហ្នឹងឯង ខ្ញុំថា ខ្ញុំចាំថាខែ -- ឆ្នាំ៧៧ តែខែចេត្រ ប៉ុន្តែបើខ្ញុំដឹងពីឥឡូវនេះ ខែចេត្រហ្នឹងឯង គឺខែ៤។

[១៤:២១:៣៩]

**ស៖** ឥឡូវនេះ ខ្ញុំសូមលើកយកប្រធានបទថ្មី មុននឹងត្រឡប់មកក្រោយវិញ។ មេបញ្ជាការកងពល៤៥០ហ្នឹង<>ឈ្មោះ សួង អ៊ីចឹងមែនទេ?

**ឆ៖** ចាស កងពល៤៥០ហ្នឹង គឺឈ្មោះ សួង អ៊ីចឹង។

**ស៖** តើ<លោកស្រី>ចាំទេ <នរណាជា>អនុប្រធានកងពល៤៥០<>?

**ឆ៖** ចាស កងពលបួនរយ ខ្ញុំស្គាល់តែកងពលមួយ គឺតែ សួង មួយហ្នឹងឯង បើអនុរបស់គាត់អី ខ្ញុំអត់ស្គាល់ទេ ព្រោះបានខ្ញុំស្គាល់ ពូសួង មួយហ្នឹងឯង ព្រោះខ្ញុំ កាលដែលខ្ញុំមកហ្នឹង ខ្ញុំបានជួបគាត់នៅមន្ទីររបស់គាត់ហ្នឹងឯង ខ្ញុំបានស្គាល់ម៉ែក្មេកគាត់ ស្គាល់បងថ្លៃគាត់ គឺខ្ញុំស្គាល់ច្បាស់ពីគាត់មួយហ្នឹង ចាស ខ្ញុំបានជួបគាត់ បានស្គាល់។ តែបើដល់អនុគាត់អី ឯណា ឯណីទៀត ខ្ញុំអត់ស្គាល់ទេ។

**ស៖** <>តើ<លោកស្រី>ចាំទេ <>តាសួង<>ដែល<លោកស្រី>ស្គាល់ច្បាស់ហ្នឹង<>គេចាប់គាត់នៅពេលណា?

**ឆ៖** ចាស ដែលឮថាគាត់ គេចាប់គាត់ហ្នឹងឯង ខ្ញុំមិនបានទេ ដែលខ្ញុំនៅកងពល៤៥០ គឺខ្ញុំអត់ដឹង អត់ដឹងថាគេចាប់គាត់នៅពេលណា គឺខ្ញុំអត់ដឹងទេ ទើបតែខ្ញុំ ដឹងដែលខ្ញុំមកអង្គភាព៧៥ ហើយដែលប្រធានអង្គភាព៧៥ គេបានប្រជុំប្រាប់ខ្ញុំហ្នឹងឯង បានខ្ញុំដឹងថា គាត់ហ្នឹងគេចាប់ចូលគុកមែន។

[១៤:២៣:៥២]

**ស៖** អ៊ីចឹងនៅពេលដែល<លោកស្រី>ឮព័ត៌មានថា សួង ហ្នឹងត្រូវគេចាប់ខ្លួនហ្នឹង គឺនៅពេលដែល<លោកស្រី>នៅអូរបែកក្អម។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ដែលខ្ញុំឮបានថា គេចាប់ខ្លួនគាត់ទៅហើយហ្នឹង គឺខ្ញុំឮនៅអូរបែកក្អម ដែលប្រធានគេប្រជុំប្រាប់ខ្ញុំហ្នឹង។

**ស៖** តើគេមានប្រាប់<លោកស្រី>អំពីហេតុផលដែលគេចាប់គាត់នោះទេ?

**ឆ៖** គេអត់មានប្រាប់ហេតុផលអ្វីទេ ប៉ុន្តែគេគ្រាន់តែថា "កងពលមិត្តឯង គេចាប់យកហើយ គេក្បត់អស់ហើយ" គេគ្រាន់ប្រាប់ប៉ុណ្ណឹងឯង។ តែហេតុផលម៉េចៗ គេអត់មានប្រាប់ថាម៉េច ខ្ញុំអត់ដឹង។

**ស៖** តើ<លោកស្រី>ធ្លាប់ឮឈ្មោះមេបញ្ជាការមួយរូបនៅក្នុងកងពល៤៥០ ឈ្មោះ <>គ្រឿន ដែរឬទេ?

**ឆ៖** ចាស ខ្ញុំនៅកងពល៤៥០មែន ប៉ុន្តែខ្ញុំអត់បានស្គាល់ទេ ខ្ញុំអត់ដឹង។

**ស៖** តើ<លោកស្រី>ដឹងទេថា សួង <>ដែល<លោកស្រី>ស្គាល់ច្បាស់ហ្នឹង គាត់ធ្លាប់ទំនាក់ទំនងជាមួយមេបញ្ជាការកងពល៣១០ ឈ្មោះ អឿន<ដែរឬ>ទេ?

**ឆ៖** ចាស ខ្ញុំអត់ដែលដឹងទេ។ ដឹងគាត់ទំនាក់ទំនងម៉េច ក៏ខ្ញុំអត់ដែលដឹងដែរ ព្រោះខ្ញុំនៅផ្សេង នៅវរៈផ្សេង។ ខ្ញុំអត់ដឹង។

**ស៖** តើមានគេធ្លាប់ប្រាប់<លោកស្រី>ថា សួង រួមជាមួយអ្នកដទៃទៀតហ្នឹង ត្រូវបានគេចោទប្រកាន់ថា <ព្យាយាម>ធ្វើរដ្ឋប្រហារនៅក្នុងដើមឆ្នាំ<១៩៧៧ ដែរឬ>ទេ?

**ឆ៖** ចាស ខ្ញុំអត់ដែលឮ អត់ដឹងទេ។ ដូចខ្ញុំនិយាយប្រាប់រួច ថាខ្ញុំអត់ដឹងទេ ព្រោះខ្ញុំអង្គភាពផ្សេង មិនអាចបានដឹងពីរឿងគេទេ។

[១៤:២៦:៤២]

**ស៖** តើ<លោកស្រី>ធ្លាប់ឮគេនិយាយ<រឿង>រក្សាកាំភ្លើងនៅកងពល៤៥០ ដើម្បី<ទុក>ធ្វើការបះបោរដែរឬទេ<>?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ បើខ្ញុំអត់ដឹង។ ខ្ញុំបានជាខ្ញុំឆ្លើយថាមិនដឹង ព្រោះខ្ញុំមិនដឹង ខ្ញុំខ្លាចណាស់របបអង្គាល់ហ្នឹង គឺខ្ញុំខ្លាចណាស់ របបផ្ដាច់ការ គឺអ្នកណាប៉ាននិយាយអី គឺអ្នកហ្នឹងឯង គឺច្បាស់ជាបាត់ខ្លួនហើយ។ អ៊ីចឹង គឺខ្ញុំអត់ប៉ានទេ។ ខ្ញុំធ្វើគតែម្ដង។ ខ្ញុំមិនដឹងរឿងហ្នឹងគេទេ ដឹងគេទៅណាទៅ។ តែខ្ញុំជាយុទ្ធជន គឺខ្ញុំប្រឹងធ្វើការ គឺខ្ញុំនៅតែធ្វើការ។ ខ្ញុំអត់ដឹងរឿងគេ។

**ស៖** តើ<លោកស្រី>ដឹងទេថា សួង គាត់ធ្លាប់មានទំនាក់ទំនងជាមួយ កុយ ធួន <ឬ ឃួន> ដែរឬទេ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងទេ។ ស្គាល់តែ បងសួង មួយហ្នឹង តែស្គាល់ កុយ, ស្គាល់ ធួន ណា ក៏ខ្ញុំមិនដែលស្គាល់ដែរ អត់ដែលស្គាល់សោះ។ ធម្មតា អង្គាល់ពីពេលនោះ យុទ្ធជនធម្មតា គេមិនដែលឲ្យយើងដឹងរឿងអីគេទេ។ រឿងគេទាំងប៉ុន្មាន គឺជារឿងលាក់ការណ៍ គេមិនឲ្យយុទ្ធជនដឹងទេ។ យុទ្ធជនដឹង

តែពីពេលហូបបាយ ហើយនិងធ្វើការអ៊ីចឹងទៅ។ គេឲ្យទៅម៉ោងណា យើងចេះតែនៅតាមគេទៅ។ ប៉ុណ្ណឹង។

**ស៖** នៅព្រឹកនេះ<លោកស្រី>បានផ្តល់សក្ខីកម្មថា <លោកស្រី>អត់ដឹងពី<មូលហេតុដែល> គេបញ្ជូន<លោកស្រី>ជាមួយ<សមមិត្ត>ដទៃទៀតទៅព្រលានយន្តហោះ<កំពង់ឆ្នាំ>នោះទេ។ អ៊ីចឹង ខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថា<លោកស្រី>មិនដឹងថា ហេតុអ្វីគេបង្គាប់<ឲ្យលោកស្រី>ទៅព្រលាន យន្តហោះ<កំពង់ឆ្នាំង> អ៊ីចឹងមែនទេ?

[១៤:២៨:៥៣]

**ឆ៖** ចាស ខ្ញុំទៅព្រលានយន្តហោះហ្នឹងឯង កាលគេឲ្យខ្ញុំទៅឯង គឺមិនមានគេឲ្យទៅជាយុទ្ធជន ធម្មតាណា តែពេលគេទៅ គេឲ្យប្រធានទៅតាមហើយ ទៅក្តាប់ ទៅតាម ទៅជួយបម្រើការងារនៅក្នុង ហ្នឹងឯង មានទាំងយុទ្ធជន និងប្រធាន ទៅទាំងអស់។

**ស៖** តើគេមានប្រាប់<មូលហេតុអ្វីបានជា>គេបញ្ជូន<លោកស្រី>ទៅទីនោះ ៦ខែទេ?

**ឆ៖** ចាស ពេលគេបញ្ជូនខ្ញុំទៅ គេអត់មានប្រាប់ថាប៉ុណ្ណេះខែ ប៉ុណ្ណោះខែ។ គេមិនបានប្រាប់ខ្ញុំ ទេ ប៉ុន្តែគេឲ្យទៅ គឺទៅៗ។ ពេលគេឲ្យមក គឺមកៗ។

**ស៖** <លោកស្រីសាក្សី> តើជាការត្រឹមត្រូវទេ ពេលដែល<លោកស្រី>មកដល់ព្រលានកំពង់ ឆ្នាំង គឺមានកងទ័ព<>ជាង១៥០០នាក់មកពីកងពល៤៥០ ធ្វើការនៅទីនោះ។ គឺមានន័យថាមានកងទ័ព ជាង ១.០០០នាក់មកពីកងពល៤៥០ <>ធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង។ តើ<លោកស្រី>ដឹង ពីបញ្ហានេះទេ?

**ឆ៖** ចាស ក្នុងកងពលខ្ញុំដែរគេបញ្ជូនទៅព្រលានយន្តហោះជាយុទ្ធជន គឺខ្ញុំអត់ដឹងទេ តែខ្ញុំដឹងពី ក្នុងកងយុវនារីយើងខ្ញុំ តែយុវជនគឺខ្ញុំអត់ដឹង មិនដឹងគេបញ្ជូនប៉ុន្មានរយ ប៉ុន្មានពាន់គឺខ្ញុំអត់ដឹង។

[១៤:៣០:៥៦]

**ស៖** លោកប្រធាន ខ្ញុំមានឯកសារ E3/849 គឺជាឯកសារជាភាសាបារាំងទាក់ទងទៅនឹងកង ពល៤៥០ ដែលឯកសារនេះបញ្ជាក់ថា នៅក្នុងខែមីនា ឆ្នាំ<១៩៧៧> គឺមានកងទ័ព<១.៥២៦>នាក់ ដែលធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង។ ហេតុដូច្នេះហើយទើបខ្ញុំសួរសំណួរមួយនេះ។ លោកស្រី ដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើខ្ញុំបញ្ជាក់ប្រាប់លោកស្រីថានៅក្នុងមីនា ឆ្នាំ<១៩៧៧> គឺមានកងទ័ព ១.៥០០នាក់មកពីកងពល៤៥០ <និងភ្ញៀវប្រាំមួយនាក់> ធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង។ <ខ្ញុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នឹងលើកពីចំណុចនេះដើម្បីសួរសំណួរ។ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី>នឹកឃើញឡើងវិញខ្លះ<ទេ>អំពីចំនួននេះ?

**ឆ៖** ខ្ញុំអត់ដឹងទេ បញ្ហាហ្នឹងគឺខ្ញុំអត់ដឹងរឿងកងពល រឿងយុទ្ធជន បំបែកតាមកង តាមវរៈអីខ្ញុំអត់ដឹង ព្រោះអីយុទ្ធជន ខ្ញុំអត់ដឹង ចំនួនគេគឺខ្ញុំអត់ដឹងទេ។ ដូចខ្ញុំបានជម្រាបប្រាប់ហើយ ខ្ញុំថាខ្ញុំដឹងតែក្នុងកងខ្ញុំ ក្នុងវរៈខ្ញុំដែលនារីដូចគ្នាហ្នឹង។ ថា គឺចំពោះយុទ្ធជនហើយ គឺខ្ញុំអត់បានដឹងទេ គេមិនឱ្យយើងជានារីទៅនិយាយរកយុទ្ធជនផងអង្កាល់ហ្នឹង គេមិនឱ្យទាក់ទងគ្នាទេ ឱ្យតែថានារី ហើយនិងយុទ្ធជនគេមិនឱ្យនិយាយរកគ្នាតែម្ដង។

**ស៖** ខ្ញុំសូមកែសម្រួលសំណួររបស់ខ្ញុំ។ នៅពេលដែលលោកស្រីបានទៅដល់ទីនោះជាមួយនឹងសមមិត្តនារី<៧ដទៃទៀតនោះ> ថាតើមានមនុស្សរាប់ពាន់នាក់ដែលធ្វើការនៅ<>ព្រលានយន្តហោះ<>កំពង់ឆ្នាំង<រួចហើយមែនទេ>?

**ឆ៖** ចាស ដែលខ្ញុំទៅដល់ពី៧៧ហ្នឹង ដែលខ្ញុំទៅដល់គឺខ្ញុំឃើញមែន។ គឺព្រលានយន្តហោះគឺធំណាស់ ប៉ុន្តែគឺយុទ្ធជនគឺធ្វើការពេញមួយព្រលានហ្នឹងឯងទាំងអស់។ ដែលធ្វើការអី ធ្វើការអីក៏ខ្ញុំមិនបានពិនិត្យគេសព្វគ្រប់ដែរ តែខ្ញុំបាននៅជុំវិញខ្លួនរបស់ខ្ញុំដែលខ្ញុំធ្វើបានជីកប្រឡាយ គឺខ្ញុំឃើញមានម៉ាស៊ីនកិនថ្ម គឺអាឡានអូសពោះនៅបង្ហាប់ដី បង្ហាប់អីហ្នឹងគឺខ្ញុំឃើញ ហើយនិងយុទ្ធជនជីកដីក្បែរខ្ញុំគឺខ្ញុំឃើញដែរ មនុស្សជាច្រើននៅកន្លែងហ្នឹង គឺមិនអាចដូចខ្ញុំថា។ មិនអាចរាប់រយទេ គឺរាប់ពាន់នៅកន្លែងហ្នឹង។ ខ្ញុំដឹងគឺខ្ញុំមានអាហ្នឹង។

[១៤:៣៣:៤២]

**ស៖** តើលោកស្រីអាចដឹងបានទេថា<>តើយុទ្ធជនទាំងអស់នោះធ្វើការនៅកន្លែងនោះអស់រយៈពេលប៉ុន្មានមកហើយដែរ<>? ថាតើ<>យោធាដែលថារាប់ពាន់នោះ ធ្វើការយូរប៉ុន្មានមកហើយមុនពេលដែលលោកស្រីទៅដល់? តើលោកស្រី<>អាចដឹងបាន<ដែរឬ>ទេ?

**ឆ៖** ចាស ខ្ញុំដែលពេលខ្ញុំទៅដល់ ខ្ញុំឃើញមនុស្សច្រើនអ៊ីចឹងតែម្ដង តែ។គេទៅពេលណា។ គឺខ្ញុំអត់ដឹង។

**ស៖** នៅពេលដែលលោកស្រីចាប់ផ្ដើមធ្វើការនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង លោកស្រីបាននិយាយថា <គេឱ្យ>លោកស្រី<ទៅ>លីបាវស៊ីម៉ង់ត៍<។ បើតាមខ្ញុំស្ដាប់យល់ថាវាមានរយៈ>ពេលពីរសប្ដាហ៍<ដែល>លោកស្រី<>និងមិត្តនារី<ដទៃទៀត>ហ្នឹង<>លីស៊ីម៉ង់ត៍<ចេញពីទូរថភ្លើង

តើត្រឹមត្រូវទេ>?

**ឆ៖** ចាស ខ្ញុំទៅនៅកំពង់ឆ្នាំងដូចខ្ញុំប្រាប់ហើយ ខ្ញុំនិយាយញ៉ឹកដែរហើយថា ខ្ញុំជីកប្រឡាយ គេដកពីប្រឡាយមករមាស គេឲ្យលីស៊ីម៉ង់ត៍ គឺទាំងអស់គ្នាហ្នឹង។ មួយកងហ្នឹងគេឲ្យលីស៊ីម៉ង់ត៍។ ខ្ញុំបានលីនៅហ្នឹងរួមគ្នាមិត្តទាំងអស់គ្នាហ្នឹង។

**ស៖** តើមានតែអង្គភាពលោកស្រីដែលស្ថិតនៅក្នុងកងពល៤៥០ ឬក៏មានសមាជិកកងពលផ្សេងទៀតក៏ចូលរួមក្នុងការលីស៊ីម៉ង់ត៍ហ្នឹងដែរ?

**ឆ៖** ចាស ពេលនោះ អត់មានកងពលណាចូលរួមទេ យុទ្ធជនក៏អត់មានចូលរួម តែនារីគ្នាខ្ញុំទាំងអស់ មួយកងៗតូចហ្នឹងឯង គឺសុទ្ធតែជានារីគ្នាខ្ញុំទេ។ អត់មានយុទ្ធជនណាមកចូលលាយ ឬក៏កងណាមកចូលលាយ អត់ទេ។

[១៤:៣៦:២៤]

**ស៖** តើលោកស្រីអាចដឹងដូចម្ដេចបានដែលថា បាវស៊ីម៉ង់ត៍ដែលលោកស្រីបានលីនោះថាប្រហែលជា៥០គីឡូក្រាម ធ្វើម៉េចបានអាចដឹងអ៊ីចឹងបាន?

**ឆ៖** ចាស ព្រោះអីគេ មិត្តយើងគេថា ស៊ីម៉ង់ត៍មួយបាវហ្នឹង គឺ៥០គីឡូ គេអ្នកប្រធានៗហ្នឹងគេប្រាប់ថា ៥០គីឡូមួយបាវហ្នឹងឯង។ រួចខ្ញុំថា តាមគេទៅ៥០គីឡូ ប៉ុន្តែស៊ីម៉ង់ត៍ហ្នឹង គឺ៥០គីឡូហើយ តែសព្វថ្ងៃហ្នឹង វាមិនដែលបាវខុសគ្នាទេ ពីមុនមកដែលខ្ញុំធ្លាប់លី ហើយនិងស៊ីម៉ង់ត៍យើងលក់ឥឡូវហ្នឹងគឺមួយបាវនៅតែ៥០គីឡូហើយ អត់ខ្វះទេ។

**ស៖** ចាតើនៅពេលនោះ មេបញ្ជាការកងរបស់លោកស្រីហ្នឹងឈ្មោះអី ដែលបញ្ជាឲ្យធ្វើការងារផ្សេងៗនៅក្នុងព្រលានយន្តហោះខេត្តកំពង់ឆ្នាំងនោះ? តើអ្នកណាជាអ្នក<>ប្រាប់ឲ្យលោកស្រី ហើយនិងសមាជិកផ្សេងទៀត លីបាវស៊ីម៉ង់ត៍ហ្នឹង?

**ឆ៖** នៅក្នុងនោះ ដែលកងខ្ញុំ កងតូចខ្ញុំហ្នឹង គឺគាត់ឈ្មោះបងរិន។ ចាស គាត់ទៅសម្រាប់ក្ដោបក្ដាប់បញ្ជាខ្ញុំហ្នឹងឯង គឺបងរិន។

**ស៖** តើគាត់ជាមេបញ្ជាការរបស់លោកស្រីដែរឬទេ នៅពេលដែលលោកស្រីនៅអូរបែកក្អម?

[១៤:៣៨:០៣]

**ឆ៖** គាត់ជាប្រធានកងតូចរបស់ខ្ញុំ ចាស។ បើប្រធានវរៈគឺខ្ញុំប្រាប់ហើយ ខ្ញុំថាបងរិន តែដល់ប្រធាន -- អនុប្រធានបងរិន ហ្នឹងឯង គឺកងធំ គឺបងភាព – បងភាព។ ដល់កងតូចដែលក្ដាប់ខ្ញុំផ្ទាល់ហ្នឹង

គឺ បងវិន។ ចាស គាត់ចុះទៅតាមខ្ញុំព្រលានយន្តហោះហើយ គេបំបែកគ្នា។ គេទុកមិត្តនារីខ្ញុំនៅហ្នឹង អូរបែកក្អមពាក់កណ្ដាល គេយកពួកមិត្តនារីខ្ញុំពាក់កណ្ដាលពីរឡាននេះ គឺទៅព្រលានយន្តហោះកំពង់ធំ ហើយ គឺបងវិនហ្នឹងឯង គាត់កងតូច គាត់តាមខ្ញុំជាប់។ តាមអង្គភាពជាប់។

**ស៖** តើមេបញ្ជាការរបស់លោកស្រីហ្នឹង ជាកម្មាភិបាលនារី<>ដែល<គ្រប់គ្រង>លោកស្រីនៅអូរបែកក្អមដែរឬទេ<?> ឬក៏ទៅ<ដល់ព្រលានយន្តហោះកំពង់ឆ្នាំង គេដូរមេបញ្ជាការ?>

**ឆ៖** ចាស ពេលដែលគេឲ្យខ្ញុំទៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងឯង គឺបងវិនហ្នឹងឯង គឺគេចាត់តាំងគាត់ជាប្រធានកង។ មេប្រធាននៅហ្នឹងឯង គេចាត់តាំងគាត់ពីនេះឯងទៅ គឺគាត់ជាប្រធានកងនេះឯងទៅតាមក្ដាប់ពួកខ្ញុំនៅព្រលានយន្តហោះហ្នឹង។ គឺទៅដល់នោះ អត់មានផ្លាស់ប្ដូរទេ តែគាត់ដដែល។

**ស៖** តើ<>ការបញ្ជា<របស់គាត់មានការប្រែប្រួលគ្នារវាងពេលនៅអូរបែកក្អម និងនៅព្រលានយន្តហោះ>កំពង់ឆ្នាំង<ដែរឬទេ>?

**ឆ៖** ខ្ញុំដូចមិនយល់ទេ រឿងកែប្រែ ដឹងកែប្រែរបៀបណា? ដឹងកែប្រែយ៉ាងម៉េច?

[១៤:៤០:២៩]

**ស៖** ប្រហែលជាសំណួរមិនច្បាស់សម្រាប់លោកស្រី។ <តើរបៀបបញ្ជារបស់មេបញ្ជាការលោកស្រីឈ្មោះវឿន នោះ>ដូចគ្នា<ឬក៏ខុសគ្នាពីកាលលោកស្រីនៅជាកងឃោធា និងពេលដែលលោកស្រីត្រូវគេបញ្ជូនឲ្យមកធ្វើការនៅ>កំពង់ឆ្នាំង<? ឬក៏>នៅពេលដែលទៅដល់ព្រលានយន្តហោះ កំពង់ឆ្នាំង <តើ>របៀបនៃការបញ្ជារបស់គាត់ដូចតែពីមុន ឬក៏ខុសគ្នាពី<ពេល>មុន<>?

**ឆ៖** ចាស ពេលគាត់ទៅដល់កំពង់ឆ្នាំង បទបញ្ជារបស់គាត់ គឺគាត់គ្មានបញ្ជាអីខុសពីឲ្យយុទ្ធជនយើងដែលនៅក្រោមគាត់ហ្នឹងធ្វើការជីកប្រឡាយ ឬក៏ធ្វើការអ្វីៗមួយ គឺគាត់បញ្ជានៅដដែលហ្នឹងចាស។

**ស៖** តើគាត់បានបញ្ជាឲ្យលោកស្រីធ្វើការខ្លាំងជាងមុនដែរឬទេនៅពេលដែលលោកស្រី ហើយនិងសមាជិកផ្សេងទៀតទៅដល់<ព្រលានយន្តហោះ>កំពង់ឆ្នាំងនោះ? ឬ<ម៉ោងពេលធ្វើការ>ក៏<គាត់>បញ្ជា<>ឲ្យធ្វើការដូចគ្នា<ដដែល>ទេ<>?

[១៤:៤១:៥៧]

**ឆ៖** ចាស ពេលគាត់ទៅដល់កំពង់ឆ្នាំង គឺមិនខុសអីដែលគាត់បញ្ជាដែលនៅអូរបែកក្អមហ្នឹង គាត់បញ្ជាដូចខ្ញុំថា មានពេលមានម៉ោង ពីម៉ោងប្រាំទៅ ប៉ុន្តែនៅអូរបែកក្អម វាតាំងពីម៉ោងបី ប៉ុន្តែទៅ

ដល់កំពង់ឆ្នាំងធ្វើការហ្នឹងឯងចាប់ពីម៉ោងប្រាំព្រឹក គឺទៅដល់ម៉ោងមួយដណ្ដប់ ចាប់ពីម៉ោងមួយដណ្ដប់ដល់ម៉ោងមួយ ក៏ទៅដល់ម៉ោង១ប្រាំល្ងាច ចាប់ពីម៉ោងប្រាំល្ងាចឡើង ចេញម៉ោងប្រាំមួយចេញទៅវិញយប់ គឺដល់ម៉ោងប្រាំបួនបានឡើង វាដល់កំពង់ឆ្នាំងគឺអ៊ីចឹង គាត់បញ្ជាឲ្យនៅតែរហូត។ អារឿងការងារវាមានលក្ខណៈរបស់វាការងារហ្នឹង ចាស។ ដែលថាដល់ពេលទៅធ្វើសំណង់ វាផ្សេងទៅ វាមានពេលម៉ោងប្រាំបួនយប់ហ្នឹងបានឡើង ម៉ោងប្រាំមួយល្ងាចស៊ីបាយរួច គេចេញទៅវិញហើយ ចាសគឺគាត់បញ្ជាជាប់ គឺបញ្ជាក្ដៅអ៊ីចឹង មិនឲ្យយើងដកថយពីការងារអីទេ ហើយក៏មិនឲ្យយើងរួញរាពីការងារទេ។ ការងារដែលត្រូវធ្វើ គឺគាត់ត្រូវតែឲ្យយើងធ្វើហើយ តែយើងធ្វើអែនអន យើងធ្វើពុត ធ្វើត្បុតហ្នឹងឯង គឺមានបទបញ្ជាហៅប្រជុំហើយ ប្រជុំទិតៀនថាមិត្តយើងពុតត្បុតម៉េច១ហើយ។ ហ្នឹងរឿងបញ្ហាការ រឿងប្រធាន។

**ស៖** តើគាត់ធ្លាប់ប្រាប់លោកស្រី ឬក៏សមមិត្តនៅក្នុងកងរបស់លោកស្រីនៅពេលដែលនៅព្រលានយន្តហោះកំពង់ឆ្នាំងដែលថាគាត់មកទីនេះ គឺគាត់ដើម្បី<>ដាក់ទណ្ឌកម្ម <កសាងខ្លួន និងលត់ដំ> ដល់ពួកលោកស្រីទេ តើ១គាត់ធ្លាប់ប្រើពាក្យទាំងអស់ហ្នឹងចំពោះលោកស្រី ឬក៏សមមិត្តនារីនៅក្នុងកងរបស់លោកស្រីទេ<>?

[១៤:៤៣:៥៣]

**ឆ៖** ចាស កាលនៅព្រលានយន្តហោះកំពង់ឆ្នាំង ការងារដូចខ្ញុំប្រាប់អ៊ីចឹង។ ការងារកាលមិត្តណាធ្វើមិនបានល្អ ធ្វើមិនពេញដៃពេញជើង អែនអន មានពុតត្បុតអី ទៅលិចទៅកើតហ្នឹងឯង ពេលហ្នឹងតែកាលគាត់មិនទាន់ថាទេនៅការដ្ឋាននោះ ប៉ុនដល់ពេលយប់ឡើងមកដេក មកសម្រាន្តហើយ គាត់ចាប់ផ្ដើមអង្គប្រជុំ គាត់១ទិតៀន គាត់ថាឲ្យហើយ។ គាត់ថា មិត្តឯងនេះធ្វើការមិន១យកចិត្តទុកដាក់ទេ មិនយកចិត្តទុកដាក់នឹងការងារទេ ឥឡូវមិត្តឯងសូមជួយកែប្រែ ក៏គាត់មិនថាកែប្រែ ឲ្យប្រឹងប្រែងធ្វើការងារ។ គាត់គ្រាន់តែប្រជុំប្រាប់ទិតៀនមិត្តយើង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី អរគុណដើមបណ្ដឹងរដ្ឋប្បវេណី ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតម៉ោង -- រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ និងអ្នកជំនាញដល់ដើម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកនៃអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០២:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការដំណើរការនៃនីតិវិធីសវនាការ។ ហើយតទៅនេះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី -- ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ ហើយភាគីសហមេធាវីទាំងពីរក្រុម មានពេលវេលា ២៥នាទីទៀត ក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីខ្ញុំមិនមានសំណួរអ្វីច្រើនបន្ថែមទៀតនោះទេ។ ប៉ុន្តែ ខ្ញុំចង់សាកសួរទៅលើឯកសារមួយជាមួយលោកស្រី។ លោកប្រធាន ឯកសារនេះគឺ E3/1161, <ERNជាភាសា>អង់គ្លេសមានលេខ00876994, ខ្មែរមានលេខ00052322 និងបារាំងមានលេខ 00803309។ <លោកស្រី>នេះគឺជារបាយការណ៍អំពីស្ថានភាពទូទៅនៅក្នុងកងពល៣១០ និង<កងពល>៤៥០ ហើយវាបាននិយាយអំពីកិច្ចប្រជុំ រវាងបងប្អូនទាំងអស់នៅថ្ងៃ១១ ខែមីនា ឆ្នាំ<១៩៧៧>។ ហើយរបាយការណ៍ហ្នឹងធ្វើឡើងដោយកម្មាភិបាលម្នាក់ឈ្មោះ រិន។

[១៥:០៤:១៤]

ខ្ញុំសូមអាននៅចំណុចមួយចំនួននៅក្នុងរបាយការណ៍នេះ ហើយប្រហែលជាចំណុចទាំងអស់នេះអាចធ្វើឲ្យ<លោកស្រី>នឹកឃើញការប្រជុំរបស់កងវរ<សេនាធំ>ដែល<លោកស្រី>និយាយកន្លងមក

៖ រិន បាននិយាយនៅចំណុចមួយចំនួនដូចជានៅក្នុងកងពល៣១០ និង<កងពល>៤៥០ គឺមានការខ្វះចបជីក ចបកាប់។ ហើយស្ថានភាពទាក់ទងទៅនឹងសាច់ និង ត្រី គឺ<ដោះស្រាយ>បាន <គឺថាក្នុងមួយកង១ទទួលបានរបបហូបបីរទេះរៀងរាល់ព្រឹក។ តើលោកស្រីនឹកឃើញខ្លះទេ? នៅពេលប្រជុំជាមួយបងប្អូន>ក្នុងកងពល៣១០ និង<កងពល>៤៥០ <>នៅថ្ងៃ<១១ ខែមីនា ឆ្នាំ១៩៧៧> ហើយ <រិន> ដឹកនាំកិច្ចប្រជុំ<នោះ>។ តើ<លោកស្រី>អាចនឹកឃើញអំពីហេតុការណ៍នេះទេ?

**លោកស្រី គង់ សៀក៖**

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ អត់ដឹងគេប្រជុំកន្លែងណា ឬថ្ងៃណាខ្ញុំអត់ដឹងទេ។

**ស៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិន លោកមេធាវី វ៉ិចទ័រកូប៉េ! សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីឲ្យដឹង ឲ្យច្បាស់ថាតើកិច្ចប្រជុំនោះជាអ្វីនោះ ប្រហែល<លោកមេធាវី>ត្រូវ<អាន> របៀបវារៈនៃកិច្ចប្រជុំនោះយ៉ាងម៉េចដែរ ដូចពីចំណុចទី១ដល់ចំណុចទី៥នោះ<។>

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកចៅក្រម ខ្ញុំនឹងធ្វើតាម។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំនឹងអាននូវរបៀបវារៈនៃកិច្ចប្រជុំនេះ។ ប្រហែលជាព័ត៌មាននេះអាចជួយឲ្យ<លោកស្រី>នឹកឃើញបានខ្លះ។ ចំណុចទី១ គឺពិនិត្យសតិអារម្មណ៍នយោបាយចាត់តាំងរបស់កងនីមួយៗ។ ទី២ ពិនិត្យសភាពការណ៍ខ្មាំងក្នុងកងទ័ព សភាពការណ៍ខ្មាំងខាងក្រៅ។ ទី៣ ភារកិច្ចរបស់យើងដែលបក្សប្រគល់ឲ្យ ពិសេសពិនិត្យមើលលើស្មារតីបំពេញភារកិច្ចរបស់បក្ស។ ទី៤ គោរពវិន័យរបស់អង្គការឲ្យបានដាច់ខាត។ ៥)បញ្ហាជីវភាពរស់នៅរបស់កង<នីមួយៗ> និងទី៦ បញ្ហាផ្សេងៗ។

នៅពេលដែលខ្ញុំអាននូវរបៀបវារៈទាំងអស់នេះ តើវាធ្វើឲ្យ<លោកស្រី>អាចនឹកឃើញបានទេ អំពីការប្រជុំនេះ?

[១៥:០៧:៣៩]

**លោកស្រី គង់ សៀក៖**

**ឆ៖** ខ្ញុំអត់មាននឹកឃើញរឿងការប្រជុំវរៈណាណី ខ្ញុំអត់ដឹង មាននឹកឃើញទេ អត់ដឹង។

**ស៖** មិនជាថ្វីទេ<លោកស្រី> ហើយសំណួរចុងក្រោយរបស់ខ្ញុំចំពោះ<លោកស្រី> គឺជាសំណួរដែលអាចថាមានភាព<ប្រឆាំង>គ្នា<>ព្រោះថាព្រះរាជអាជ្ញាក៏បានលើកយកឯកសារនេះយកមកប្រើប្រាស់ គឺឯកសារ <E3/1892> គឺជាចម្លើយសារភាពរបស់ <សួង។> ហើយនៅផ្នែកខាងលើនៃចម្លើយសារភាពគឺបាននិយាយថា ចម្លើយសារភាពនេះត្រូវបានសរសេរឡើងមុនពេល<>គេធ្វើទារុណកម្ម<ដូចដែលខាងព្រះរាជអាជ្ញាបានបញ្ជាក់ដែរ កថាខណ្ឌមួយនៅក្នុង>ឯកសារនេះ គឺនិយាយអំពីមន្ទីរពេទ្យកង<ពល> <>និងស្ថានភាព<របស់ពេទ្យ>កងពល។ <ខ្ញុំអានខ្លឹមសារនៃអត្ថបទ>នេះ។ បញ្ហាចំពោះឯកសារនេះ គឺថាវាមាន<តែជាភាសាអង់គ្លេស>--

[១៥:០៨:៥៥]

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិនលោក វ៉ិចទ័រ កូប៉េ! សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ប្រហែលជាត្រូវសួរ<ខាងព្រះរាជអាជ្ញា ឬលោក>ខ្លួនឯងថា តើ<អ្វីដែលអះអាងថាជា>ចម្លើយសារភាព<>មុនពេលធ្វើទារុណកម្ម<នោះ>?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនដឹងទេ លោកចៅក្រម ឡាវែន៍។ ខ្ញុំគ្រាន់តែអាននូវផ្នែកដំបូងនៃឯកសារនេះ ដែលនិយាយថា "ចម្លើយសារភាពនេះធ្វើឡើងមុនពេលធ្វើទារុណកម្ម"។ ខ្ញុំលើកយកឯកសារនេះ ព្រោះថាព្រះរាជអាជ្ញាក៏គាត់បានដកស្រង់នូវប្រយោគដដែលនេះ។ ហើយដើមបណ្តឹងរដ្ឋប្បវេណី ក៏បាននិយាយថាគាត់ធ្វើការនៅមន្ទីរពេទ្យកងពលនោះដែរ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់អានផ្នែកដែលទាក់ទងទៅនឹងមន្ទីរពេទ្យរបស់កងពលប៉ុណ្ណោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើលោកអាចសួរទៅសហភាតាខ្មែររបស់លោកនោះ <>ថាតើ<>សំណៅ<ដើមជាភាសាខ្មែរ>មាននិយាយ<បែបហ្នឹងដែរឬទេ? តាមពិតទៅនៅក្នុងឯកសារដើមជាភាសាខ្មែរមិនមាននិយាយថា ">ចម្លើយសារភាព<សរសេរ>មុនពេលធ្វើទារុណកម្ម"<>ទេ។<>

[១៥:១០:២៨]

**លោក វ៉ិចទ័រ កូប៉េ៖**

អានេះគឺជាអ្វីដែលខ្ញុំចង់សួរនាំដែរ ហើយប៉ុន្តែ<ខ្ញុំមានតែសេចក្តីសង្ខេបជា>ភាសាអង់គ្លេស<> ប្រហែលជា៣០-៤០ទំព័រ<>។ ហើយខ្ញុំគិតថា ព័ត៌មានសង្ខេបនេះ គឺប្រហែលជាជាធ្វើឡើងដោយស្ទីវ ហេដឌ័រ<។> ប៉ុន្តែសំខាន់បំផុតគឺយើងមិនមានឯកសារជាភាសាខ្មែរ។ ការពិតឯកសារជាភាសាខ្មែរ គ្រាន់តែយើងមិនអាចអានបាន <ហើយជាភាសាបារាំងយើងក៏គ្មានទៀត>។ ដូច្នេះ ខ្ញុំគ្រាន់តែចង់<ដកស្រង់ឃ្លាទីមួយ>--

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អ៊ីចឹងក្នុងករណីហ្នឹង<លោកមេធាវី កូប៉េ មិនគួរ>ប្រើឯកសារហ្នឹងទេ <ព្រោះថា>យើងមិនដឹងថាតើក្នុងកាលៈទេសៈណាដែលទទួលបានចម្លើយសារភាពនោះផងនោះ <ហើយយើងក៏មិន>ដឹងថានេះជាចម្លើយសារភាពដែលចេញមកពីមន្ទីរស-២១<ដែរឬទេ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំចង់អាន<អត្ថបទនោះ> ប៉ុន្តែប្រសិនបើជាលោកមិនចង់ឲ្យខ្ញុំអាន--<អ៊ីចឹងមានតែខ្ញុំ-->

[១៥:១១:២៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី ខ្ញុំគិតថា លោកអាចប្រើចម្លើយសារភាពបាន តែក្នុងករណីលោកប្រើតែលើចំណានោះទេ មិនអាចប្រើលើខ្លឹមសារក្នុងឯកសារចម្លើយសារភាពហ្នឹង<គឺមិនត្រឹមត្រូវ>ទេ។ <ក្នុងកាលៈទេសៈណាក៏ដោយ វាមិនត្រឹមត្រូវទាល់តែសោះចំពោះចម្លើយសារភាពដែលយើងមិនដឹងថាវាទទួលបាននៅក្នុងសភាពបែបណានោះ។>

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនដឹងអំពីការសម្រេចអំពីបញ្ហានេះទេ។ ដូច្នេះ ខ្ញុំគិតថាឥឡូវនេះ ខ្ញុំកំពុងតែរង់ចាំនូវ<ការ>សម្រេចទៅលើបញ្ហាមួយនេះ។ ច្បាស់ណាស់ថា គឺមានការ<ណែនាំប្រាប់នៅពេលសួរថាតើមានការធ្វើទារុណកម្ម>សួរចម្លើយមេបញ្ជាការកងពល៤៥០<ឬយ៉ាងណានោះ>។ ដូច្នេះ ប្រសិនបើលោកចៅក្រមនិយាយថា ខ្ញុំមិនអាចសួរបាន ខ្ញុំគ្មានជម្រើសអ្វីផ្សេងនោះទេ។ <តើ>នេះគឺជាការសម្រេចរបស់លោកចៅក្រមមែនទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ខ្ញុំគិតថាលោកយល់ច្បាស់ហើយអំពីបទបញ្ហា។

**លោក វិចទ័រ កូប៉េ៖**

ដូច្នេះមែន ខ្ញុំសូមបញ្ចប់ការសួររបស់ខ្ញុំ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ក្រុមមេធាវីការពារលោក ខៀវ សំផន មិនមានសំណួរដើម្បីសួរទៅដើមបណ្ដឹងនេះទេ លោកប្រធាន។

[១៥:១៣:០៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកស្រី គង់ សៀក ដូចអង្គជំនុំជម្រះបានជម្រាបលោកស្រីរួចហើយ កាលពីដំបូងនៃ -- មុននឹងស្ដាប់សក្ខីកម្មរបស់លោកស្រីថា ជាចុងក្រោយលោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្ដាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទទាំងពីររូប នួន ជា និងខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យលោកស្រីសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្ដឹងទាមទារសំណងជំងឺចិត្ត និងជាសមូហភាពពីជនជាប់ចោទ និងអំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកស្រីជាអាទិ៍ ការខូចខាតរាងកាយ ផ្លូវចិត្ត ឬខូចខាតសម្ភារៈ ផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតឡើងមានពិតប្រាកដរហូតដល់បច្ចុប្បន្ន។ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ សូមអញ្ជើញ!

**លោកស្រី គង់ សៀក៖**

ចាស ខ្ញុំ គឺខ្ញុំសូមនិយាយ ហើយក៏ខ្ញុំសូមព្រះរាជអាជ្ញា លោកចៅក្រម ដើម្បីខ្ញុំរាយការណ៍ពីខ្លួនរាងកាយរបស់ខ្ញុំ ហើយនិងក្រុមគ្រួសាររបស់ខ្ញុំ ខ្ញុំសូមសួរសំណួរមួយថា ខ្ញុំនៅសមរភូមិក្រោយ ចាស ខ្ញុំបានគេជម្លៀសម៉ែឪ បងប្អូនខ្ញុំទៅនៅក្នុងព្រៃ ហើយពេលនោះ ក៏គេបានលើកអង្គប្រជុំថា គេធ្វើបដិវត្តន៍នេះគឺដើម្បីរំដោះប្រជាជន តែដល់ពេលខ្ញុំធ្វើទៅតាំងពីឆ្នាំ៧៣ រហូតដល់ឆ្នាំ៧៤។ ធ្វើទៅ គឺគេថាឲ្យប្រជាជនគឺមានសិទ្ធិសេរី ចាស។ ដល់ក្រោយឡើង ប្រជាជនខ្ញុំស្ដាប់ ខ្ញុំតាមមើលទៅ ខ្ញុំអត់មានសិទ្ធិសេរីភាពចំពោះបងប្អូនម៉ែឪខ្ញុំ មីងៗខ្ញុំ គឺគេយកចូលទៅក្នុងព្រៃ គឺគេឲ្យអត់បាយ បាយហូបមិនឆ្អែត គេមិនហ៊ានថាឲ្យអត់ទេ ប៉ុន្តែបាយគេឲ្យហូបហើយតែហូបមិនឆ្អែត។ ហើយគេឲ្យធ្វើការ គេឲ្យដាំដំឡូង

គេឲ្យធ្វើស្រូវ ហើយក្នុងនោះក៏គ្មានខោអាវស្លៀកពាក់។ អ៊ីចឹងគេលើកថា មានសេរីភាពត្រង់ណា ចុងក្រោយបង្អស់គេថាមានសេរីភាព តែជាប្រជាជនទាំងរូបខ្ញុំក្តី ទាំងរូបបងប្អូនក្តី គឺគេប្រើរបបជាទាសករ គេទុកប្រជាជនជាទាសកររបស់គេវិញ។ កន្លែងនេះសូមលោកជួយវិនិច្ឆ័យឲ្យខ្ញុំ និងរកយុត្តិធម៌ឲ្យខ្ញុំផង ពីព្រោះអីខ្ញុំវេទនានៅសមរភូមិក្រោយ ហើយខោអាវស្លៀកពាក់ម៉ែខ្ញុំ ឪខ្ញុំ គោក្របី គេនេះអស់ គេដកចូលរួមអស់ហើយ គេមិនឲ្យហូបឆ្អែតទេ ហើយគេថាមានសេរីភាព។ តាមការពិតរបបនេះគឺប្រើប្រជាជនជាទាសកររបស់គេពិតប្រាកដ។ ហើយឪខ្ញុំគឺគាត់គ្មានខោស្លៀក គាត់សុំគេថា ឲ្យសុំខោខ្លីមួយមក គេថាគេមិនឲ្យទេ។ ឪខ្ញុំថាបើមិនឲ្យហ៊ីទៅឲ្យវាចេញក្តទៅចុះ តែប៉ុណ្ណេះឯង។ ឪខ្ញុំថា ក៏គេយកឪខ្ញុំឲ្យជួយមតិ គេយកទាំងរូបខ្ញុំទៀតទៅជួយមតិឪខ្ញុំ។ អង្កាល់នោះដល់ពេលនេះចប់ ភ្នំពេញ៧៥ ចប់ភ្នំពេញ ៧៥ ខ្ញុំនឹកឃើញថានៅសមរភូមិក្រោយនេះវាលំបាកវេទនាខ្លាំងពេក ក៏ខ្ញុំឃើញប្អូនខ្ញុំចេញពីភ្នំពេញនេះទៅដែលរំដោះរួចហើយ ទៅលេងស្រុកភូមិក៏គេទៅយកប្រពន្ធគេ ក៏ខ្ញុំបានសុំប្អូនខ្ញុំមក។ ដល់ពេលខ្ញុំដល់សមរភូមិមុខនេះ នៅក្នុង៧៥នោះ នៅក្នុងសមរភូមិមុខ ដូចខ្ញុំរាយប្រាប់ពីមុនហើយ អង្កាល់ខ្ញុំនៅមន្ទីរពេទ្យឫស្សីកែវ។ រហូតមកដល់ខ្ញុំមកដល់ណេះគេបញ្ជូនខ្ញុំមកដល់អូរបែកក្អមនេះ ក៏គេធ្វើបាបខ្ញុំៗឲ្យខ្ញុំស្ទូងស្រូវ ឲ្យខ្ញុំហូបបាយមិនឆ្អែត ឲ្យខ្ញុំដេកតាមភ្លឺស្រែចាប់តាំងពីម៉ោង មួយយប់ៗគឺទាល់ភ្លឺ ខ្ញុំគ្មានអីហូប រាងកាយរបស់ខ្ញុំក៏ស្គមស្គាំងទៅ។ ខ្ញុំដើរហូបផ្លែអំពិលទឹក ហើយខ្ញុំហូបផ្លែអំពិលទឹកនេះ ក៏ខ្ញុំហូបមិនឲ្យគេឃើញដែរ មិនឲ្យកម្មាភិបាលណាមួយឃើញខ្ញុំទេ គឺខ្ញុំលួចហូប តែមិត្តគ្នាឯងស្ទាត់ស្ទៀមតាមភ្លឺស្រែនេះ ហើយគេថាមានសិទ្ធិសេរីភាព។ ខ្ញុំសូមថាមានសិទ្ធិសេរីភាពពីត្រង់ណា បើគេប្រើប្រជាជនដល់ប៉ុណ្ណេះឯង យុទ្ធជនដល់ប៉ុណ្ណេះៗឯង។ សូមលោកជួយរកយុត្តិធម៌ចែកខ្ញុំផង។

[១៥:១៧:២៩]

ហើយមួយទៀត ខ្ញុំទៅដល់កំពង់ឆ្នាំងគេឲ្យខ្ញុំលើកដី គេឲ្យខ្ញុំជីកប្រឡាយ ខ្ញុំជីកបែកដៃ ពងដៃក៏ខ្ញុំមិនហ៊ានត្អូញត្អែរថា ខ្ញុំបែកដី ពងដៃ សុខចិត្តតែខ្ញុំខំប្រឹងធ្វើទាំងយប់ទាំងថ្ងៃ ការលំបាកវេទនាប៉ុនណាក៏ខ្ញុំសូម -- តែខ្ញុំធ្វើនៅក្នុងពេលនោះគឺខ្ញុំខ្លាចស្លាប់ មិនបានរស់មកដល់សព្វថ្ងៃ ខ្ញុំចេះខំប្រឹងធ្វើទៅ គឺរបបផ្តាច់ការរបស់គេរហូតដល់ឲ្យខ្ញុំលីស៊ីម៉ង់ត៍ទៀតៗ ខ្ញុំខំប្រឹងលីៗមិនរួច ខ្ញុំដើរទា គេថាឲ្យខ្ញុំទៀតគេថាមិត្តឯងអីក៏លីមិនរួច ក៏កម្លាំងអីក៏លីមិនរួច។ រហូតដល់ខ្ញុំលីស៊ីម៉ង់ត៍ ខ្ញុំជីកដីហើយ សព្វថ្ងៃក៏ប៉ះពាល់ដល់រាងកាយរបស់ខ្ញុំនេះឈឺដើមទ្រូងខ្ញុំនៅរាល់ថ្ងៃ ហើយចង្កេះខ្ញុំគឺគ្រាំគ្រារាល់ថ្ងៃ ទោះបីខ្ញុំមកសាលាក្តីកន្លែងនេះក៏ខ្ញុំលេបថ្នាំដែរ ខ្ញុំលេបថ្នាំឡើងឈាម ខ្ញុំលេបថ្នាំសរសៃបានខ្ញុំដើររួចបានប៉ុណ្ណេះ។ នេះខ្ញុំសូម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មានសំណួរចុងតែប៉ុណ្ណេះឯង ដែលគេថាមានសិទ្ធិសេរីភាព តែលោកជួយរកយុត្តិធម៌ចែកខ្ញុំ សិទ្ធិសេរីភាពត្រង់ណា បើប្រជាជនជាទាសករដាច់ថ្លៃរបស់គេ។ ខ្ញុំសូមអស់មតិប៉ុណ្ណេះឯង។ សូមចប់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយតើលោកស្រីមានសំណួរអ្វីជាក់លាក់សួរទៅ -- មានបំណងចង់សួរទៅជនជាប់ចោទ នួន ជា និង ខៀវ សំផន ដែរឬទេ? ប្រសិនបើមានសំណួរជាក់លាក់លោកស្រីអាចធ្វើបានដោយសង្ខេបខ្លី ហើយសួរតាមរយៈយើងជាប្រធានអង្គជំនុំជម្រះ មិនអាចសួរគាត់ផ្ទាល់បានទេ។

**លោកស្រី គង់ សៀក៖**

ខ្ញុំដូចថា សំណួររបស់ខ្ញុំនេះដែលចុងក្រោយបង្អស់នេះ ដែលខ្ញុំពិបាកវេទនាដល់ប៉ះពាល់រាងកាយខ្ញុំប៉ុណ្ណេះឯង ដែលខ្ញុំគ្រាន់តែថាឲ្យលោករកយុត្តិធម៌ឲ្យខ្ញុំទេ បើរាងកាយខ្ញុំដល់ប៉ុណ្ណេះឯង គឺខ្ញុំសូមថាធ្វើយ៉ាងណាគឺឲ្យខ្ញុំបានធូរអារម្មណ៍នៅក្នុងខ្លួនខ្ញុំផង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានចប់ហើយ ។សវនាការបន្តទៅនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-943 សូមភាគីជ្រាប។ អង្គជំនុំជម្រះអរគុណលោកស្រី គង់ សៀក សវនាការស្តាប់សក្ខីកម្មនិងការស្តាប់ ការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលលោកស្រីអះអាងថា លោកស្រីបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានដល់ទីបញ្ចប់ហើយ ហើយវត្តមានរបស់លោកស្រីនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលមាន -- លោកស្រីមានបំណងចង់ទៅបានហើយ ហើយសូមលោកស្រីមានសំណាងល្អ មានសុខភាពល្អ ហើយនិងវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។ ហើយអង្គជំនុំជម្រះក៏សូមអរគុណផងដែរលោកស្រី ឆាយ ម៉ារីដែន បុគ្គលិកអង្គការ ធី.ភី.អូ ដែលបានជួយអង្គុយនៅក្បែរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្ម ហើយលោកស្រីអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹង គង់ សៀក វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណង ចង់ទៅបានហើយ ហើយនិងបង្គាប់ឲ្យអញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-943 ចូល

មកកាន់កន្លែងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

*(ដើម្បីរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

*(សាក្សីថ្មីចូលក្នុងបន្ទប់សវនាការ)*

[១៥:២៣:០០]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកឈ្មោះអី?

កុំអាលទាន់ឆ្លើយតប ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការដោយភ្លើងក្រហម សឹមឆ្លើយតប!

**លោក សែម ហឿន៖**

**ឆ៖** បាទ ខ្ញុំឈ្មោះ សែម ហឿន នៅខេត្តកំពង់ធំ ស្រុកបារាយណ៍ -- ខេត្តកំពង់ធំ ឃុំបាក់ស្នា ស្រុកបារាយណ៍ ខេត្តកំពង់ធំ។

**ស៖** បាទ អរគុណ ហើយក្រៅពីឈ្មោះ ហឿន ហ្នឹង តើលោកធ្លាប់បានប្រើឈ្មោះអ្វីផ្សេងទៀតទេ? កុំអាលទាន់ឆ្លើយតប!

**ឆ៖** សម័យ ប៉ុល ពត ខ្ញុំប្រែឈ្មោះដាក់ឈ្មោះ សែម ហឿន។

**ស៖** ក្រៅពីឈ្មោះនេះ តើលោកមានដែល មានឈ្មោះហៅក្រៅផ្សេងទៀតដែរឬទេ?

**ឆ៖** អត់មានទេ។

**ស៖** ចុះឈ្មោះ គឹម ហ្នឹងយ៉ាងម៉េចដែរ?

**ឆ៖** ឈ្មោះ គឹម ដែល -- ឈ្មោះ សែម គឹម។

**ស៖** អ៊ីចឹងបានថា ពីមុនប្រើឈ្មោះ គឹម អ៊ីចឹង? សែម គឹម ដែលបច្ចុប្បន្ននេះប្រើឈ្មោះ សែម ហឿន អ៊ីចឹងទេ?

**ឆ៖** បាទ ឈ្មោះ ហឿន – ឈ្មោះ សែម ហឿន។

**ស៖** លោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ?

**ឆ៖** ខ្ញុំអត់បានចាំ។

**ស៖** លោកមានអាយុប៉ុន្មានឆ្នាំហើយ ឆ្នាំនេះ?

**ឆ៖** ខ្ញុំអាយុ ៦៣ហើយ។

[១៥:២៥:១៥]

**ស៖** លោក សែម ហឿន តើលោកប្រកបមុខរបរអ្វី<ដែរ>សព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំសព្វថ្ងៃប្រកបធ្វើស្រែចម្ការ។

**ស៖** បាទអរគុណ។ ឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតឈ្មោះ សែម ម្ដាយបង្កើត ឈ្មោះ ឃុត។ ស្លាប់ទាំងពីរ។

**ស៖** បាទ អរគុណ។ ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធឈ្មោះ ជុំ លី មានកូនប្រាំមួយនាក់។

**ស៖** អរគុណលោក សែម ហឿន។ តាមសមត្ថភាព និងលទ្ធភាពដែលលោកដឹង តើលោកមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប នួន ជា និងខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ នេះដែរឬទេ?

**ឆ៖** គឺអត់មាន ខ្ញុំអត់មានពាក់ព័ន្ធ។

**ស៖** បាទ អរគុណ។ ហើយមុននឹងចូលមក នៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកបានស្បថរួចហើយឬនៅ?

**ឆ៖** បានស្បថហើយ។

**ស៖** បាទ អរគុណលោក សែម ហឿន។ ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោក ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោក សែម ហឿន ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការដែលឲ្យលោកធ្វើអត្ថាធិប្បាយមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធ-ភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សីត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកលើកលែង តែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោក នាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់លោករួចហើយអម្បាញ់មិញនេះ។

[១៥:២៧:៤៩]

ក្នុងឋានៈជាសាក្សីលោកត្រូវតែឆ្លើយឲ្យការណ៍ តែការណ៍ណាដែលពិត ដែលលោកបានដឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគីសួរចំពោះលោក។

លោក សែម ហឿន តើលោកដែលផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងពេលកន្លងមក? ហើយប្រសិនបើដែល តើធ្វើប៉ុន្មានដង ធ្វើនៅពេលណា? ធ្វើនៅទីកន្លែងណា?

**ឆ៖** ខ្ញុំធ្លាប់ផ្តល់សក្ខីកម្មដែលចៅក្រមចុះទៅស៊ើបអង្កេតនៅភូមិអណ្តោត ឃុំបាក់ស្នា ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ តែប៉ុន្មានដងៗ ខ្ញុំវាអត់បានចាំ។

**ស៖** បាទ អរគុណ។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោក សែម ហឿន បានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្តល់ចម្លើយកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** ខ្ញុំបានអានចប់ហើយ ប៉ុន្តែចាំខ្លះ មិនចាំខ្លះ។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹងបាន តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំហ្នឹង វាពិតជាត្រឹមត្រូវ វាស៊ីចង្វាក់គ្នាស្របទៅនឹងចម្លើយដែលលោកបានធ្វើផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតការពីពេលមុននោះដែរ ឬទេ?

**ឆ៖** គឺត្រឹមត្រូវ និងស៊ីខ្សែចង្វាក់គ្នា។

**ប្រធានអង្គជំនុំ៖**

បាទ ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិ៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី សែម ហឿន មុនភាគីដទៃទៀតនៃរឿងក្តី។ ហើយសូមបញ្ជាក់ថាភាគីសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេលបីវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៥:៣០:៥០]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

សូមជម្រាបសួរលោកប្រធាន សូមជម្រាបសួរលោកសាក្សី ខ្ញុំនឹងសួរសំណួរ<ងាយៗអំពី

សាវតារ>របស់លោក។

**ស៖** តើត្រឹមត្រូវដែរឬទេលោកទៅសាលារៀនបានតែមួយឆ្នាំទេ?

**លោក សែម ហឿន៖**

**ឆ៖** បាទ អត់ៗច្បាស់ ម៉េច? សូមបញ្ជាក់ម្តងទៀត។

**ស៖** លោកសាក្សី តើលោកបានរៀនសូត្រអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំបានរៀនតែរយៈកាលខ្ញុំវារៀនតាំងពីតូចមក រៀនដល់ឆ្នាំ១៩៦៨ ខ្ញុំរៀនបានថ្នាក់ទី១២ ពីសង្គម។

**ស៖** តើត្រឹមត្រូវដែរឬទេ លោកបានរៀនតែ១ឆ្នាំ<តែប៉ុណ្ណោះ>?

**ឆ៖** រៀនតែ១ឆ្នាំទេ។ ដល់៦៨ ប្រទេសជាតិត្រូវរដ្ឋប្រហារ។

**ស៖** តើលោក<ធ្លាប់>បានបួសជាព្រះសង្ឃដែរឬទេ?

**ឆ៖** គឺអត់បានទេ គឺគេរំលាយព្រះសង្ឃអស់ហើយ។

**ស៖** នៅពេលដែលលោកនិយាយថានៅ "ពេលនោះ គឺគេផ្សឹកលោកសង្ឃអស់ហើយ"។ តើ<ពេលនោះដែលលោកនិយាយនោះ>នៅក្នុងឆ្នាំណា<>ដែលគេបង្ខំឲ្យព្រះសង្ឃសឹកនោះ?

**ឆ៖** បង្ខំនៅឆ្នាំ១៩៧១ គឺបង្ខំព្រះសង្ឃឲ្យជិះកង់ ឲ្យសឹក ឲ្យធ្វើគេហៅថាពលកម្ម។ ហ្នឹងចាប់ផ្តើមគេបង្ខំព្រះសង្ឃហើយ។

**ស៖** <>តើអ្នកណាជាអ្នកបង្ខំឲ្យព្រះសង្ឃសឹកទាំងនោះ? <>

**ឆ៖** គឺបង្ខំឲ្យព្រះសង្ឃសឹកនៅពេលនោះ គឺប៉ុល ពត និងខ្មែរក្រហមហ្នឹងឯង អ្នកបង្ខំ។

**ស៖** សូមអរគុណ។ អ៊ីចឹងគឺថា ដោយសារថាលោកមានឱកាសរៀនសូត្របានតែ១ឆ្នាំមុនពេលរដ្ឋប្រហារ ហើយក៏មិនធ្លាប់បានបួសជាព្រះសង្ឃ តើលោកចង់និយាយថាលោកអាចៗអានអក្សរខ្មែរបានទេ ឬក៏មិនអាចអាន សរសេរបានទេ?

**ឆ៖** ខ្ញុំអាចសរសេរបានបន្តិចបន្តួច ហើយនិងអានបានបន្តិចបន្តួច ម៉ាធម្មតា។

[១៥:៣៤:០០]

**ស៖** លោកបានបញ្ជាក់ថាលោកបានអានចម្លើយដែលលោកបានឆ្លើយកាលពីមុន ប៉ុន្តែអ្វីដែលខ្ញុំមាននោះគឺថា មានកំណត់ហេតុស្តាប់ចម្លើយពីរដែលលោកបានផ្តល់ទៅតុលាការ បាទដែលជាចម្លើយខ្លីៗទៅដល់អ្នកស៊ើបអង្កេតនៃ អ.វ.ត.ក ហើយបទសម្ភាសន៍ដ៏វែងមួយដែលលោក<ម្នាក់ឈ្មោះ ផាន់

សុជា>មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា <សួរទៅលោក>។ តើលោកបានអានកំណត់ហេតុទាំងបីហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំបានអានទាំងបីហើយ ប៉ុន្តែដល់ពេលខ្ញុំយូរទៅ ខ្ញុំវាភ្លេចភ្លាំងខ្លះ។

**ស៖** ខ្ញុំមិនទទួលបានការបកប្រែនោះទេ ប្រហែលមកពីឧបករណ៍ ឬក៏បញ្ហាអ្វី។ សហសេវិកបានថាសហសេវិកថាបានអានទាំងបី។ តើពេលដែលលោកអានកំណត់ហេតុទាំងបី តើមានចំណុចណាដែល<លោកឃើញថា>មិនស្របគ្នាដែរឬទេព័ត៌មាននៅក្នុងនោះ?

**ឆ៖** អានទាំងបីឯកសារហ្នឹង វាអត់មានខ្វែងគ្នា អត់មានពាក់ព័ន្ធអីជាមួយគ្នាទេ តែវាបានសមស្របទៅតាមឯកសារ។

**ស៖** តើ<លោក>កើតឆ្នាំ<>អី<?> ដូចថាឆ្នាំ ជូត ឆ្លូវ ខាល ថោះ ហើយបើតំណាងសត្វហ្នឹង គឺសត្វអ្វី<>?

**ឆ៖** គឺខ្ញុំកើតនៅឆ្នាំមមី តំណាងឲ្យសត្វសេះ។

**ស៖** គឺឆ្នាំមមី គឺឆ្នាំ១៩៤៣? តើលោកចាំខែដែលលោកកើតដែរឬទេ?

**ឆ៖** ខ្ញុំអត់បានខែទេ ចាំតែថ្ងៃ ហើយខ្ញុំកើតនៅឆ្នាំមមី នៅថ្ងៃព្រហស្បតិ៍។

**ស៖** នៅក្នុងចម្លើយនោះគឺអង់គ្លេស 00205079 និយាយថាលោកបានកើតនៅខែវិច្ឆិកា – ខែ១១។ តើលោកចាំថាបានកើតនៅខែវិច្ឆិកា ដែរឬអត់ ដែរឬទេ?

**ឆ៖** ខ្ញុំអត់បានចាំ ខ្ញុំចាំតែថ្ងៃទេ ថ្ងៃព្រហស្បតិ៍ ហើយនិងឆ្នាំ។

[១៥:៣៧:៤០]

**ស៖** បាទ ពេលដែលថាលោកកើតនៅខែវិច្ឆិកា ឬក៏ពេលណាមួយក្រោយពីខែមេសា ឆ្នាំ១៩៤៣ ឆ្នាំមមី <អ៊ីចឹង>នៅក្នុងខែមេសា ឆ្នាំ១៩៧០ លោកអាយុបាន១៦ឆ្នាំហើយ តើការគណនារបស់ខ្ញុំហ្នឹងត្រូវ ឬក៏យ៉ាងដូចម្ដេចដែរ?

**ឆ៖** គឺត្រូវៗតាម ព្រោះខ្ញុំឆ្នាំ៦៨ ខ្ញុំអាយុ១៨ហើយ។ ឆ្នាំ៧០ ខ្ញុំអាយុ១៩ ខ្ញុំចេញទៅ គេប្រមូលខ្ញុំទៅធ្វើទ័ព។

**ស៖** តើអាយុលោកនៅឆ្នាំ១៩៧០ ណាមួយត្រូវជាង ឬក៏ព័ត៌មានដែលថាលោកកើតនៅឆ្នាំមមីបើរាប់ទៅ វាត្រូវជាង។ តើណាមួយ?

**ឆ៖** ត្រូវជាង ត្រូវនឹងឆ្នាំមមី។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** សូមអរគុណ។ អ៊ីចឹងថាតើលោករៀបការនៅពេលណា?

**ឆ៖** ខ្ញុំរៀបការនៅឆ្នាំ១៩៧៩។

**ស៖** តើលោករៀបការ ឬក៏លីវនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺខ្ញុំនៅលីវ។

**ស៖** សូមអភ័យទោស ខ្ញុំមិនបានទទួលចម្លើយក្នុងការបកប្រែ។ លោកសាក្សី តើលោកបានចូល<កងទ័ពនៅ>ក្រោយពី<រដ្ឋប្រហារ>ឆ្នាំ<១៩៧០ ដែរឬ>ទេ?

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយតប!

[១៥:៤០:២៤]

**លោក សែម ហឿន៖**

**ឆ៖** នៅឆ្នាំ១៩៧២ ខ្ញុំនៅធ្វើទ័ពនៅសមរភូមិមុខ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តើកាលនោះ លោកធ្វើកងកម្លាំង តើបម្រើឲ្យចលនាងខាងណា? <>

**ឆ៖** គឺសម័យនោះ ខ្ញុំធ្វើបម្រើកងទ័ពរណសិរ្សសង្គ្រោះជាតិ។

**ស៖** សូមអរគុណ។ តើ<នៅជាកងទ័ព លោកបម្រើការ>នៅក្នុងអង្គភាពណា<>?

**ឆ៖** ខ្ញុំនៅអង្គភាពកងពល៣១០ – កងពល៣១០ វរសេនាធំ១២ វរសេនាតូច១២៣ អនុសេនាធំទី៥។

**ស៖** តើលោកចាំកងអនុសេនា<ធំ របស់លោកដែរឬ>ទេ?

<>

**ប្រធានអង្គជំនុំ៖**

លោកសាក្សីមិនគប្បីអានទេ កាលណាលោកចាំ លោកថាចាំទៅ លោកមិនអាចមើលឯកសារដើម្បីឆ្លើយតបទេណា នេះជាការពិភាក្សាដេញដោលផ្ទាល់មាត់ បើលោកអាចចាំបាន លោកឆ្លើយថាចាំទៅ ចាំមិនបាន លោកឆ្លើយថាមិនចាំទៅ ជាការស្រេចហើយ។

លោកចាំសំណួរទេ? បើលោកមិនចាំសំណួរ សូមសហព្រះរាជអាជ្ញាអន្តរជាតិតាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីចំពោះសាក្សី ទំនងសាក្សីភ្លេចសំណួររបស់លោកហើយ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** បាទ លោកសាក្សី តើ បើសិនជាលោកមិនចាំទេ ឬក៏លោកមិនដឹងចម្លើយសូមលោកសាក្សីប្រាប់ថា លោកមិនចាំ ឬមិនដឹងទេ<។> ហើយយើងខ្ញុំមិនចង់ឲ្យលោក<ឆ្លើយដោយ>ស្មាន<ៗ>នោះទេ។ ការឆ្លើយថា<ខ្ញុំ>មិនដឹង<ទេ គឺគ្មានអ្វីខុសឡើយ។ ហើយយើងចង់ឲ្យលោកឆ្លើយនូវ>ចម្លើយ<>ដែលលោកបានដឹង បានឮ និងបាន<ចងចាំផ្ទាល់។> តើលោកនៅចាំកងអនុសេនាធំ<ដែលលោកនៅទេ? លោកបានប្រាប់ថាលោកនៅវរសេនាធំ១២ វរសេនាតូច១២៣។ តើលោកចាំ>កងអនុសេនាធំរបស់លោក<ដែរឬទេ>?

ខ្ញុំអត់ទាន់បានទទួលចម្លើយពីលោកទេ លោកសាក្សី។ តើលោកនៅចាំឈ្មោះកងអនុសេនាធំដែរឬទេ? សូមលោកចាំដល់មេក្រូហ្វូនមានភ្លើងក្រហម ចាំឆ្លើយ។

[១៥:៤៤:៣៥]

**លោក សែម ហឿន៖**

**ឆ៖** ខ្ញុំចាំអនុសេនាធំខ្ញុំ អនុសេនាធំទី៥។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់ចាប់ផ្តើមពីខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលកងទ័ពខ្មែរក្រហមចូលភ្នំពេញ <លោកចាំទេ>តើលោកនៅទីណានៅពេលនោះ?

**ឆ៖** ឆ្នាំ១៩៧៥ ខ្ញុំបានចូលមកទីក្រុងភ្នំពេញគឺខ្ញុំនៅនឹងក្រុងភ្នំពេញហ្នឹង ខ្ញុំនៅវត្តភ្នំ ផ្សារថ្មី វត្តភ្នំ។

**ស៖** តើនៅពេលនោះ លោកមានតួនាទីជាអ្វី<>នៅក្នុងកងអនុសេនាធំ៥ <នៃ>កងវរសេនា<តូច១២៣>?

**ឆ៖** ខ្ញុំនៅ -- ក្នុង១៩៧៥ហ្នឹង ខ្ញុំនៅជាអនុកងតូច។

**ស៖** តើលោកធ្វើជានីរសារ? តើលោកជា<យុទ្ធជន? តើ>លោកមាន<នាទីជា>អ្វី?

**ឆ៖** គឺខ្ញុំនៅធ្វើទ័ព នីរសារខ្ញុំអត់ដែលបានធ្វើ។

**ស៖** តើមេបញ្ជាការកងអនុសេនាធំឈ្មោះអ្វី?

**ឆ៖** កងអនុសេនាធំ ខ្ញុំអង្គាល់ណោះវាភ្លេចទៅហើយ វាអត់បានចាំទេ ព្រោះវាយូរទៅហើយវាភ្លេចឈ្មោះអស់ខ្លះ។

**ស៖** តើលោកនៅចាំមេបញ្ជាការកងវរសេនាតូច<១២៣>ដែរឬទេ<>?

**ឆ៖** បាទ ខ្ញុំចាំបានវរសេនាតូចឈ្មោះ អេត។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** សូមអរគុណ។ ចុះកងវរសេនាធំនៅពេលដែលខ្មែរក្រហមកាន់កាប់បានភ្នំពេញឆ្នាំ១៩៧៥ ខែមេសា នោះថាតើមេបញ្ជាការកងវរសេនាធំ<លេខ១២>នោះឈ្មោះអ្វី<>?

**ឆ៖** ខ្ញុំភ្លេចឈ្មោះគាត់ហើយ។ ដល់ពេលដែលទ័ពពួក -- *(ឮមិនច្បាស់)* មកក្តោបក្តាប់អីចឹងទៅ ក៏គេចាប់គាត់ទៅបាត់ទៅ ក៏ខ្ញុំវាភ្លេចឈ្មោះគាត់។

[១៥:៤៨:០៦]

**ស៖** សូមអរគុណ។ ចុះមេបញ្ជាការកងពលវិញ តើលោកចាំទេគាត់ឈ្មោះអ្វី?

**ឆ៖** គឺបញ្ជាការកងពល គឺខ្ញុំចាំឈ្មោះ អឿន។

**ស៖** ហើយលោកនិយាយថា មេបញ្ជាការកងវរសេនាធំ គឺត្រូវបានចាប់ខ្លួនមិនយូរប៉ុន្មានពីលោកទេ < -- មិនយូរប៉ុន្មាន>ក្រោយពីការដួលរលំនៃភ្នំពេញ។ តើលោកនៅចាំពីមូលហេតុដែលគេចាប់ខ្លួនគាត់ដែរឬទេ?

**ឆ៖** ខ្ញុំមិនចាំបានទេ គ្រាន់តែដឹងដំណឹងថាគេចាប់ខ្លួនគាត់តែម្តង។

**ស៖** ចុះលោកសាក្សីផ្ទាល់ តើ<កម្លាំងខ្មែរក្រហម>ធ្លាប់ចាប់ខ្លួនលោកដែរឬទេ<>?

**ឆ៖** ទេ មិនដែលចាប់ខ្លួនខ្ញុំទេ គ្រាន់តែគេនៅក្នុងតាមដានក្នុងសកម្មភាព គេចោទខ្ញុំវាជាប់ជាខ្សែហៅថា ខ្សែក្បត់ ឬក៏មេកងពលគឺក្បត់ហើយ ខ្ញុំជាប់ក៏ទៅជាសមាសភាពគេតាមដាន។

**ស៖** នៅក្នុងកងពល៣១០របស់លោក តើ<យុទ្ធ>មិត្តទាំងអស់ ឬក៏ភាគច្រើននៅក្នុងកងពល<នោះ>មកពីកន្លែង ឬក៏មកពីតំបន់<តែមួយមែនទេ? តើលោកមកពីណាដែរ>?

**ឆ៖** គឺកងទ័ពដែលប្រមូលបានហ្នឹងមកគ្រប់តំបន់ គ្រប់ខេត្ត គ្រប់ស្រុក។

**ស៖** តើមានភាគច្រើននៅក្នុងកង<ពល>របស់លោកនោះ មកពីកំពង់ធំ<មែន>ដែរឬទេ?

**ឆ៖** គឺក្នុងកងពល ក្នុងអនុសេនាធំខ្ញុំហ្នឹងវាច្រើនមកពីកំពង់ធំខ្លះ កំពង់ចាមខ្លះ គ្រប់ខេត្តតែម្តងរួមគ្នាមក ប៉ុន្តែច្រើន ភាគច្រើន គឺប្រមូលមកពីខាងកំពង់ធំ ភូមិភាគឧត្តរហ្នឹង។

**ស៖** លោកបាននិយាយថា ប្រធានវរសេនាធំត្រូវបានគេចាប់ខ្លួន ហើយគេចោទថា ជាក្បត់ជាតិ ហើយគេប្រាប់លោកថា លោកជាប់និន្នាការ ជាប់ខ្សែ។ តើលោកផ្ទាល់ហ្នឹង តើលោកមានពាក់ព័ន្ធអីទៅនឹងសកម្មភាព<>ក្បត់<>ហ្នឹងដែរឬទេ?

[១៥:៥១:១៧]

**ឆ៖** ព្រោះខ្ញុំដែលជាប់គេចោទថា ខ្ញុំជាប់សមាសភាពហ្នឹង ព្រោះវរសេនាធំក៏ ប៉ុល ពត ចាប់

ប្រធានកងពលក៏ ប៉ុល ពត ចាប់។ អ៊ីចឹងគេចាត់ទុកអង្គភាពហ្នឹង ជាអង្គភាពជាប់សមាសភាពមិនល្អ ជាប់ខ្សែរយៈក្បត់។

**ស៖** តើមានយោធាណាម្នាក់ដែលលោកបានស្គាល់ ឬក៏រូបលោកផ្ទាល់តើលោកជាសមាជិកនៃខ្សែ កា.ហ្សេ.បេ ឬក៏ ស៊ី.អ៊ី.អា ដែរឬទេ<>?

**ឆ៖** ខ្ញុំមិនដែលបានជាប់ជំពាក់នឹងខ្សែ សេ.អ៊ុ.អា ក៏ខ្ញុំមិនដែលបានជាប់ជំពាក់, កា.ហ្សេ.បេ ក៏ខ្ញុំមិនដែលបានជាប់ជំពាក់។ គ្រាន់តែឮពាក្យស្តោករបស់ អាពត ថា "អ្នកឯងមេក្បត់ហើយ មេកងពលក្បត់ហើយ មេវរសេនាធំក្បត់ហើយ វរសេនាតូចក្បត់ហើយ អ្នកឯងសុទ្ធតែខ្សែ សេ.អ៊ុ.អា, កា.ហ្សេ.បេ ហើយអ្នកឯងត្រូវជាប់ ហៅថា និន្នាការនយោបាយក្បត់"។

**ស៖** សូមអរគុណលោកសាក្សី។ ចំពោះបងប្អូនបង្កើតរបស់លោកវិញ <តើលោក>មានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ? បងប្រុស ប្អូនប្រុស ឬក៏ស្រីដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទ មានបងប្អូនមានចំនួនបួននាក់ ស្រីមួយ ប្រុសបី។ បងទី១ គឺ គេ ប៉ុល ពត ចាប់យកទៅសម្លាប់ហើយ ហើយនៅតែរូបខ្ញុំមួយ ហើយនិងបងទី៣ មួយ ហើយនិងបងស្រីមួយ។

**ស៖** តើលោកដឹងពីមូលហេតុដែលគេយកបងប្រុសលោកយកទៅសម្លាប់នៅក្នុងរបបខ្មែរក្រហមនោះដែរឬទេ?

**ឆ៖** គេយកបងខ្ញុំទៅ ថាខ្ញុំហ្នឹងវាជាប់ជំពាក់នឹងខ្សែក្បត់។

[១៥:៥៤:១០]

**ស៖** ដោយសារថា គេចោទលោកថា <>ជាប់ខ្សែក្បត់ អ៊ីចឹងជាមូលហេតុដែល<>នាំឲ្យគេចាប់បងប្រុសរបស់លោកយកទៅសម្លាប់<។> តើ<ខ្ញុំយល់>ហ្នឹង<ត្រឹមត្រូវទេ>?

**ឆ៖** បាទ គេតាមដានទៅថា ខ្ញុំជាប់ជំពាក់នឹងខ្សែក្បត់ ព្រោះភូមិភាគឧត្តរ គឺសុទ្ធតែខ្សែក្បត់ទាំងអស់។

**ស៖** លោកសាក្សី តើបងប្រុសរបស់លោកហ្នឹង ជាសមាជិកនៃកងពល៣១០ <ឬគាត់នៅកងពលផ្សេងនៃ>ភូមិភាគឧត្តរហ្នឹង<>?

**ឆ៖** បាទ គាត់អត់មាននៅជាមួយខ្ញុំទេ គាត់នៅអង្គភាពដោយឡែកទេ។ ខ្ញុំនៅកងពល៣១០ គាត់នៅជាប់តំបន់ ប៉ុន្តែខ្ញុំអត់ស្គាល់លេខគាត់ទេ គ្រាន់តែបានជួបគ្នា ដែលរំដោះឆ្នាំ១៩៧៥ បានជួបគ្នាតែម្តងហ្នឹងឯង។

**សៈ** តើបងប្រុសរបស់លោក តើមានតំណែងអ្វីកាលពីរបបចាស់ <>សម័យ<សម្តេចឪ> នរោត្តម សីហនុ ដែរឬទេ?

**ឆៈ** បងប្រុសខ្ញុំគ្រាន់តែថា ពេលសម័យរាស្ត្រនិយម គឺគាត់ធ្លាប់ថា ទំនាក់ទំនងជាមួយរាជការ ប៉ូលិស ទាហានអីហ្នឹង គាត់ធ្លាប់ទំនាក់ទំនង។ ហើយពេលសម័យកើតខ្មែរក្រហមហ្នឹង គាត់សហការ ជាមួយប៉ូលិស ទាហាន ហ្នឹងដើម្បីដើររុករកខ្មែរក្រហម។

[១៥:៥៦:១៨]

**សៈ** តើលោកបានដឹងដែរឬទេ ថាដោយសារតែគាត់<ធ្លាប់>មានទំនាក់ទំនងទៅនឹង<អតីត>រដ្ឋាភិបាល<>សម្តេច សីហនុ <ទើប>គេចាប់គាត់យកទៅសម្លាប់ <អ៊ីចឹងមែនទេ>?

**ឆៈ** បាទ ខ្ញុំកាលសម័យនោះ គឺខ្ញុំនៅតូចទេ ខ្ញុំអត់ទាន់បានចាំទេ គ្រាន់តែខ្ញុំបានឃើញ ហើយ និងខ្ញុំបានយល់ ឃើញគាត់ទំនាក់ទំនងជាមួយប៉ូលិស ទាហាន ដែលឡើងទៅបង្រ្កាបខ្មែរក្រហមពី សម័យមួយជំនាន់ឆ្នាំ១៩៦៨ ហ្នឹងដែលកើតខ្មែរក្រហមផ្ទុះ កើតខ្មែរក្រហមហ្នឹង គឺគាត់ទំនាក់ទំនង។ តែក្រោយមក ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំនៅតូច ខ្ញុំមិនចាំច្បាស់ទេ។

**សៈ** តើបងប្រុសរបស់លោក<>ដែលខ្មែរក្រហម<ចាប់>គាត់ទៅសម្លាប់នោះ<មានឈ្មោះ អ្វី>?

**ឆៈ** បងប្រុសខ្ញុំឈ្មោះ អិន ជេត។ ជីតាត្រកូលគាត់ឈ្មោះ អិន គាត់ ឈ្មោះ ជេត។ រួចត្រកូល ខ្ញុំ ដាក់ឈ្មោះ សែម១ ហ្នឹង ខ្ញុំយកឪពុកខ្ញុំទេ ដាក់ត្រកូល។

**សៈ** ខ្ញុំសួរពីមេបញ្ជាការកងពលឈ្មោះ អឿន ដែល<លោកថា>គេ<>ចាប់ខ្លួន<នោះ> តើគេ ចាប់ខ្លួនគាត់នៅខែឆ្នាំណា លោកចាំទេ?

**ឆៈ** ខ្ញុំចាំនៅក្នុងឆ្នាំ១៩៧៥ ប៉ុន្តែនៅចុងឆ្នាំ។ ប៉ុនខែណា ខ្ញុំអត់បានចាំដែរ។

**សៈ** ខ្ញុំនឹងព្យាយាមជួយលោក។ តើលោកនៅកន្លែងណា នៅពេលដែលលោកបានឮថា គេចាប់ខ្លួនលោក អឿន ហ្នឹង? តើលោកនៅចាំទេ លោកនៅកន្លែងណា<>?

**ឆៈ** ខ្ញុំនៅធ្វើស្រែទួលគោក។

**សៈ** តើលោកបានឮផងដែរទេថា គេក៏បានចាប់<>លេខានៅភូមិភាគឧត្តរ <>ឈ្មោះ កុយ ធួន<>ដែរឬទេ?

[១៥:៥៩:១៥]

**ឆ៖** ខ្ញុំបានឮហើយ បានទទួលព័ត៌មាន ហើយកងរួមគ្នាហ្នឹងក៏ផ្តល់ថា ឥឡូវ គេចាប់ តាធុច តាកុយ ធួន ហើយក៏ តាធុច, តាកុយធួន ហ្នឹងដើរខ្សែក្បត់។ បានក្រោយមក បានគេចាប់មេកងពលខ្ញុំហ្នឹងចាប់រួចបានគេហៅខ្ញុំថា "សមមិត្តទាំងអស់ ត្រូវឡើងទៅរៀន" ឡើងទៅរៀន ដល់ពេលខ្ញុំមកដល់វត្តភ្នំ គេតម្រង់ជួរទាំងអស់ ឱ្យខាងនីរតីហ្នឹងគេមកទទួលតំណែងពីគាត់ហ្នឹងឯង។ ដល់ពេលអ៊ីចឹងទៅ គេថាឱ្យខ្ញុំដោះអាវ លើកដៃអ៊ីចឹងឆែក ឆែកមើលៗ រួច គេឱ្យពាក់អាវទៅវិញ។ បានគេនិយាយថា "ហ្វូងអស់អ្នែងនេះ មេអ្នែងគឺក្បត់ហើយ ហ្វូងអ្នែងនេះក៏សុទ្ធតែក្បត់ដែរ"។ អាហ្នឹងខ្ញុំដឹងព័ត៌មាន គឺច្បាស់តែប៉ុណ្ណឹង។

**ស៖** លោក តើវាជាការចម្លែកដែរឬទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលថា ខ្មែរក្រហមប្រាប់លោកក្រោយពេលដែលគេចាប់ខ្លួននរណាម្នាក់ ហើយសម្លាប់នរណាម្នាក់ដោយសារតែពួកហ្នឹងជាបណ្តាញជនក្បត់<នោះ?> តើវាជារឿងដែលគេ<អនុវត្ត>ជាទូទៅ ឬក៏វាជារឿងដែលគេធ្វើម្តងម្កាលទេ<? តើលោកអាចប្រាប់បានទេ>?

**ឆ៖** អាហ្នឹងដែលខ្ញុំទទួលព័ត៌មានគឺព័ត៌មានវា -- ម្តងម្កាលទេ តែខ្ញុំអត់បានដឹងទេ ថារាល់ថ្ងៃ ឬរាល់ពេលវេលាហ្នឹង គឺអត់ៗមានបានដឹងទេ។

**ស៖** លោកបានចូលរួមប្រយុទ្ធនៅក្នុងសមរភូមិជាច្រើនក្រោមការបញ្ជារបស់<អឿន>។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំបានប្រយុទ្ធច្រើនសមរភូមិណាស់។ សមរភូមិសឹងថាមួយភូមិភាគឧត្តរ ខ្ញុំអត់មានចន្លោះសមរភូមិណាមួយទេ ព្រោះខ្ញុំនៅជាកងទ័ពរហូតតាំងពីឆ្នាំ៧០មក។

**ស៖** តើលោកអាចប្រាប់<>ពី<>សមរភូមិមួយចំនួនដែលលោកបានវាយប្រយុទ្ធក្រោមការបញ្ជារបស់<គាត់បាន>ទេ?

**ឆ៖** បាទ ខ្ញុំបាទអាចប្រាប់បាន។ ក្នុងឆ្នាំ១៩៧៣ ខ្ញុំទៅសមរភូមិសៀមរាប សមរភូមិឧត្តរមានជ័យ ឆ្នាំ១៩៧០ -- ចុងឆ្នាំ៧៣ គឺខ្ញុំដកពីឧត្តរមានជ័យមក ខ្ញុំនៅការពារអង្គរវត្តរយៈ១ឆ្នាំដាច់។ ប្រហែលជានៅនេះ គេដកយន្តហោះពីកម្ពុជា ខ្ញុំចុះមកសមរភូមិកំពង់ចាម។ មកសមរភូមិកំពង់ចាមរួចខ្ញុំចុះមកសមរភូមិព្រែកព្នៅនេះ ហើយខ្ញុំចប់ពីព្រែកព្នៅ ដកខ្ញុំទៅសមរភូមិអង្គស្នួល ខាងៗកំពង់ស្ពឺបាទ តែប៉ុណ្ណឹងបាទ សមរភូមិដែលខ្ញុំធ្លាប់បានប្រយុទ្ធ។

[១៦:០៣:១៧]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមានសំណួរច្រើនតទៀត ប៉ុន្តែខ្ញុំមើលទៅឃើញថាដូចជាដល់ម៉ោងហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ បាទ។

បាទ សវនាការថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២២ ខែមិថុនា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃចន្ទដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី សែម ហឿន ហើយបន្ទាប់មកពី សែម ហឿន អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-901 ហើយសូមបញ្ជាក់ថាថ្ងៃស្អែក និងថ្ងៃសុក្រទី១៩ ខែមិថុនា ឆ្នាំ២០១៥ ចុងសប្តាហ៍នេះ អង្គជំនុំជម្រះមិនធ្វើសវនាការទេ ព្រោះជាថ្ងៃឈប់សម្រាកបុណ្យជាតិ។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

[១៦:០៤:១៥]

អង្គជំនុំជម្រះអរគុណ លោកសែម ហឿន ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឱ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយឥឡូវនេះ លោកអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពការពារសាក្សី និងអ្នកជំនាញជូនលោក សែម ហឿន វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏កន្លែងណាដែលគាត់ស្នាក់នៅវិញចុះ និងសូមអញ្ជើញគាត់មកចូលរួមសវនាការបន្តផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយនៅវេលាម៉ោងប្រាំបួនព្រឹក។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃចន្ទ ទី២២ ខែមិថុនា ឆ្នាំ២០១៥ ឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*